ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- តុលាការកាត់ទោសខ្មែរក្រហម៖ សកម្មភាព និងព្រឹត្តិការណ៍
- តួនាទីរបស់សហគមន៍ក្នុងការផ្សព្វផ្សាយព័ត៌មានអំពីសាលាក្តីខ្មែរក្រហម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១០៥ ខែកញ្ញា ឆ្នាំ២០០៨

# ស្វែងរកការពិត

លេខ១០៥ ខែកញ្ញា ឆ្នាំ២០០៨


## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


◆ តុលាការកាត់ទោសខ្មែរក្រហម ៖ សកម្មភាព និងព្រឹត្តិការណ៍ ................. ១

**ផ្នែកឯកសារ**

◆ ជនជាតិអារ៉ាប់ដែលត្រូវបានដោះលែងពីគុកទួលស្លែង .......................... ៧

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ កាលប្បវត្តិសំខាន់ៗរបស់តុលាការខ្មែរក្រហម .................................. ៦

◆ អ្នកនឹងក្លាយជាដីនៅវាលស្រែ ..................................................... ១៧

◆ គម្រោងជួយជនរងគ្រោះដាក់ពាក្យបណ្តឹង .................................... ១ ៤

◆ រំឭកប្រាប់ក្មេងជំនាន់ក្រោយ ....................................................... ១ ៦

◆ ផលប៉ះពាល់ក្រោយរបបខ្មែរក្រហម ............................................. ១៨

◆ តួនាទីរបស់សហគមន៍ក្នុងការផ្សព្វផ្សាយព័ត៌មាន .............................. ២ ០

◆ របាយការណ៍ពីខេត្តសៀមរាប .................................................... ២៦

◆ ដំណើរទស្សនកិច្ចរបស់សិស្សវិទ្យាល័យនិងយុវជនមូស្លីម ..................... ៣៧

**ផ្នែកច្បាប់**

◆ ដីកាសម្រេចពីការបន្តថេរវេលាឃុំខ្លួនបណ្តោះអាសន្នរបស់ ............. ៣ ៨

◆ ការវិភាគទៅលើដីកាដំណោះស្រាយបញ្ជូនសំណុំរឿង .................... ៤១

◆ សេចក្តីប្រកាសព័ត៌មាន ............................................................ ៤៥

**វេទិកាពិភាក្សាសាធារណៈ**

◆ សត្រូវខាងក្នុងនិងខាងក្រៅ ........................................................ ៤៦

◆ ដំណើរហេតុ ៖ ការកាត់ទោសខ្មែរក្រហមនិងយុត្តិធម៌ .................... ៥៥

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ កុំបោះបង់ខ្ញុំអី ..................................................................... ៥ ៦

◆ កំព្រាឪពុកម្តាយ .................................................................. ៥៩





និស្សិតកំពុងមើលវិន័យសន្តិបាលរបស់ខ្មែរក្រហមនៅទួលស្លែង




**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



**ស្នេរលេខនេះ ៖** អានី ដែល, ហ៊ិន សុធានី, ដេង ពង្សរ៉ាស៊ី, ស៊ីវ សាវីណា, សារ៉ា ថូម៉ាស និង ជី ទេវិទ្ធិ, ម៉ាហ្គារីតា ក្លាវែន, អ៊ីលីហ្សាបែ ដូ,, គីម សុវណ្ណ
**អ្នកនិពន្ធនិងស្រាវជ្រាវ ៖** គាត លក្ខិណា, សោម ប៊ុនថន **អ្នកបកប្រែៈ** ជា ផល្លា **និពន្ធនាយកទូទៅៈ** ឆាំង យុ **ជំនួយការនិពន្ធនាយកៈ** ទេព ម៉េងឃាន
**ក្រាហ្វិកកុំព្យូទ័រៈ**ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** ឆេង វេង Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ ៖*

# តុលាការកាត់ទោសខ្មែរក្រហម ៖ សកម្មភាពនិងព្រឹត្តិការណ៍

***អង្គបុរេជំនុំជម្រះបានដាក់ចេញទាន់នូវការឲ្យនៅបែកពីគ្នារបស់ជនត្រូវចោទ***

នៅថ្ងៃទី២៦ ខែកញ្ញា អង្គបុរេជំនុំជម្រះបានដាក់ចេញទាន់នូវការបង្គាប់របស់សហចៅក្រមស៊ើបអង្កេតហាមឃាត់ការទាក់ទងគ្នារបស់ជនត្រូវចោទ ។ យោងទៅតាមច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិនិងតុលាការសិទ្ធិមនុស្សនៅអឺរ៉ុប ព្រមទាំងការអនុវត្តនៅក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះយល់ឃើញថា ការដាក់កំហិតទៅលើការទាក់ទងគ្នារវាងជនត្រូវចោទអាចត្រូវបានធ្វើឡើងដរាបណាមានភ័ស្តុតាងនៃហានិភ័យមួយច្បាស់លាស់បង្ហាញពីការឃុបឃិតដើម្បីដាក់សម្ពាធទៅលើសាក្សីនិងជនរងគ្រោះ ។

***ពន្យារពេលឃុំឃាំង នួន ជា***

នៅថ្ងៃទី១៦ ខែកញ្ញា សហចៅក្រមស៊ើបអង្កេតបានពន្យារពេលឃុំឃាំង នួន ជា ១ឆ្នាំបន្ថែមទៀត ។ នួន ជា បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកានេះ ។ វិធាន៦៣ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានអនុញ្ញាតឲ្យឃុំខ្លួនជនត្រូវចោទពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងឧក្រិដ្ឋកម្មសង្គ្រាមរយៈពេលមួយឆ្នាំដំបូង ហើយអាចពន្យារពេលពីរដងទៀត ប្រសិនជាមានលក្ខខណ្ឌចាំបាច់ ។

***ប្រទេសអាមេរិកបានផ្តល់ជំនួយដោយផ្ទាល់ជាលើកដំបូងទៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា***

ក្នុងខែកញ្ញានេះ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានសន្យាផ្តល់ជំនួយជាលើកដំបូងទៅដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលមានទឹកប្រាក់ចំនួន១លាន៨សែនដុល្លារសហរដ្ឋអាមេរិកសម្រាប់ភាគីអង្គការសហប្រជាជាតិ ។ យោងទៅតាមរបាយការណ៍បានឲ្យដឹងថានឹងមានជំនួយបន្ថែមរបស់សហរដ្ឋអាមេរិកនៅពេលក្រោយ ។

***ចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានកែប្រែនីតិវិធីច្បាប់***

ចាប់ពីថ្ងៃទី១-៥ ខែកញ្ញា ចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានជួបគ្នានៅក្នុងការប្រជុំពេញអង្គ ហើយបានអនុម័តច្បាប់វិសោធនកម្មវិធានផ្ទៃក្នុងរបស់តុលាការដែលទាក់ទងនឹងប្រធានបទមួយចំនួនដូចជា តំណាងដើមបណ្តឹងរដ្ឋប្បវេណី វិសាលភាពនៃបណ្តឹងឧទ្ធរណ៍ និងតុល្យភាពរវាងការរក្សាអាថ៌កំបាំងនិងតម្រូវការសម្រាប់សវនាការសាធារណៈ ។ ចៅក្រមក៏បានអនុម័តក្រមសីលធម៌តុលាការ ។

***ពាក្យបណ្តឹងដំបូងរបស់ដើមរដ្ឋប្បវេណីទាក់ទងនឹងការរំលោភសេពសន្ថវៈ***

ថ្ងៃទី៣ ខែកញ្ញា បុរសបួរភេទម្នាក់ត្រូវបានខ្មែរក្រហមចាប់រំលោភក្នុងខណៈពេលកំពុងឃុំឃាំងនិងត្រូវបានបង្ខំឲ្យរៀបការជាមួយនារីម្នាក់ បានដាក់ពាក្យបណ្តឹងដំបូងទាក់ទងនឹងការរំលោភសេពសន្ថវៈទៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

***អង្គបុរេជំនុំជម្រះបានសម្រេចទៅលើវិសាលភាពនៃសិទ្ធិរបស់ដើមបណ្តឹងដែលមិនមានអ្នកតំណាងឲ្យនិយាយដោយផ្ទាល់នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា***

នៅថ្ងៃទី២៩ ខែតុលា អង្គបុរេជំនុំជម្រះបានសម្រេចថា ៖ ១) ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានអ្នកតំណាងស្របច្បាប់អាចត្រូវបានអនុញ្ញាតឲ្យនិយាយដោយផ្ទាល់នៅអង្គបុរេជំនុំជម្រះនៅពេលដែលចំណាប់អារម្មណ៍របស់គាត់មានភាពខុសប្លែកពីការចោទប្រកាន់ ។ ២) រាល់ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានអ្នកតំណាងអាចទាមទារសិទ្ធិដើម្បីនិយាយដោយផ្ទាល់នៅអង្គជំនុំជម្រះនៅពេលមានសវនាការដែលបានរៀបចំទុក គួរតែដាក់សារណាជាលាយលក្ខណ៍អក្សរពន្យល់អំពីហេតុផលនិងការជាប់ពាក់ព័ន្ធគ្នានៃសារណាដែលបានស្នើយ៉ាងហោចណាស់ឲ្យបាន១០ថ្ងៃមុនពេលសវនាការ ។ ***(តទៅទំព័រ៤)***

# ជនជាតិអារ៉ាប់ដែលត្រូវបានដោះលែងពីគុកទួលស្លែង

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺជាថ្ងៃមហាជ័យជម្នះជាប្រវត្តិសាស្ត្ររបស់កងទ័ពបដិវត្តន៍ខ្មែរក្រហមដែលវាយរំដោះបានទីក្រុងភ្នំពេញ ។ ប្រជាជនកម្ពុជានាំគ្នាអបអរសាទរដោយសង្ឃឹមថាប្រទេសនឹងលែងមានសង្គ្រាម ហើយទទួលបានសន្តិភាពឡើងវិញ ។ ប៉ុន្តែក្តីសង្ឃឹមទាំងនេះត្រូវរលាយបាត់អស់ បន្ទាប់ពីកងទ័ពខ្មែរក្រហមបានចេញបញ្ជាឲ្យប្រជាជនចាកចេញពីផ្ទះសម្បែងក្នុងរយៈពេលបីថ្ងៃ ។ ខ្មែរក្រហមបា នអនុវត្តនូវគោលនយោបាយជ្រុលហួសហេតុរបស់ខ្លួន តាមរយៈការធ្វើបន្សុទ្ធកម្មពូជសាសន៍ដែលបណ្តាលឲ្យប្រជាជនកម្ពុជាស្លូតត្រង់ រួមទាំងជនបរទេសដូចជា ចិន វៀតណាម ថៃ ញូវសេឡែន បារាំង អូស្ត្រាលី និងអាមេរិកទទួលរងនូវទារុណកម្មនិងការសម្លាប់យ៉ាងសាហាវឃោរឃៅបំផុត ។ ក្នុងនោះគុកទួលស្លែងឬមន្ទីរស២១ គឺជាមណ្ឌលឃុំឃាំងធំជាងគេបំផុតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានអ្នកទោសប្រមាណ១៥.០០០នាក់ ត្រូវបានធ្វើទារុណកម្ម ហើយកម្ទេចចោលទាំងអស់ ។ នៅក្នុងចំណោមអ្នកទាំងនោះ សេក កាលខាន់ គឺជាអ្នកទោសម្នាក់ដែលមានឈ្មោះនៅក្នុងបញ្ជីកម្ទេចរបស់គុកទួលស្លែងដែរ ប៉ុន្តែក្រោយមកត្រូវបានអង្គការដោះលែងវិញ ដោយសារតែរកមិនឃើញកំហុស រួចក៏បញ្ជូនគាត់ឲ្យទៅធ្វើស្រែនៅសហករណ៍វិញ ។

## ជនជាតិអារ៉ាប់នៅស្រុកខ្មែរ

កាលខាន់ ជាជនជាតិអារ៉ាប់ មានស្រុកកំណើតនៅភូមិអារ៉ាប់ សង្កាត់លេខ៥ ក្រុងភ្នំពេញ (បច្ចុប្បន្នម្តុំស្ថានទូតចិន) ។ នៅក្នុងភូមិនេះមានគ្រួសារអារ៉ាប់រស់នៅសរុបទាំងអស់ប្រមាណ ៤០គ្រួសារ ដែលភាគច្រើនមកពីប្រទេសអារ៉ាប់រួម ប្រកបមុខរបរចិញ្ចឹមគោ ពពែ និងធ្វើជំនួញ ។ ឪពុករបស់ កាល់ខាន់ ឈ្មោះ អាឌុលហ្គោលី បានចាកចេញពីស្រុកកំណើត (អារ៉ាប់រួម) មករស់នៅក្នុងស្រុកខ្មែរតាំងពីឆ្នាំ១៨៩៨ ធ្វើជាកម្មករមើលថែទាំគោ និងពពែក្នុងកសិដ្ឋានរបស់គ្រួសារអារ៉ាប់ ។ នៅពេលមានអាយុ ២៥ឆ្នាំ ហ្គោលី បានរៀបការជាមួយនារីជនជាតិលាវឈ្មោះ សាលីមា៉ា បន្ទាប់មកប្រកបមុខរបរចិញ្ចឹមគោ ពពែ និងយកទឹកដោះគោលក់ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ ។

កាលខាន់ មិនចេះនិយាយភាសារ៉ាប់ទេ ព្រោះពីកុមារភាពរៀនតែអក្សរសាស្ត្រខ្មែរនិងភាសាបារាំងប៉ុណ្ណោះ ។ កាន់ខាន់ រៀនដល់ថ្នាក់ទី៥ (សង្គមចាស់) នៅសាលាបឋមសិក្សាចក្រវាល ដោយចេះអាននិងសរសេរបានយ៉ាងស្ទាត់ជំនាញ ។ ក្រោយរដ្ឋប្រហារទម្លាក់សម្តេច សីហនុ នៅឆ្នាំ ១៩៧០ កាលខាន់ សម្រេចចិត្តឈប់រៀនមកជួយការងារឪពុកម្តាយវិញដូចជា ច្របូតស្មៅ មើលថែទាំគោនិងពពែនៅកសិដ្ឋានដែលមានពាកន្លែងគឺ នៅម្តុំចាក់សំរាមស្ទឹងមានជ័យ ស្ថានទូតចិន និងក្នុងទីក្រុងភ្នំពេញ ហើយឆ្លៀតពេលទំនេរជួយលក់ទឹកដោះគោនៅផ្ទះថែមទៀត ។

## ចាកចេញពីផ្ទះ

ថ្ងៃជ័យជម្នះ ១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលដែលកងទ័ពខ្មែរក្រហមចូលមកដល់ក្រុងភ្នំពេញ ក៏បានឃោសនាប្រាប់ប្រជាជនថា «សូមបងប្អូនទាំងអស់ចាកចេញពីផ្ទះក្នុងរយៈពេល៣ថ្ងៃសិន ដើម្បីឲ្យអង្គការបោសសម្អាតខ្មាំងផ្ទៃក្នុង ប៉ុន្តែមិនចាំបាច់យកសម្ភារៈអ្វីទៅជាមួយទេ» ។ ប្រជាជនជាច្រើនបានយល់ព្រមចាកចេញពីគេហដ្ឋានតាមការឃោសនានេះ ប៉ុន្តែ កាលខាន់ ឃើញមានប្រជាជនតែ៤នាក់ប៉ុណ្ណោះដែលមិនព្រមចាកចេញតាមបញ្ជារបស់អង្គការ បន្ទាប់មកក៏ត្រូវកងយោធាខ្មែរក្រហមបាញ់សម្លាប់ចោលតែម្តង ។ ឃើញដូច្នេះ កាលខាន់ រួមជាមួយជនជាតិអារ៉ាប់ ៤គ្រួសារទៀតបានធ្វើដំណើរសំដៅទៅសង្កាត់ព្រែកប្រាដើម្បីស្នាក់នៅបណ្តោះអាសន្ននៅទីនោះត្រៀមចាំចូលមករស់នៅផ្ទះរបស់ខ្លួនវិញ ចំណែកប្រជាជនដែលមានស្រុកកំណើតនៅក្រៅទីក្រុងភ្នំពេញក៏ត្រឡប់ទៅរកបងប្អូនវិញដែរ ។ គ្រួសាររបស់ កាលខាន់ ត្រូវស្នាក់នៅភូមិព្រែកតាពៅ សង្កាត់ព្រែកប្រារយៈពេល ២០ថ្ងៃ ព្រោះឪពុកគាត់នៅស្តាយផ្ទះសម្បែងនិងទ្រព្យសម្បត្តិសេសសល់ដែលមិនបានយកមកជាមួយ ។ ថ្ងៃមួយស្រាប់តែកងយោធាខ្មែរក្រហមដែលយាមនៅក្នុងភូមិបានមកប្រាប់ថា «មិន

បាច់រង់ចាំទេ អង្គការមិនអនុញ្ញាតឲ្យចូលក្រុងឡើយ» ។ ដោយគិតថាគ្មានសង្ឃឹម ក្រុមគ្រួសាររបស់ កាលខាន់ ក៏បន្តដំណើរទៅស្នាក់នៅជាមួយប្រជាជនមូលដ្ឋាននៅឃុំត្រើយស្លា ស្រុកស្អាងវិញ ។ ជារៀងរាល់ថ្ងៃ កាលខាន់ តែងតែដើរទៅរាវលៀស ខ្ចៅនិងរកត្រីដើម្បីយកមកហូបបន្ថែម ។

## ជីវភាពថ្មី

រយៈពេលមួយខែក្រោយមក អង្គការបានបញ្ជូនគ្រួសារ កាលខាន់ ឲ្យទៅរស់នៅឃុំព្រែកដាច់ ស្រុកលើកដែក តំបន់២៥ ។ នៅទីនោះ មានប្រជាជនជាច្រើននាក់ត្រូវស្លាប់ដោយសារជាន់មីន ព្រោះនោះជាបន្ទាយទាហានចាស់របស់កងទ័ព លន់ នល់ ។ ដូច្នេះ ដោយសារអង្គការមិនទាន់ចាត់វិធានការម៉ឺងម៉ាត់ ទើបមានគ្រួសារជាច្រើនចូលទៅស្នាក់នៅបណ្ដោះអាសន្នក្នុងតំបន់នេះ ដូចជា គ្រួសារជន ជាតិចិន វៀតណាម ចាម អារ៉ាប់ និងគ្រួសារតាហ៊ីង ជាដើម រួចបន្តដំណើរតាមទូកឆ្លងទៅរស់នៅប្រទេសវៀតណាមទៀត ។ រស់នៅបានរយៈពេល៣ខែ តា ស៊ិន ឌី ដែលគ្រប់គ្រងនៅតំបន់នេះបានជិះរថយន្តហ្ស៊ីបដើរចែកអង្ករ អំបិល ថ្នាំពេទ្យ ហើយឃោសនាប្រាប់ប្រជាជនថា «មិត្តមិនចាំបាច់នឹកផ្ទះសម្បែងនៅភ្នំពេញឡើយ យើងមករស់នៅធ្វើការងារជាមួយគ្នា ហើយអង្គការជាអ្នករៀបចំឲ្យ» ។ អង្គការចាប់ផ្ដើមជ្រើសរើសកងឈ្លប មេកង មេក្រុម មេភូមិ មេឃុំ ដើម្បីបែងចែកកម្លាំងប្រជាជនឲ្យចុះទៅធ្វើការតាមមុខសញ្ញារៀងៗខ្លួន ។ ពេលនោះ ដោយសារ កាល់ខាន់ មានមាឌធំនិងកម្លាំងខ្លាំង ឌឹម ដែលជាគណៈឃុំព្រែកតូច បានចាត់តាំងគាត់ឲ្យនៅជាមួយ តាជា ដែលជាប្រធានកងសិប្បកម្ម ដំដែក ធ្វើកាំបិត ពូថៅ ចប កណ្ដៀវនិងផាលនង្គ័ល ។ ចំណែកឪពុកម្ដាយដែលមានវ័យចាស់និងបងប្អូនត្រូវចាត់ឲ្យធ្វើបង្គី ដងរែក ធ្វើស្រែតាមកងចល័ត និងដេញចាបនៅតាមវាលស្រែ ។ គ្រួសារ កាលខាន់ ត្រូវអង្គការដឹងតាមរយៈការនិយាយភាសាខ្មែរមិនច្បាស់និងការមិនហូបសាច់ជ្រូក ប៉ុន្តែអង្គការនៅតែផ្ដល់ម្ហូបអាហារដល់គ្រួសាររបស់គាត់បានហូបដដែល ។

## អ្នកទោសគ្មានកំហុស

នៅខែមីនា ឆ្នាំ១៩៧៦ អង្គការបានមកប្រាប់ថា គ្រួសាររបស់ កាលខាន់ និងគ្រួសារ តាខ្វីង ត្រូវត្រឡប់ទៅស្រុកកំណើតនៅភ្នំពេញវិញ ។ បន្ទាប់ពីហូបបាយថ្ងៃត្រង់រួច ស្រាប់តែ កាលខាន់ ឃើញរថយន្តសេអ៊ីមសេមួយគ្រឿងបើកមកឈប់និងស៊ីប្លនៅមុខរោងសិប្បកម្មឃុំព្រែកតូច ។ ដោយសារចាកចេញពីផ្ទះអស់រយៈពេលយូរមកហើយ កាលខាន់ ត្រេកអរយ៉ាងខ្លាំង ហើយគ្មានគិតអ្វីទាំងអស់ រួចទម្លាក់ញញួរចុះរត់ឡើងជិះរថយន្តនឹងគេភ្លាម ដោយមានតែខោអាវដែលឆេះធ្លុះធ្លាយដោយសារផ្កាភ្លើងស្លៀកពាក់ជាប់នឹងខ្លួនប៉ុណ្ណោះ ។ នៅតាមផ្លូវជាតិលេខ១ កាល់ខាន់ បានមើលឃើញប៉ុស្តិ៍ត្រួតពិនិត្យរបស់កងយោធាខ្មែរក្រហមជាច្រើនកន្លែងដូចជា នៅដីឥដ្ឋ បឹងស្នោ និងនៅច្បារអំពៅ រហូតមកឈប់នៅមុខចំណតរថភ្លើងក្នុងទីក្រុងភ្នំពេញ ។ ខណៈនោះ កងយោធាខ្មែរក្រហមចំនួន៤នាក់បានហៅឈ្មោះ កាលខាន់ ឲ្យចុះពីលើរថយន្ត បន្ទាប់មកភ្ជង់កាំភ្លើង យកក្រណាត់រុំភ្នែក ដាក់ខ្នោះដៃ រួចបញ្ចូលក្នុងរថយន្តពណ៌ខៀវបីបាំង ដោយមិនបាននិយាយប្រាប់ពីមូលហេតុនៃការចាប់ខ្លួនគាត់ទាំងអស់ ។ មកដល់គុកទួលស្លែង យោធាខ្មែរក្រហមម្នាក់បានស្រាយក្រណាត់រុំភ្នែកចេញ រួចស្រែកគំរាមថា «ឯងស្គាល់ទេនេះហើយទួលស្លែង នៅពេលអញសួរអ្នកឯងត្រូវតែឆ្លើយ» បន្ទាប់មកក៏ទាញវាំងននដែលចងភ្ជួរនៅលើជញ្ជាំងថ្ម ដែលក្នុងនោះមានឧបករណ៍សម្រាប់ធ្វើទារុណកម្មជាច្រើនដូចជា គល់ឫស្សី ខ្សែភ្លើងឆក់ ដង្កាប់ និង តង្កៀប ។ កងសន្តិសុខគុកមាឌធំៗប្រហែល១០នាក់បានចូលមកទាត់ធាក់និងទាញសក់ក្បាលរបស់ កាលខាន់ ហើយអ្នកខ្លះចោទគាត់ថា «អាហ្នឹងសក្តិ៣ ឬសក្តិ៤ ឬ សក្តិ៥ ឬអ្នកបើកយន្តហោះ» ។ ប៉ុន្តែក្នុងចំណោមអ្នកទាំងនោះ កាល់ខាន់ បានឮសំឡេងកងសន្តិសុខម្នាក់ស្រែកបញ្ជាយ៉ាងច្បាស់ថា «បញ្ជូនទៅដាក់នៅ០៧ទៅ» (ជាលេខបន្ទប់ឃុំឃាំង) ។ ទៅដល់បន្ទប់ កងសន្តិសុខបានយកឃ្នាងមកដាក់ជើង ប៉ុន្តែដោយសារកជើងរបស់គាត់ធំជាងឃ្នាង កងសន្តិសុខក៏ជាន់ឃ្នាងបញ្ចូលកជើងដើម្បីចាក់សោ រួចដោះខ្នោះដៃចេញវិញ ។

## ជាប់ឃុំក្នុងគុកទួលស្លែង

មួយថ្ងៃក្រោយមក ក្រុមធ្វើប្រវត្តិរូបចំនួន៤នាក់បានកាន់បញ្ជីឈ្មោះចូលមកក្នុងបន្ទប់របស់ កាល់ខាន់ រួចសួរសំណួរជាច្រើនដូចជា «ជនាន់ សីហនុ មិត្តឯងធ្វើអ្វី?» ។ ក្រោយពី កាលខាន់ ឆ្លើយថា «នៅរៀន និងជួយឪពុកម្ដាយមើលថែទាំគោ

ពពែ និងលក់ទឹកដោះគោ» ក្រុមធ្វើប្រវត្តិរូបក៏គំរាមថា «មិត្តឯង ត្រូវឆ្លើយឲ្យត្រង់» ។ ទោះបីជាមានការគំរាមបែបនេះក៏ដោយ ក៏ កាលខាន់ នៅតែបញ្ជាក់ថា «ខ្ញុំនិយាយត្រង់ ខ្ញុំឆ្លើយការពិត» អស់ហើយ ។ ប៉ុន្តែក្រុមធ្វើប្រវត្តិរូបមិនចង់បានចម្លើយនេះទេ ក៏ សួរបន្តថា «ចុះមកដល់សង្គម លន់ នល់ មិត្តឯងមានធ្វើអាហារឬ ទេ?» ។ កាលខាន់ នៅតែឆ្លើយថា «ខ្ញុំអត់មានធ្វើអាហារទេ ខ្ញុំនៅ ចិញ្ចឹមគោជាមួយឪពុកម្តាយដែលមានវ័យចាស់ជរា និងមើលការ ខុសត្រូវផ្ទះសម្បែង» ។ ហើយចុងក្រោយ ក្រុមអ្នកធ្វើប្រវត្តិរូប សួរបន្ថែមទៀតថា «ចុះមកដល់របបកុម្មុយនីស្តនេះ មិត្តឯង ធ្វើអ្វី?» ។ កាល់ខាន់ ក៏ឆ្លើយការពិតថា «ធ្វើជាងដែក នៅវាយ ដែករាល់ថ្ងៃ» ។ ក្រោយពីបញ្ចប់សំណួរ ក្រុមធ្វើប្រវត្តិរូបក៏បានឲ្យ កាល់ខាន់ សរសេរប្រវត្តិរូបដោយខ្លួនឯង ព្រោះក្រុមនេះមិនសូវ ចេះអក្សរទេ ។ នៅក្នុងគុក កាលខាន់ ត្រូវបានក្រុមធ្វើប្រវត្តិរូប ផ្លាស់ប្តូរគ្នាពី៣ទៅ៤ដងក្នុងមួយថ្ងៃ ដើម្បីសួរនូវសំណួរដដែលៗ ។ រយៈពេល២០ថ្ងៃក្រោយមក ក្រុមថតរូបជនជាតិចិនចំនួន២នាក់ រួមជាមួយកងសន្តិសុខគុក៤នាក់ទៀតបានចូលមកក្នុងបន្ទប់ ឃុំឃាំងរបស់ កាល់ខាន់ ហើយប្រាប់ថា «កុំមើលអ្វីក្រៅពីខ្លួនឯង ឲ្យសោះ» រួចក៏ដាក់ខ្នោះដៃបណ្តើរចេញមកខាងក្រៅ ។ ប៉ុន្តែ ដោយជើងជាប់ឃ្នាងមិនបានធ្វើចលនាយូរមកហើយ បណ្តាលឲ្យ គាត់ដើរដួលបោកខ្លួនទៅនឹងជញ្ជាំង ។ ពេលនោះជនជាតិចិនម្នាក់ បានយកថ្នាំមកលាបជើងឲ្យគាត់ បន្ទាប់មកកងសន្តិសុខបានបញ្ជា ឲ្យគាត់ឈរផ្អែកនឹងកៀនជញ្ជាំងដើម្បីសិតសក់និងឲ្យញញឹម ដើម្បីថតរូបចំនួន៣ប៉ុស្តិ៍ ។ មួយអាទិត្យក្រោយមក កម្មាភិបាល ខ្មែរក្រហមដែលមានវ័យចំណាស់ម្នាក់កាន់បញ្ជីឈ្មោះ រួមជាមួយ កងការពារ៤នាក់ចូលមកសួរថា «មិត្តពីមុនរស់នៅកន្លែងណា?» ។ កាល់ខាន់ ឆ្លើយទាំងមានអារម្មណ៍ភ័យខ្លាចថា «ខ្ញុំនៅភូមិអារ៉ាប់» ។ កម្មាភិបាលនោះសួរបន្តថា «មិត្តសរសេរនៅក្នុងប្រវត្តិដូចម្តេច ខ្លះ?» ។ ចម្លើយស្មោះត្រង់របស់គាត់គឺមានត្រឹមតែ «ចិញ្ចឹមគោ ពពែ និង លក់ទឹកដោះគោដើម្បីដោះស្រាយជីវភាព» ប៉ុណ្ណោះ ។ រយៈពេល៣ថ្ងៃបន្ទាប់ពីសួរអំពីប្រវត្តិរូប នៅវេលាម៉ោង១២យប់ កងសន្តិសុខក៏ទៅគុក ហើយចូលទៅក្នុងបន្ទប់របស់ កាល់ខាន់ ដោះ ឃ្នាងចេញ រួចបញ្ជាឲ្យដើរត្រង់ទៅមុខ ។ កាលខាន់ បានទៅជួប ឪពុកម្តាយបងប្អូន ព្រមទាំងគ្រួសាររបស់ គាត់ខ្លួន នៅអគារថ្មក្នុង បរិវេណគុកទួលស្លែងដែលត្រូវកងសន្តិសុខឃុំឃាំងដែរ ។ ដោយ រកមិនឃើញថាគ្រួសាររបស់ កាលខាន់ ជាសមាសភាពក្បត់ ព្រឹក ឡើងអង្គការបានចែកអង្ករនិងឆ្នាំងទៅឲ្យក្រុមគ្រួសារទាំងពីរ បន្ទាប់មក កម្មាភិបាលម្នាក់បានហៅគាត់ឲ្យចូលរួមប្រជុំដោយបាន លើកឡើងថា នៅពេលស្រុកយើងជឿនលឿន យើងនឹងឈប់ប្រើ កម្លាំងមនុស្សនិងគោក្របី ហើយយើងនឹងប្រើត្រាក់ទ័រជំនួសវិញ» ព្រមទាំងណែនាំឲ្យខិតខំធ្វើស្រែចម្ការថែមទៀត ។

## វិលត្រឡប់ទៅសហករណ៍

ក្រោយពីកិច្ចប្រជុំបញ្ចប់នៅម៉ោង១២ថ្ងៃត្រង់ កាលខាន់ ត្រូវអង្គការបញ្ជូនតាមរថយន្តកាត់ខេត្តកំពង់ស្ពឺ តាខ្មៅ និងច្បារ អំពៅ រហូតបានមកដល់សហករណ៍ព្រែកដាច់វិញ ។ នៅតាមផ្លូវ គ្រួសាររបស់គាត់ទទួលបានស្ករត្នោតមួយពាងពីអ្នកភូមិដែលមាន ចិត្តសប្បុរសសម្រាប់ទុកហូបពេលខ្វះខាត ។ ប៉ុន្តែព្រោះតែខ្លាច អង្គការចាប់ដាក់គុកម្តងទៀត ឪពុករបស់ កាល់ខាន់ បានយក ស្ករនេះទៅដាក់នៅសហរណ៍រួមនិងហាមឃាត់កូនៗមិនឲ្យនិយាយ អ្វីពីរឿងដែលអង្គការចាប់យកទៅឃុំឃាំងនៅទួលស្លែងទេ ។ នៅពេលជួបប្រជុំការងារ ប្រធានភូមិ-ឃុំ ព្រមទាំងប្រជាជន បានសួរ កាល់ខាន់ ថា «អង្គការបញ្ជូនទៅស្រុកកំណើតហើយ ហេតុដូចម្តេចបានជាត្រឡប់មកទីនេះវិញ?» ។ កាល់ខាន់ បាន ឆ្លើយទាំងអារម្មណ៍ភិតភ័យថា «នេះជាទិសរបស់អង្គការដាក់ឲ្យ ធ្វើ» ។ ចំណែកឪពុករបស់ កាល់ខាន់ វិញ នៅពេលរំឭករឿងនេះ ម្តងៗ គាត់មិនបាននិយាយស្តីអ្វីទាំងអស់ គឺបានត្រឹមតែសម្រក់ ទឹកភ្នែកនៅចំពោះមុខកូនៗប៉ុណ្ណោះ ។

ក្រោយមក កាលខាន់ ត្រូវបានអង្គការចាត់តាំងឲ្យធ្វើស្រែ លើកភ្លឺ លើកទំនប់នៅក្នុងបឹង ដែលមានចម្ងាយ៣គីឡូម៉ែត្រ ពីភូមិ ។ នៅពាក់កណ្តាលឆ្នាំ១៩៧៧ ប្អូនប្រុសពៅបានរត់មក ប្រាប់ កាល់ខាន់ ទាំងទឹកមុខហេវហត់ថា «ឪពុកស្លាប់ហើយ» ពួ ដូច្នេះ គាត់បានទៅសុំច្បាប់ប្រធានកងដើម្បីយកសពទៅធ្វើបុណ្យ តាមប្រពៃណីសាសនា ។ ប៉ុន្តែអង្គការមិនអនុញ្ញាតឲ្យ កាល់ខាន់ ធ្វើដូច្នេះទេ ។ ហេតុនេះ គាត់ក៏បានទៅសុំប្រជីសបុស្សីសម្រាប់ ហាលថ្នាំជក់ពីប្រធានកងដើម្បីដាក់សពឪពុកសែងយកទៅកប់

ប៉ុន្តែត្រូវអង្គការបដិសេធដដែល ។ បន្ទាប់ពី កាល់ខាន់ យកឪពុកទៅបញ្ចុះនៅទួលក្បែរភូមិរួច ប្រធានកងបានដាក់ទណ្ឌកម្មគាត់ឲ្យនៅបោកស្រូវក្នុងភូមិរយៈពេលមួយសប្តាហ៍ដោយមិនបានផ្តល់អាហារឲ្យហូបទេ គឺបានត្រឹមតែទឹកដឹកប៉ុណ្ណោះ ។

ក្រោយរំដោះថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កាល់ខាន់ បានប្រកបមុខរបរធ្វើស្រែ ធ្វើកម្មករ នេសាទ និងរត់ម៉ូតូឌុប ។ សព្វថ្ងៃ កាល់ខាន់ មានប្រពន្ធឈ្មោះ អូន សារ៉េត និងមានកូនប្រុស៤នាក់ ។ អស់រយៈពេលជាង៣០ឆ្នាំមកហើយដែលគាត់មិនមានឱកាសនិយាយពីរឿងឈឺចាប់នេះប្រាប់ទៅដល់ប្រជាជនកម្ពុជាទេ ។ ក្រោយពេលមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទើបគាត់ហ៊ាននិយាយពីការពិតនេះ ដើម្បីឲ្យតុលាការរកយុត្តិធម៌ជូនគាត់ក៏ដូចជាប្រជាជនស្លូតត្រង់ផ្សេងទៀតដែលត្រូវបានកងយោធាខ្មែរក្រហមចាប់ឃុំឃាំងនិងសម្លាប់ដោយគ្មានទោសពៃរ៍ ។ **សោម ប៊ុនថន និង គាត លក្ខិណា**

*(តមកពីទំព័រ១)*

### *សហព្រះរាជអាជ្ញាប្តឹងឧទ្ធរណ៍ទាក់ទងនឹងការចោទប្រកាន់ ឌុច*

នៅថ្ងៃទី២១ ខែសីហា សហព្រះរាជអាជ្ញាបានប្រកាសពីបណ្តឹងឧទ្ធរណ៍របស់ខ្លួនទាក់ទងនឹងដីកាដំណោះស្រាយរបស់ ឌុច ដោយអះអាងថា «វាបានកំណត់ពីបទឧក្រិដ្ឋរបស់ ឌុច និងទម្រង់នៃបទឧក្រិដ្ឋរបស់គាត់» ហើយ «អាចធ្វើឲ្យអង្គបុរេជំនុំជម្រះមិនអាចកាត់ទោសគ្រប់បទល្មើសដែល ឌុច ត្រូវទទួលខុសត្រូវនៅ ស-២១» ។ ដោយឡែកព្រះរាជអាជ្ញាបានរកឃើញថា សំណុំរឿងនោះមានកំហុសច្រើនពីព្រោះមិនបានចោទប្រកាន់ ឌុច តាមច្បាប់ព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ និងទំនួលខុសត្រូវរបស់គាត់ក្នុងនាមជាសហជនដែលនៃសហកម្មឧក្រិដ្ឋកម្មរួម ។

### *សហចៅក្រមស៊ើបអង្កេតបានចេញដីកាចោទប្រកាន់ ឌុច*

នៅថ្ងៃទី៨ ខែសីហា សហចៅក្រមស៊ើបអង្កេតបានចេញដីកាបញ្ជូនសំណុំរឿង ឌុច ទៅជំនុំជម្រះ ព្រមទាំងបញ្ជូនគាត់ទៅកាត់ទោសពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវ ។

### *សហព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានស្ថាពរលើករណីសំណុំរឿងរបស់ ឌុច*

នៅថ្ងៃទី១៨ ខែកក្កដា សហព្រះរាជអាជ្ញាបានបញ្ជូនដីកាសន្និដ្ឋានស្ថាពរលើករណី ឌុច ទៅតុលាការដោយតំណាងថា «ជាការសន្និដ្ឋានយ៉ាងច្បាស់លាស់របស់សហព្រះរាជអាជ្ញាដែលបានលើកឡើង ចាត់ទុកថាជាភ័ស្តុតាងដែលជាប់ពាក់ព័ន្ធនៅក្នុងសំណុំរឿង» ក៏ដូចជាការអះអាងតាមផ្លូវច្បាប់ដើម្បីគាំទ្រការចោទប្រកាន់ដ៏មានសារសំខាន់ដែលសហព្រះរាជអាជ្ញាចង់ឲ្យសហចៅក្រមស៊ើបអង្កេតធ្វើការចោទប្រកាន់ទៅលើ ឌុច ។

### *សេចក្តីសម្រេចទាក់ទងនឹងការឃុំខ្លួន អៀង ធីរិទ្ធ នៅអង្គបុរេជំនុំជម្រះត្រូវបានប្រកាស*

នៅថ្ងៃទី៩ ខែកក្កដា អង្គបុរេជំនុំជម្រះបានស្វែងយល់ថា វាមានសារសំខាន់ណាស់ក្នុងការបន្តការឃុំខ្លួន អៀង ធីរិទ្ធ ដើម្បីធានាសន្តិសុខជនរងគ្រោះ និងសាក្សី រក្សាភ័ស្តុតាង ធានាឲ្យមានវត្តមានរបស់លោកស្រីនៅពេលមានដំណើរការនីតិវិធី ព្រមទាំងរក្សាសណ្តាប់ធ្នាប់សាធារណៈ ។

### *ឯកសារដែលផ្តល់ឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា*

ក្នុងរយៈពេលបីខែនេះ ក្រុមឆ្លើយតបនឹងតុលាការបានផ្តល់ឯកសារជាច្រើនទៅឲ្យសហចៅក្រមស៊ើបអង្កេត មេធាវីការពារក្តី ការិយាល័យសហចៅក្រមស៊ើបអង្កេត និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។ ជាឧទាហរណ៍ អ្នកស្រី គាត បូផា ប្រធានអង្គភាពជនរងគ្រោះបានស្នើសុំជំនួយពី លោក វ៉ាន់ថាន់ ពៅដារ៉ា ប្រធានក្រុមឆ្លើយតបនឹងតុលាការ ដើម្បីស្វែងរកឯកសារទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណីចំនួន១៨រូបដែលមានការជួយពីអង្គការផ្សេងទៀត ។ ការស្នើសុំឯកសាររបស់ព្រះរាជអាជ្ញានៅមុនពេលវិស្សមកាលបុណ្យភ្ជុំបិណ្ឌខែកញ្ញានឹងត្រូវបានរៀបចំរួចនៅដើមខែតុលា ។

### *ការផ្តល់ជំនួយទៅកាន់សាធារណជន និង ប្រព័ន្ធផ្សព្វផ្សាយ*

ក្នុងរយៈពេលបីខែនេះ ក្រុមគម្រោងបានផ្តល់ឯកសារចំនួន៤៧០ទំព័រទៅឲ្យលោក ប៉ាន់ រិទ្ធី ដែលជាប្រធានមជ្ឈមណ្ឌលបុប្ផាណា ដើម្បីប្រើប្រាស់នៅក្នុងភាពយន្តឯកសារទាក់ទងនឹងវប្បធម៌របស់ខ្មែរក្រហមនិង១៣៨៧ទំព័រទៅឲ្យអ្នកស្រាវជ្រាវជនជាតិអាល្លឺម៉ង់ ។

***សេចក្តីរាយការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា***

# កាលប្បវត្តិសំខាន់ៗរបស់តុលាការខ្មែរក្រហម

***(តពីលេខមុន)***

◆ *នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៦ គណៈប្រតិភូសហគមន៍អឺរ៉ុបដឹកនាំដោយ* Mark Tarabela *និយាយនៅអំឡុងទស្សនកិច្ចនៅកម្ពុជាថា សហគមន៍អឺរ៉ុបនឹងគាំទ្រសាលាក្តីខ្មែរក្រហមនៅពេលភាគីកម្ពុជានិងអន្តរជាតិប្រគល់សំណើថ្មី ។*

◆ *នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៦ អតីតព្រះមហាក្សត្រ សម្តេចព្រះនរោត្តម សីហនុ បានចំអកថា អ្វីដែលព្រះអង្គមានព្រះបន្ទូលគឺជាការរំឭកឡើងវិញនូវអ្វីដែលបានផ្សព្វផ្សាយថាអតីតមេដឹកនាំខ្មែរក្រហមលោក ប៉ុល ពត ជាវីរបុរសរបស់ជាតិ ។ ព្រះអង្គមានព្រះបន្ទូលឆ្លើយតបទៅនឹងសារព័ត៌មានស្តីពីពិធីបុណ្យតាមបែបព្រះពុទ្ធសាសនាដែលប្រារព្ធធ្វើនៅខួបលើកទី៨នៃមរណភាពរបស់ ប៉ុល ពត ថ្ងៃទី១៥ខែមេសា ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ អ្នកក្រោមបង្គាប់របស់លោក ប៉ុល ពត បានយកចំណីអាហារនិងទៀនធូបទៅកាន់កន្លែងកប់សាកសពរបស់គាត់នៅថ្ងៃទី ១៥ ខែមេសា ។ ប្រជាជនដែលមានជំនឿប្រាប់ថា ប៉ុល ពត អាចផ្តល់សំណាងដល់ពួកគាត់ ។ ដូចច្នេះការបួងសួងនៅមុខផ្នូរ (ទេវតាថ្មី ប៉ុល ពត) ដែលជាទីគោរពសក្ការៈដោយមានការអុជទៀនធូបគឺអាចធ្វើឲ្យព្រលឹងរបស់គាត់បានដល់សុគតិភព និងឆាប់ចាប់ជាតិថ្មី ។*

◆ *នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៦ «ល្បែងខ្មោច» ជាខ្សែភាពយន្តមួយដែលមានអ្នកចូលរួមប្រកួតប្រជែងចំនួន១១នាក់ឈ្នះរង្វាន់៥លានបាត ហើយចាក់ផ្សាយនៅថ្ងៃទី២៧ ខែមេសា ។ ខ្សែភាពយន្តដែលថតនៅប្រទេសថៃមានសភាពស្រដៀងនឹងរូបភាពខាងក្នុងនៃសារមន្ទីរទួលស្លែងដែរ ជាពិសេសរូបថតជនរងគ្រោះមួយកំណាត់ខ្លួនដែលតម្រៀបជាជួរ ភាពយន្តនេះធ្វើឲ្យប្រជាជនកម្ពុជាមានប្រតិកម្មយ៉ាងខ្លាំង ។ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាបានហៅភាពយន្តនេះថា «ការចងចាំដ៏ឈឺចាប់» ហើយបានឲ្យដឹងថា ទោះបីជាភាពយន្តគួរឲ្យរន្ធត់ថ្មីរបស់ថៃដែលមានចំណងជើងថា «ល្បែងខ្មោច» ខុសពីឈ្មោះមន្ទីរសន្តិសុខស-២១យ៉ាងណាក្តី ប៉ុន្តែភាពយន្តនេះហាក់ដូចជាក្រឡេចេញពីសារមន្ទីរអំពើប្រល័យពូជសាសន៍ទួលស្លែង ។ លោក កែន ដារ៉ា ប្រធាននាយកដ្ឋានខ្សែភាពយន្តនៃក្រសួងវប្បធម៌បាននិយាយថា ការស្នើសុំដើម្បីថតភាពយន្តនៅប្រទេសកម្ពុជាត្រូវបានបដិសេធ ហើយភាពយន្តថតចម្លងនៅតាមទីផ្សារគួរតែរឹបអូសឲ្យអស់ ។ ទោះបីជាលោក ខុន សាម៉ែន ប្រធាននាយកដ្ឋានសារមន្ទីរនៃក្រសួងវប្បធម៌ទទួលបន្ទុកសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង មិនទាន់បានមើលភាពយន្តថៃនៅឡើយ ប៉ុន្តែលោកបានចោទប្រកាន់អ្នកផលិតភាពយន្តថៃថាកំពុងតែបំផ្លាញកេរ្តិ៍ឈ្មោះប្រទេសកម្ពុជា ។*

◆ *នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៦ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អង់ វង្សវឌ្ឍនា និយាយថា «ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងជ្រើសរើសចៅក្រមនិងព្រះរាជអាជ្ញាអន្តរជាតិសម្រាប់សាលាក្តីខ្មែរក្រហមនៅថ្ងៃទី៤ ខែឧសភា» ។*

*អ្នកតំណាងអ្នកថតភាពយន្ត «ល្បែងខ្មោច» របស់ថៃបានបើកសន្និសីទកាសែតដើម្បីសុំទោសអំពីព្រឹត្តិការណ៍នៅក្នុងសាច់រឿងដែលស្រដៀងនឹងគុកទួលស្លែងនៅកម្ពុជា ។ នៅក្នុងសន្និសីទកាសែតតំណាងផលិតករគឺ អ្នកស្រី ណាប៉ាត ប៉ាវ៉ាពូតាណង់ ណាម៉ាហាសាវ៉ាកាម ធ្វើការសុំទោសចំពោះការខ្វះខាតការយល់ដឹងរបស់ផលិតកម្មដោយនិយាយថា «យើងគួរតែបែងចែកឲ្យច្បាស់រវាងរឿងប្រឌិតនិងរឿងពិត» ។ លោកស្រីបញ្ចប់ការអធិប្បាយដោយសម្តែងកាយវិការគោរពនិងសុំទោស ។*

◆ *នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៦ កាសែតថៃ* The Nation *ចេញផ្សាយជាភាសាអង់គ្លេសបានសរសេរអត្ថបទទាក់ទងនឹងភាពយន្ត «ល្បែងខ្មោច» ថា ប្រជាជនថៃភាគច្រើនបានបំភ្លេចព្រមទាំងមិនអើពើនូវអ្វីដែលបានកើតឡើងនៅប្រទេសជិតខាងនៅសម័យកាលដ៏គួរឲ្យភ័យរន្ធត់ដែលបង្កឲ្យមានឧក្រិដ្ឋកម្មប្រឆាំង*

មនុស្សជាតិដ៏អាក្រក់បំផុតនេះ ។ រួចបានសរុបសេចក្តីថា សង្គមថៃគួរតែអប់រំប្រជាជនក្មេងៗឲ្យបានដឹងពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនិងការយល់ដឹងពីវប្បធម៌ប្រទេសដទៃ ។

◆ នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០០៦ ចៅក្រម ព្រះរាជអាជ្ញាជាតិនិងអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជានៅថ្ងៃទី៤ ខែឧសភា ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ នស.រកត ០៥០៦/២១៨ នៃព្រះមហាក្សត្រនរោត្តម សីហមុនី ។ បញ្ជីឈ្មោះផ្លូវការ ៖

១) ចៅក្រមសាលាដំបូង

◆ លោក និល ណុន (កម្ពុជា)

◆ លោក ធូ មណី (កម្ពុជា)

◆ លោក យ៉ា សុខន (កម្ពុជា)

◆ អ្នកស្រី *Silvia Cartwright* (នូវែលសេឡង់)

◆ លោក *Jean-Marc Lavergne* (បារាំង)

ចៅក្រមបម្រុង

◆ លោក យូរ ឧត្តរា (កម្ពុជា)

◆ អ្នកស្រី *Claudia Fenz* (អូទ្រីស)

២) ចៅក្រមតុលាការកំពូល

◆ ឯកឧត្តម គង់ ស្រឹម (កម្ពុជា)

◆ លោក សោម សេរីវុឌ្ឍ (កម្ពុជា)

◆ លោក ស៊ិន រិទ្ធ (កម្ពុជា)

◆ លោក យ៉ា ណារិន (កម្ពុជា)

◆ លោក *Motoo Noguchi* (ជប៉ុន)

◆ អ្នកស្រី *Agnieszka Klonowiecka-Milart* (ប៉ូឡូញ)

◆ លោក *Chandra Nihal Javasinghe* (ស្រីលង្កា)

ចៅក្រមបម្រុង

◆ លោក ម៉ុង មុន្នីចរិយា (កម្ពុជា)

◆ លោក *Martin Karopkin* (សហរដ្ឋអាមេរិក)

៣) សហចៅក្រមស៊ើបអង្កេត

◆ លោក យូ ប៊ុនឡេង (កម្ពុជា)

◆ លោក *Marcel Lemonde* (បារាំង)

ចៅក្រមបម្រុង

◆ លោក ថោង អុល (កម្ពុជា)

៤) សហព្រះរាជអាជ្ញា

◆ អ្នកស្រី ជា លាង (កម្ពុជា)

◆ លោក *Robert Pertit* (កាណាដា)

សហព្រះរាជអាជ្ញាបម្រុង

◆ ឯកឧត្តម ជួន ស៊ុនឡេង (កម្ពុជា)

◆ លោក Paul Coffey (សហរដ្ឋអាមេរិក)

៥) អង្គបុរេជំនុំជម្រះ

◆ ឯកឧត្តម ប្រាក់ គឹមសាន (កម្ពុជា)

◆ ឯកឧត្តម ន័យ ថុល (កម្ពុជា)

◆ លោក ហួត វុទ្ធី (កម្ពុជា)

◆ លោក Rowan Downing (អូស្ត្រាលី)

◆ អ្នកស្រី Katinka Lahuis (ហូឡង់)

ចៅក្រមបម្រុង

◆ លោក ប៉ែន ពេជ្រសាលី (កម្ពុជា)

◆ នៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០០៦ អ្នកផលិតភាពយន្ត «ល្បែងខ្មោច» ដែលចាក់ផ្សាយនៅខែមុនចាប់ផ្តើមថតទិដ្ឋភាពថ្មី ហើយធ្វើការសុំទោសដល់ស្ថានទូតកម្ពុជាប្រចាំនៅប្រទេសថៃ ។

នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៦ អ្នកស្រី មីសែល លីនិងភាគីខាងកម្ពុជាលោក ស៊ាន វិសុទ្ធ មន្ត្រីការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប្រាប់សន្និសីទកាសែតថាមានការពន្យារពេលការកាត់ទោសរហូតដល់ខែមិថុនា ដោយសារខ្វះបុគ្គលិកកម្ពុជាដែលមានគុណសម្បត្តិគ្រប់គ្រាន់ និងបានបន្ថែមថា ពួកគេសង្ឃឹមថាស្ថានភាពនេះនឹងត្រូវកែតម្រូវនៅត្រឹមខែកក្កដា ទោះបីជាវាអាចនឹងពន្យារទៅពេលក្រោយទៀតក៏ដោយ ។

◆ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៦ និយាយនៅឯពិធីប្រគល់សញ្ញាប័ត្រនៅសាលាភូមិន្ទរដ្ឋបាល សម្តេចនាយរដ្ឋមន្ត្រី ហ៊ុន សែន រិះគន់ទៅអ្នកដែលបានចោទសួរពីលក្ខណៈសម្បត្តិនៃចៅក្រមនិងសហព្រះរាជអាជ្ញាដែលត្រូវបានតែងតាំងសម្រាប់សាលាក្តីខ្មែរក្រហម ។

◆ នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៦ បដិមាករលោកតាដំបងដែកត្រូវបានសម្ពោធនៅខេត្តកណ្តាលកាលពីព្រឹកថ្ងៃសុក្រ ។ យោងតាមបទបញ្ញត្តិច្បាប់កម្ពុជា សាក្សីត្រូវស្បថឲ្យប្រាប់ការពិតចំពោះមុខបដិមាករនេះមុនពេលផ្តល់ចម្លើយកសិណសាក្សី ។

◆ នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៦ ឧត្តមស្នងការជាន់ខ្ពស់ទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ លោកស្រី លូស៊ីស អាបឺរ (Louis Arbour) បានរៀបចំការជជែកពិភាក្សារយៈពេល២ម៉ោង ស្តីពីកំណែទម្រង់ប្រព័ន្ធតុលាការនិងធ្វើទស្សនកិច្ចទៅកាន់សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងជាមួយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ។

◆ នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៦ ចៅក្រមនិងសហព្រះរាជអាជ្ញាកម្ពុជាថ្មីចំនួន១៧រូប ត្រូវបានជ្រើសសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងត្រូវបានណែនាំជាផ្លូវការដល់មន្ត្រីការិយាល័យរដ្ឋបាលរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ ចៅក្រមនិងសហព្រះរាជអាជ្ញា៩រូបត្រូវអញ្ជើញឲ្យចូលរួមវេទិកា «សន្និសីទស្តីពីការយល់ដឹងពីតុលាការនៅទីជនបទខាងកើត» ដែលធ្វើឡើងនៅទីក្រុងបាងកកនៅថ្ងៃទី២៨-២៩ ខែឧសភា រៀបចំដោយមជ្ឈមណ្ឌលអ៊ីសវែសនិងមជ្ឈមណ្ឌលសិក្សាឧក្រិដ្ឋសង្គ្រាមបឺខេលី ។ កិច្ចប្រជុំនៃអង្គសន្និសីទបានបង្ហាញពីបទពិសោធន៍ចំនួន៥ឆ្នាំពីតុលាការឧក្រិដ្ឋកម្មធ្ងន់របស់អង្គការសហប្រជាជាតិនៅទីជនបទខាងកើតដែលរួមមាន ក្រុមការងារពិសេសសម្រាប់បទឧក្រិដ្ឋកម្មធ្ងន់ ទស្សនវិស័យរបស់ប្រជាជនទីជនបទនិងអន្តរជាតិទៅលើដំណើរការកាត់ក្តីពីបទឧក្រិដ្ឋកម្មធ្ងន់ តុលាការឧក្រិដ្ឋកម្មធ្ងន់រួមមាន ការស៊ើបអង្កេត ការចោទប្រកាន់ ការការពារក្តីនិងអ្វីដែលបន្សល់ទុកពីតុលាការបន្ទាប់ពីការកាត់ទោសនិងការចុះទៅជួបផ្ទាល់ជាមួយប្រជាជននៅតាមមូលដ្ឋាន ប្រព័ន្ធផ្សព្វផ្សាយ និងតួនាទីរបស់អង្គការជាតិនិងអន្តរជាតិ ព្រមទាំងការយល់ឃើញរបស់ប្រជាជនតាមតំបន់ ។ ប្រធានការិយាល័យរដ្ឋបាលរបស់អង្គជំនុំជម្រះវិសាមញ្ញ លោក ស៊ាន វិសុទ្ធ និងអនុប្រធាន អ្នកស្រី មីសែល លី នឹងធ្វើចំណាប់អារម្មណ៍រួមគ្នានិងទស្សនវិស័យនៅថ្ងៃអនាគត ។

◆ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៦ រាជរដ្ឋាភិបាលកម្ពុជា



សិស្សានុសិស្ស កំពុងតម្រង់ជួរចូលទស្សនាអគារតុលាការខ្មែរក្រហម

និងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់ប្រាក់ប្រមាណ៦,៣លានដុល្លារអាមេរិកដល់អង្គជំនុំជម្រះវិសាមញ្ញ ។ ទឹកប្រាក់ចំនួន៥លានដុល្លារអាមេរិកបានមកពីប្រទេសន័រវែស ស៊ុយអែត ដាណឺម៉ាក អូស្ត្រាលី ជប៉ុន នូវែលសេឡង់ អៀរឡង់ កាណាដា ចក្រភពអង់គ្លេស ហូឡង់ បារាំង និងអាល្លឺមង់ ដែលត្រូវបានផ្តល់សម្រាប់ប្រតិបត្តិការអ៊ិនតាក់នៅកម្ពុជា និងទឹកប្រាក់១លានអឺរ៉ូទៀតបានមកពីរដ្ឋជាសមាជិករបស់បេសកកម្មសហគមន៍អឺរ៉ុប ។ កម្ពុជាបរិច្ចាគប្រាក់១៣,៣លានដុល្លារអាមេរិក ។ ប្រាក់បរិច្ចាគចុងក្រោយនេះបានកាត់បន្ថយកង្វះថវិការបស់ភាគីកម្ពុជាមកត្រឹម៤,៩៦លានដុល្លារអាមេរិក ។

◆ នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៦ លោក ជួន ជឿន រដ្ឋមន្ត្រីក្រសួងសុខាភិបាលនៅសម័យខ្មែរក្រហមដែលបានទទួលសញ្ញាប័ត្រពេទ្យពីប្រទេសបារាំង ស្លាប់ដោយជំងឺចាស់ជរាក្នុងអាយុ៨៦ឆ្នាំ នៅទីក្រុងភ្នំពេញ ។ ប្អូនប្រុសរបស់គាត់ ជួន ប្រាសិទ្ធិ ជាអគ្គរដ្ឋទូតកម្ពុជាប្រចាំអង្គការសហប្រជាជាតិពីឆ្នាំ១៩៧៨-១៩៩២ ពេលដែលខ្មែរក្រហមតំណាងឲ្យប្រទេសនេះនៅវេទិកាពិភពលោក ។ ប្អូនប្រុសម្នាក់ទៀត ជួន ម៉ុម ក៏បានបម្រើក្នុងតំណែងជាន់ខ្ពស់ជាមួយខ្មែរក្រហមដែរ ។ ប្អូនប្រុសទាំងពីរនាក់ដែលក្មេងជាង ជួន ជឿន ត្រូវបានជឿជាក់ថាបាននៅរស់ (ជួន ប្រាសិទ្ធិ ហើយរបាយការណ៍ចុងក្រោយបានឲ្យដឹងថា កំពុងរស់នៅទីក្រុងញូវយ៉កបន្ទាប់ពីការងាររការទូតរបស់គាត់ត្រូវបញ្ចប់ ។ គាត់ត្រូវបានអនុញ្ញាតឲ្យរស់នៅទីនោះដោយសារប្រពន្ធរបស់គាត់ធ្វើការនៅអង្គការសហប្រជាជាតិ) ។

◆ នៅថ្ងៃទី២៦-២៧ ខែមិថុនា ឆ្នាំ២០០៦ មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញប្រធានឃុំចំនួន៥៣០រូបមកពីខេត្តចំនួន១២ ធ្វើទស្សនកិច្ចនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ដើកឯកនិងទីតាំងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

◆ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ តាម៉ុក អាយុ៨២ឆ្នាំ គាត់ជាអ្នកជាប់ឃុំឃាំងម្នាក់ក្នុងចំណោមពីរនាក់ដែលរង់ចាំការកាត់ទោសនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានជំងឺធ្ងន់នៅក្នុងគុក ។ មេធាវីរបស់គាត់ ប៉ែនសុន សាម័យ និយាយថាខ្ញុំកំពុងស្នើសុំទៅតុលាការយោធាឲ្យដោះលែងគាត់នៅក្រៅឃុំ ។

◆ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៦ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រកាសជាផ្លូវការថា ចៅក្រមជាតិ និងអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងធ្វើសច្ចាប្រណិធានចុងក្រោយនៅមុខព្រះបដិមាព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម (ព្រះសុវណ្ណកោដ្ឋ) នៅវេលាម៉ោង៤ល្ងាចថ្ងៃច័ន្ទ ទី៣ ខែកក្កដា ដែលមានមន្ត្រីនៅព្រះបរមរាជវាំង និងមន្ត្រីតំណាងឲ្យអគ្គលេខាធិការអង្គការសហប្រជាជាតិធ្វើជាអធិបតី ។

តាម៉ុក មានអាយុ៨២ឆ្នាំ មានជំងឺលើសឈាម ឈឺក្រពះនិងក្អក ។ កាលពីសប្តាហ៍មុន មេធាវីរបស់គាត់ ប៉ែនសុន សាម័យ និយាយថាខ្ញុំព្រួយបារម្ភថាគាត់ប្រហែលជាមិនអាចឈរនៅក្នុងតុលាការបានទេ ។ ឧត្តមសេនីយត្រី ព្រំ សនថុន ព្រះរាជអាជ្ញានៅតុលាការយោធាដែលមើលការខុសត្រូវលើ តាម៉ុក និង កាំង ហ្កេកអ៊ាវ បដិសេធមិនផ្តល់សេចក្តីអត្ថាធិប្បាយលម្អិតពីសភាពជំងឺរបស់គាត់ទេ ។ លោកបាននិយាយថា តាម៉ុក បានទទួលការព្យាបាលនៅក្នុងមន្ទីរឃុំឃាំងយោធាតាំងពីគាត់ឈឺមួយខែមុន ។ លោកបន្ថែមថា «ដោយសារជំងឺរបស់គាត់មិនមានភាពធូរស្រាល ទើបយើងសម្រេចចិត្តបញ្ជូនគាត់ទៅមន្ទីរពេទ្យ» ។

◆ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៦ លោកមេធាវី ប៉ែនសុន សាម័យ បាននិយាយថា តាម៉ុក ដែលមានជំងឺច្រើនប្រភេទប្រហែលជាធ្វើឲ្យគាត់មិនអាចរង់ចាំការកាត់ក្តីបានទេ ។ តាម៉ុក និយាយថា «កាត់ទោសខ្ញុំឥឡូវនេះទៅ មុនពេលដែលខ្ញុំស្លាប់ ធ្វើបែបនេះទើបខ្ញុំអាចប្រាប់ដល់តុលាការថា អ្នកណាជាមេក្លោងក្នុងការសម្លាប់រង្គាល» ។

◆ នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៦ ចៅក្រមនិងសហព្រះរាជអាជ្ញាកម្ពុជា១៧រូប និងអន្តរជាតិ៨រូប ដែលត្រូវជ្រើសរើសឲ្យធ្វើជាអធិបតីនៃសាលាក្តីខ្មែរក្រហម ធ្វើពិធីសច្ចាប្រណិធានចូលកាន់តំណែងដែលប្រារព្ធឡើងនៅព្រះបរមរាជវាំង ។

◆ នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦ មេធាវីរបស់ ឌុច លោក កា សាវុធ និយាយថា គាត់នឹងធ្វើពហិការមិនចូលរួមការកាត់ក្តីនេះទេ ពីព្រោះចៅក្រមកម្ពុជាស្ទើរតែទាំងអស់នៅសាលាក្តីខ្មែរក្រហមបានបាត់បង់បងប្អូនដោយសាររបបនេះ ។

◆ នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៦ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រកាសនៅឯសន្និសីទកាសែតថា «ដើម្បីធានាថាអតីតមេដឹកនាំខ្មែរក្រហមទទួលបានការការពារគ្រប់គ្រាន់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងបង្កើតការិយាល័យមេធាវីការពារក្តី ដែលមានមេធាវីបរទេសជាបុគ្គលិក ។ លោក រូផឹត ស្គីលបេក (**Rupert Skilbeck**) ប្រធានក្រុមមេធាវីការពារក្តីដែលដឹកនាំការិយាល័យនេះបាននិយាយថា ច្បាប់ស្តីពីការចាត់តាំងគណៈមេធាវីត្រូវតែធ្វើវិសោធនកម្ម ដើម្បីឲ្យមេធាវីបរទេសចូលបម្រើជាក្រុមប្រឹក្សាសហមេធាវីការពារក្តីនៅកម្ពុជា ហើយថាមេធាវី១៥រូបនឹងធ្វើជាបុគ្គលិកការិយាល័យការពារក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីធានាបាន «ភាពស្មើគ្នា» រវាងការកាត់ទោសនិងការការពារនៅសាលាក្តី ។

◆ នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៦ អតីតព្រះមហាវីរក្សត្រ សម្តេចព្រះនរោត្តម សីហនុ ចេញព្រះរាជប្រកាសថា ព្រះអង្គប្រឆាំងនឹងសាលាក្តីខ្មែរក្រហមដែលទើបសម្ពោធនេះ ដោយមានបន្ទូលថា សាលាក្តីនេះនឹងកាត់ទោសតែអ្នកដែលទទួលខុសត្រូវរបបនេះមួយក្តាប់តូចប៉ុណ្ណោះ ហើយថាថវិកានេះគួរតែចំណាយទៅលើការកាត់បន្ថយភាពក្រីក្រវិញ ។

◆ នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៦ រដ្ឋមន្ត្រីក្រសួងព័ត៌មាន លោក ខៀវ កាញារិទ្ធ ចោទប្រកាន់អ្នកកាសែតពីបទរំខានផ្លូវចិត្តនិងបំភិតបំភ័យអតីតមេដឹកនាំខ្មែរក្រហម ដោយបន្ថែមថា ការខិតខំប្រឹងប្រែងរាយការណ៍ស្តីពីចលនាខ្មែរក្រហមរបស់ពួកគេគឺជាផ្នែកមួយនៃ «ការឃ្លាំមើលខ្មែរក្រហម» ដែលអាចបង្កគ្រោះថ្នាក់ដល់សាលាក្តី ។

◆ នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦ លោក នួន ជា អតីតបងធំទីពីរនៅសម័យខ្មែរក្រហមបដិសេធពាក្យចចាមអារាមដែលថាគាត់និងលោក ខៀវ សំផន ដែលជាប្រធានរដ្ឋព្យាយាមរត់គេចខ្លួន ។ «ខ្ញុំចង់បង្ហាញថា អតីតមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យនឹងមិនរត់ចោលប្រទេសជាតិទេ យើងនឹងរស់នៅក្នុងប្រទេស» ។

◆ នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៦ មេធាវីរបស់ តាម៉ុក និយាយថា តាម៉ុក អតីតមេបញ្ជាការយោធាខ្មែរក្រហមបាត់បង់ស្មារតី ហើយអាចនឹងស្លាប់ក្នុងពេលឆាប់ៗនេះ ។

◆ នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៦ ទោះបីជាអតីតព្រះមហាក្សត្រនរោត្តម សីហនុ បដិសេធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក៏ដោយ ក៏ព្រះអង្គបានចេញព្រះរាជសារថា ទ្រង់មានសុឆន្ទៈនឹងធ្វើសេចក្តីអធិប្បាយនៅក្នុងតុលាការ ។ «ខ្ញុំមិនមែនខ្វះសេចក្តីក្លាហានក្នុងការផ្តល់ចម្លើយមុនពេលមានអង្គជំនុំជម្រះទេ ។ គ្រួសាររបស់ខ្ញុំនិងព្រះអគ្គមហេសី ព្រមទាំងប្រជាជនជាច្រើនដែលគាំទ្រព្រះមហាក្សត្រនរោត្តម សីហនុ សុទ្ធតែទទួលរងទារុណកម្មនិងត្រូវបានសម្លាប់ដោយ ប៉ុល ពត" ។ ទោះបីជាយ៉ាងនេះក្តី មន្ត្រីក្រសួងព័ត៌មានលោក ខៀវ កាញារិទ្ធ បាននិយាយថា រដ្ឋាភិបាលមិនចង់ឲ្យព្រះមហាក្សត្រដែលចូលនិវត្តន៍បង្ហាញព្រះកាយមុនពេលមានអង្គជំនុំជម្រះទេ ពីព្រោះទ្រង់គឺជានិមិត្តរូបរបស់ជាតិទាំងមូល ។

◆ នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦ រយៈពេល៤ខែ ២សប្តាហ៍បន្ទាប់ពីត្រូវបានចាប់ខ្លួននិងដាក់ឃុំឃាំងដោយមិនទាន់ទទួលការកាត់ទោសដោយរដ្ឋាភិបាល តាម៉ុក អាយុ៨១ឆ្នាំ ត្រូវស្លាប់នៅមន្ទីរពេទ្យយោធាព្រះកេតុមាលាវេលាម៉ោង៨:៤៥នាទីព្រឹក ។ វេជ្ជបណ្ឌិតម្នាក់ដែលបដិសេធមិនបញ្ចេញឈ្មោះបាននិយាយថា តាម៉ុក ស្លាប់ដោយជំងឺចាស់ជរានិងរបេង ។

◆ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៦ សាកសពរបស់ តាម៉ុក ត្រូវបានយកទៅកប់នៅស្រុកអន្លង់វែង ខេត្តឧត្តរមាន-ជ័យ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាចាប់ផ្តើមបណ្តុះបណ្តាលមន្ត្រីប៉ូលិស១២រូប អំពីវិធីសាស្ត្រស៊ើបអង្កេតឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយខ្មែរក្រហមនិងវិធីសាស្ត្រសម្ភាសន៍ជនរងគ្រោះនិងជនសង្ស័យ ។

ក្មួយស្រីរបស់ តាម៉ុក ឈ្មោះ វិន រ៉ា និយាយថា តាម៉ុក បានប្រាប់គាត់ថា តុលាការយោធាបានបដិសេធមិនព្យាបាលគាត់អស់ពេលជាច្រើនខែនៅពេលនាងបានជួបគាត់កាលពីចុងសប្តាហ៍មុន ។ «គាត់ប្រាប់ខ្ញុំថា គាត់បានសុំឲ្យអ្នកដែលមើលថែគាត់បញ្ជូនគាត់ទៅមន្ទីរពេទ្យអស់រយៈពេល៣ខែមកហើយ ទើបគេបានបញ្ជូនគាត់ទៅមន្ទីរពេទ្យ» ។

◆ នៅថ្ងៃទី២៤-២៥ ខែកក្កដា ឆ្នាំ២០០៦ ប្រធានឃុំចំនួន

*៥១២រូបមកពីទូទាំងប្រទេសទៅទស្សនាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង វាលពិឃាដជើងឯក និងទីតាំងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ពួកគាត់ក៏បានជជែកជាមួយសមាជិករដ្ឋសភាដែលចូលរួមក្នុងការព្រាងច្បាប់សាលាក្តីខ្មែរក្រហមជាមួយមន្ត្រីសាលាក្តី និងអគ្គរដ្ឋទូតអាមេរិកប្រចាំនៅទីក្រុងភ្នំពេញ ។*

*◆ នៅថ្ងៃទី១៧-២៤ ខែសីហា ឆ្នាំ២០០៦ គម្រោងចុះផ្សព្វផ្សាយដល់មូលដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា មាននិស្សិតស្ម័គ្រចិត្តចំនួន១៤២នាក់ មកពីសាកលវិទ្យាល័យនានានៅក្រុងភ្នំពេញធ្វើដំណើរទៅកាន់ខេត្តចំនួន១៦ ដើម្បីផ្សព្វផ្សាយព័ត៌មានស្តីពីសាលាក្តីខ្មែរក្រហម ។ ពួកគេក៏បានសម្ភាសន៍អ្នកនៅរស់ពីរបបកម្ពុជាប្រជាធិបតេយ្យផងដែរ ។ ព័ត៌មានដែលបានផ្តល់ទៅប្រជាជនរួមមាន សៀវភៅណែនាំស្តីពីការកាត់ទោសខ្មែរក្រហម កូនសៀវភៅពីរក្បាលដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីច្បាប់កាត់ទោសខ្មែរក្រហម កិច្ចព្រមព្រៀងស្តីពីការបង្កើតសាលាក្តីរបស់អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ហើយនឹងសុន្ទរកថានិងអត្ថបទផ្សេងៗដែលទាក់ទងទៅនឹងសាលាក្តី ។*

*◆ នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៦ រដ្ឋាភិបាលអាមេរិកផ្តល់ទឹកប្រាក់២លានដុល្លារអាមេរិកទៅឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាទុកជា «មូលនិធិប្រចាំឆ្នាំ» ។ មូលនិធិនេះគឺជាជំនួយរបស់ប្រជាជននៅសហរដ្ឋអាមេរិកដែលផ្តល់ទៅឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិអាមេរិក ក្នុងគោលបំណងពង្រឹងចំណេះដឹងឲ្យមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។*

*◆ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៦ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកោះហៅក្រុមហ៊ុនឯកជនមកដេញថ្លៃទទួលសិទ្ធិសាងសង់មណ្ឌលឃុំខ្លួនចុងចោទរបស់សាលាក្តីមុនការកាត់ទោស ។ អ្នកនាំពាក្យសាលាក្តីខ្មែរក្រហមលោក រាជ សម្បត្តិ បាននិយាយថា មណ្ឌលឃុំខ្លួននេះនឹងត្រូវសាងសង់ក្នុងបរិវេណសាលាក្តីក្នុងខេត្តកណ្តាល ។ គាត់មានប្រសាសន៍ថា មណ្ឌលនេះមានសារ-សំខាន់ដោយសារអង្គជំនុំជម្រះវិសាមញ្ញមានទីតាំងនៅក្រៅទីក្រុង ហើយសាលាក្តីមិនចង់ដឹកជញ្ជូនជនសង្ស័យទៅមកតុលាការនោះទេ ។*

*◆ នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៦ សិស្ស និស្សិត បុគ្គលិកនិងប្រជាជនចាមមូស្លីមចំនួន១៤៥នាក់ធ្វើការបន់ស្រន់នៅព្រះវិហារខ្ទូបៃ ដែលនេះជាផ្នែកមួយនៃការប្រមូលផ្តុំជាសាកលដើម្បីរំឭកដល់ការបញ្ចប់អំពើប្រល័យពូជសាសន៍នៅតំបន់ដាហ្វួរ ។*

*បាតុករពាក់អាវយឺតដែលមានអក្សរថា «យើងទាំងអស់គ្នាគឺជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ យើងមិនគាំទ្រការសម្លាប់នៅប្រទេសស៊ូដង់ទេ» ហើយអ្នកទាំងនោះបានធ្វើដំណើរមកកាន់សារមន្ទីរអំពើប្រល័យពូជសាសន៍ទួលស្លែងនៅពេលថ្ងៃ ។*

*ប្រជាជនរាប់ម៉ឺននាក់នៅទីក្រុងញូវយ៉ក ឡុងដ៍ ប៉ារីស និងប្រទេសជាច្រើនទៀតនៅលើពិភពលោកនាំគ្នាធ្វើបាតុកម្មដើម្បីគោរពដល់ «ទិវាពិភពលោកសម្រាប់ប្រទេសដាហ្វួរ» ។*

*◆ នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៦ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចេញផ្សាយតាមរយៈវេបសាយថ្មី ។ វេបសាយ* www.eccc.gov.kh *ផ្តល់ជាខ្សែអាត់សំឡេងនិងវីដេអូនៃសវនាការជំនុំជម្រះក្តីនិងដីកាតុលាការ ។ វេបសាយនេះនឹងមានជាភាសាបារាំងបន្ថែមលើភាសាខ្មែរនិងអង់គ្លេស ។*

*◆ នៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០០៦ សាលាក្តីខ្មែរក្រហមបានចេញសេចក្តីព្រាងវិធានផ្ទៃក្នុងដើម្បីឲ្យសាធារណជនផ្តល់យោបល់ ។ សេចក្តីព្រាងបទបញ្ជាផ្ទៃក្នុងនេះកំណត់ពីតួនាទីចៅក្រមព្រះរាជអាជ្ញា មេធាវីការពារក្តី ជនសង្ស័យ សាក្សី និងជនរងគ្រោះដែលបង្ហាញខ្លួនមុខអង្គជំនុំជម្រះ ។ គេមានវិធីសាស្ត្រដូចជាការបំលែងសំឡេងនិងការបិទបាំងមុខមាត់ដើម្បីការពារសាក្សី ។ ប្រាក់ពិន័យ១ម៉ឺនដុល្លារអាមេរិកនឹងត្រូវពិន័យប្រសិនបើសាក្សីត្រូវបានគេស្គាល់ ។ សេចក្តីព្រាងច្បាប់នេះក៏អនុញ្ញាតឲ្យជនរងគ្រោះធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីដើម្បីអះអាងការខូចខាតផងដែរ ។*

*◆ នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៦ អង្គជំនុំជម្រះវិសាមញ្ញបញ្ចប់ការងារសាងសង់មណ្ឌលឃុំខ្លួនដែលមាន៤បន្ទប់ ។ បន្ទប់នីមួយៗមានបំពាក់ដោយម៉ាស៊ីនត្រជាក់និងប្រព័ន្ធទឹកក្តៅ ។ ការចំណាយលើការសាងសង់អស់ទឹកប្រាក់ចំនួន៤៥.០០០ ដុល្លារអាមេរិកដែលផ្តល់ឲ្យដោយប្រទេសជប៉ុន ។* ***(នៅមានត)***

**គាត លក្ខិណា**

# អ្នកនឹងក្លាយទៅជាជីនៅវាលស្រែ

នាពេលថ្មីៗនេះ អ្នកភូមិជាច្រើនដែលរស់នៅក្បែរភ្នំទ្រង់បាត្រក្នុងស្រុកក្រឡាញ់ ខេត្តសៀមរាបបានចែករំលែកនូវការចងចាំរបស់ពួកគេចំពោះការប្រព្រឹត្តយ៉ាងឃោរឃៅរបស់ខ្មែរក្រហមក្នុងការប្រើប្រាស់សំណល់សាកសពប្រជាជនកម្ពុជាជាច្រើនដែលបានស្លាប់មកធ្វើជាជីនៅវាលស្រែប្រាប់ក្រុមគម្រោងជួយជនរងគ្រោះដាក់ពាក្យបណ្តឹងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកដែលនៅរស់ជាច្រើនទៀតពីរបបប៉ុល ពត បានពិពណ៌នាអំពីរឿងរ៉ាវដ៏គួរឲ្យរន្ធត់ចំពោះការដែលបានឃើញការប្រើប្រាស់សាកសពមនុស្សនិងដេះដើម្បីធ្វើឲ្យដីមានជីជាតិ ។ បន្ទាប់មក ដីនេះត្រូវបានប្រើសម្រាប់ដាំស្រូវដែលខ្មែរក្រហមយកទៅដោះដូរជាអាវុធមកវិញ ដើម្បីគាំទ្ររបបដ៏ឃោរឃៅរបស់ខ្លួនជំនួសឲ្យការចិញ្ចឹមប្រជាជនកម្ពុជាដែលកំពុងស្រេកឃ្លាន ។

របាយការណ៍ដំបូងបំផុតដែលបានកត់ត្រាទុកពីការប្រើប្រាស់សំណល់សាកសពមនុស្សធ្វើជាជី ចេញមកពីការស៊ើបអង្កេតជាច្រើនលើករបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាក្នុងឆ្នាំ១៩៧៩ គឺជាសម័យដែលកើតឡើងក្រោយការដួលរលំរបស់ខ្មែរក្រហម ។ អ្នកស៊ើបអង្កេតបានកត់ត្រាទុកនូវបទសម្ភាសន៍ជាមួយសាក្សីបីរូប នៅស្រុកក្រឡាញ់ ខេត្តសៀមរាប ដែលពិពណ៌នាអំពីរឿងរ៉ាវនៃឃាបនដ្ឋានមួយចំនួនក្បែរភ្នំទ្រង់បាត្រ ។

គង់ សារ៉ាយ ដែលមានអាយុ២៥ឆ្នាំ នៅក្នុងពេលធ្វើសម្ភាសន៍ឆ្នាំ១៩៧៩ ត្រូវបានទាហានខ្មែរក្រហមចាប់ខ្លួនជាមួយនឹងសមាជិកគ្រួសាររបស់គាត់៩នាក់ទៀត ដោយចោទប្រកាន់ក្រុមគ្រួសាររបស់គាត់ថាខ្សិលប្រអូស ហើយទាហានទាំងនោះបានបំបែកសមាជិកក្រុមគ្រួសាររបស់គាត់ឲ្យនៅឆ្ងាយពីគ្នា និងទុកឲ្យគាត់នៅតែម្នាក់ឯងក្នុងមន្ទីរឃុំឃាំង ។ នៅពេលដែលទាហានទាំងនោះត្រឡប់មកវិញ ក៏ចាប់ផ្តើមបែងចែកសម្លៀកបំពាក់របស់ក្រុមគ្រួសារគាត់ឲ្យអ្នកភូមិ ហើយពេលនោះគាត់ដឹងថា គ្រួសារគាត់ត្រូវបានខ្មែរក្រហមសម្លាប់អស់ហើយ ។ គាត់ក៏បានដឹងតាមរយៈអ្នកភូមិជាច្រើនទៀតពីរណ្តៅដែលខ្មែរក្រហមបានជីកនៅក្បែរៗនោះ ដែលជាកន្លែងខ្មែរក្រហមនាំយកអ្នកទោសទៅសម្លាប់និងដុតសាកសពនោះធ្វើជាជីដែរ ។ សារ៉ាយ ប្រាកដថា គ្រួសារគាត់ពិតជាត្រូវបានខ្មែរក្រហមសម្លាប់ដោយវិធីនេះ ។

ពីរបីថ្ងៃក្រោយមក សារ៉ាយ ត្រូវបានអង្គការបញ្ជូនឲ្យទៅជួសជុលរបងដែលមានចម្ងាយតែប្រាំម៉ែត្រប៉ុណ្ណោះពីឃាបនដ្ឋានទាំងនោះ ហើយបានឃើញបុរសជាច្រើនអង្គុយលើគំនរឆ្អឹងរបស់មនុស្ស ។ ថ្ងៃបន្ទាប់ គាត់បានឃើញរថយន្តជាច្រើនដឹកមនុស្សចំនួន៦០នាក់ដែលត្រូវបានវាយដំរហូតដល់ស្លាប់ រួចយកទៅទម្លាក់ក្នុងរណ្តៅភ្លើងដែលដុតដោយអង្កាមនិងប្រេង ។

អ្នកស្រី មុន នី ដែលមានអាយុ៣០ឆ្នាំ នៅក្នុងបទសម្ភាសន៍របស់គាត់បានឲ្យដឹងថា គាត់ត្រូវបានខ្មែរក្រហមឃុំនៅក្នុងមន្ទីរឃុំឃាំងដោយគ្មានមូលហេតុ ។ ទោះបីជាគាត់មិនធ្លាប់ឃើញទាហានបោះមនុស្សចូលទៅក្នុងឃាបនដ្ឋាននៅអំឡុងពេលនៃការឃុំឃាំងរបស់គាត់ក៏ដោយ ក៏គាត់ធ្លាប់បានឮកម្មាភិបាលខ្មែរក្រហមពិភាក្សាគ្នាអំពីវិធីសាស្ត្រសម្លាប់មនុស្សដែរ ដូចជាបន្ទាប់ពីនាំក្រុមអ្នកទោសទាំងនោះទៅដល់ជើងភ្នំ ខ្មែរក្រហមបានបង្ខំឲ្យកិននិងខ្ទប់ដីដែលធ្វើពីឆ្អឹងជនរងគ្រោះពីមុន ។ ក្រោយមក ចងអ្នកទោសទាំងនោះ រួចវាយនឹងដំបងម្តងហើយម្តងទៀត បន្ទាប់មកបោះអ្នកទាំងនោះចូលទៅក្នុងរណ្តៅ ។ សាកសពត្រូវបានដុតជាមួយអង្កាមនិងប្រេងកាតធ្វើជាជីបន្ថែមទៀតសម្រាប់ឲ្យជនរងគ្រោះកិននិងខ្ទប់ជាបន្តបន្ទាប់ ។

អ្នកស្រី មុន នី បានរំឭកថា អ្នកភូមិជាច្រើនត្រូវបានហាមឃាត់មិនឲ្យចូលទៅក្នុងទីតាំងដែលត្រូវបានហ៊ុមព័ទ្ធទៅដោយដើមឈើយ៉ាងក្រាស់ ។ យ៉ាងណាមិញ ផ្សែងពណ៌សអណ្តែតឡើងទៅលើនិងក្លិនឈ្ងៀមនៃសាកសពរបស់មនុស្សដែលគេបានដុត អ្នកភូមិស្រូបផ្សែងនេះរាល់ថ្ងៃពេលគាត់ធ្វើការនៅក្នុងវាលស្រែដែលបានប្រាប់ពួកគេឲ្យដឹងពីអ្វីដែលបានកើតឡើងនៅទីនេះ ។

បន្ទាប់ពីថ្ងៃរំដោះ ពេលដែលអ្នកស្រី មុន នី ទៅមើលទីតាំងនោះ គាត់បានឃើញដោយផ្ទាល់ភ្នែកនូវគ្រោងឆ្អឹងសាកសពរបស់មនុស្សនិងដេះដែលបានបន្សល់ទុកពីសាកសពប្រជាជនកម្ពុជាជាច្រើនគ្រឿងដែលខ្មែរក្រហមដឹកយកទៅសម្លាប់នៅទីនោះ ។

អ្នកស្រី បែ វ៉ាន់ថុន ដែលមានអាយុ២៥ឆ្នាំ នៅក្នុងបទសម្ភាសន៍របស់គាត់បានឲ្យដឹងថា នៅអំឡុងពេលនៃការឃុំខ្លួន គាត់បានឃើញរទេះគោចំនួនប្រាំមួយដឹកមនុស្សមកជរំជារៀងរាល់ថ្ងៃនិងសម្លាប់ចោល ។ គាត់ក៏បានរំឭកផងដែរពីផ្សែងពណ៌សដែលអណ្តែតឡើងនិងក្លិនឈ្ងៀមនៃសាច់មនុស្សដែលត្រូវខ្មែរក្រហមដុត ព្រោះគាត់ធ្វើការងារធ្ងន់នៅក្នុងជរំឃុំឃាំងនោះ ។ គាត់ចាំកន្លែងដែលបិទបាំងដោយដើមឈើនិងហ៊ុមព័ទ្ធដោយបន្លាលួសគឺជាកន្លែងដែលហាមឃាត់អ្នកភូមិទាំងអស់មិនឲ្យចូលទៅ ។ ទោះបីជាគាត់មិនធ្លាប់ឃើញការដុតសាកសពក៏ដោយ ក៏គាត់បានប្រាប់រឿងរ៉ាវដូចគ្នាដែលអ្នកទោសទាំងនោះត្រូវបានវាយនឹងព្រនង់រួចបោះចូលទៅក្នុងភ្លក់ភ្លើងដុតជាមួយប្រេងកាតនិងអង្កាម ។

ស្របតាមការរៀបរាប់របស់សាក្សីទាំងអស់ មន្ត្រីរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាបានស៊ើបអង្កេតទីតាំងនៃឈាបនដ្ឋាននៅជើងភ្នំទ្រង់បាត្រ ។ ឯកសារស្តីពីរបាយការណ៍ស៊ើបអង្កេតលើប្រឡាយទឹក គឺផ្ទុកទៅដោយបំណែកឆ្អឹងមនុស្សដែលត្រូវបានខ្មែរក្រហមដុត ។ អ្នកស៊ើបអង្កេតបានត្រួតពិនិត្យប្រឡាយទឹកចំនួនប្រាំបី អណ្តូងដៃ និងស្រះទឹកធំមួយ ។ គេបានរកឃើញថាជញ្ជាំងនៃប្រឡាយទឹកខ្លះត្រូវបានធ្វើឲ្យខ្មៅ ដេះត្រូវបានពង្រាយនិងបំណែកឆ្អឹងឆេះរោលរាល ។ បំណែកដែលគេអាចមើលស្គាល់រួមមានដូចជាសន្លាក់ឆ្អឹង និងបំណែកសន្លាក់ឆ្អឹងខ្នងខ្លះ ផ្នែកមួយនៃឆ្អឹងជំនីរ ឆ្អឹងជើង និងឆ្អឹងលលាដ៏ក្បាលដែលត្រូវបានដុត ។ ក្រុមមន្ត្រីក៏បានរកឃើញផងដែរនូវគំនរអង្កាមនិងកម្ទេចខោអាវកខ្វក់ដែលគេជឿថា វាបានមកពីខោអាវដែលគេប្រើរួច ។

របាយការណ៍បានបញ្ជាក់ថា បន្ទាប់ពីខ្មែរក្រហមភៀសខ្លួនចេញពីតំបន់នេះ អ្នកភូមិបានកប់ឆ្អឹងដែលត្រូវបានគេដុតដោយផ្នែកៗជាច្រើន និងបានកាយដីបំពេញប្រឡាយទឹកខ្លះដើម្បីបន្ទូរទុក្ខព្រួយរបស់គាត់ពីអំពើដ៏ឃោរឃៅដែលបានកើតឡើងនៅភ្នំទ្រង់បាត្រ ។ អ្នកភូមិនិងអាជ្ញាធរក្នុងតំបន់ត្រូវបានគេអះអាងថា មានគម្រោងសាងសង់ «វិមាននៃសេចក្តីស្អប់ខ្ពើមឧក្រិដ្ឋកម្មប្រល័យពូជសាសន៍» មួយនៅកន្លែងនោះ ។ កំណត់ត្រាជាច្រើនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបង្ហាញថា ទីតាំងចងចាំបែបនេះមានឈ្មោះថា វាលពិឃាដភ្នំទ្រង់បាត្រ ។

អ្នកដែលនៅរស់ពីសម័យខ្មែរក្រហមបានរាយការណ៍ពីអត្ថ-ប្រយោជន៍នៃសំណល់សាកសពមនុស្សដែលមិនត្រូវបានធ្វើជាដី ។ អ្នកស្រី នួន ធួក ជាងកាត់ខោអាវនៅខេត្តសៀមរាបបានរាយការណ៍ប្រាប់អ្នកស៊ើបអង្កេតនៅឆ្នាំ១៩៧៩ថា គាត់ត្រូវបានគេឲ្យដឹកយកឆ្អឹងមនុស្សជាញឹកញយ រួចកិនជាមួយនឹងទឹកនោមធ្វើជាជីសម្រាប់ដាក់ស្រែ ។ អ្នកនៅរស់ដែលបានរួមចំណែកនៅក្នុងសៀវភៅរបស់ ឌិត ប្រន មានចំណងជើងថា *វាលពិឃាដរបស់កុមារកម្ពុជា ការចងចាំរបស់អ្នកនៅរស់* រំឭកពីការចងចាំដ៏គួរឲ្យរន្ធត់ស្រដៀងគ្នារបស់ប្រជាជន ។ លី ម៉ូលី ជាកងកុមារម្នាក់នៅសម័យខ្មែរក្រហមត្រូវបានបង្ខំឲ្យប្រមូលសំណល់សាកសពមនុស្សជាមួយដី ។ ដូចគ្នានេះដែរ ចាន់ យីគីមនី និយាយថា «នៅពេលខ្លះពួកគេបោះផ្នែកខ្លះនៃខ្លួនក្មេងប្រុសដែលគេបានកាត់ជាចំណែកទៅក្នុងវាលស្រែនៅពេលដែលយើងធ្វើការនៅកន្លែងនោះ ។ ពួកគេនឹងនិយាយថា «ជី» ។

ការអនុវត្តធ្វើឲ្យមនុស្សលោកក្លាយទៅជាជី គឺជាការបញ្ជាក់យ៉ាងច្បាស់ពីការដកហូតភាពជាមនុស្សរបស់ប្រជាជនកម្ពុជាដោយខ្មែរក្រហម ។ ជារបបដែលមិនឲ្យតម្លៃទៅលើអាយុជីវិតរបស់មនុស្សដែលត្រូវបានគេដឹងយ៉ាងទូលំទូលាយតាមរយៈពាក្យស្លោករបស់ខ្មែរក្រហមគឺ «ទុកក៏មិនចំណេញ ដកចេញក៏មិនខាត» ។ គីវ ឃួន ជាកុមារនៅក្នុងសម័យនោះបានចងចាំនូវការគំរាមកំហែងដែលធ្វើឡើងដើម្បីក្រើនរំឭកដល់ប្រជាជនអំពីភាពគ្មានតម្លៃរបស់ពួកគេនៅក្នុងក្រសែភ្នែករបស់អង្គការ «អ្នកនឹងក្លាយជាជីនៅវាលស្រែ» ។

**សេឌី ប្លែនឆាដ**

# គម្រោងជួយជនរងគ្រោះដាក់ពាក្យបណ្តឹងនិងក្រុមថតខ្សែភាពយន្តនៅខេត្តសៀមរាប

ខេត្តសៀមរាបត្រូវបានពិភពលោកដឹងថាជាទីកន្លែងដែលទាក់ទាញចំណាប់អារម្មណ៍បំផុតសម្រាប់អ្នកទេសចរណ៍បរទេស ។ ជារៀងរាល់ឆ្នាំ យន្តហោះដឹកអ្នកដំណើរជាច្រើនគ្រឿងហោះហើរទៅកាន់ខេត្តសៀមរាប ដោយស្នាក់នៅសណ្ឋាគារដ៏ប្រណីតៗ និងទស្សនាប្រាសាទបុរាណដែលគួរឲ្យស្ញប់ស្ញែង រួចចាកចេញទៅវិញ ។ ទោះបីជាកន្លែងខ្លះមានស្នាមប្រហោងដោយសារគ្រាប់កាំភ្លើងនិងរូបសំណាកបាក់បែកនៅប្រាសាទអង្គរវត្ត ដែលការបំផ្លាញនេះបង្កដោយខ្មែរក្រហមក៏ដោយ ក៏ភ្ញៀវទេសចរណ៍សាមញ្ញនៅតែចាប់អារម្មណ៍នឹងសម្រស់នៃប្រាសាទទាំងឡាយនិងភាពរុងរឿងនៃទីក្រុងនេះដែរ ។

គ្រាន់តែមើលទៅលើប្រវត្តិសាស្ត្រនៃខេត្តសៀមរាប ក៏វាបង្ហាញឲ្យឃើញរឿងរ៉ាវយ៉ាងស្មុគស្មាញស្តីពីអំពើដ៏ឃោរឃៅការរងទុក្ខយ៉ាងធ្ងន់ធ្ងរនិងអ្នកដែលទទួលរងការឈឺចាប់ដែរ ។ ប្រាសាទដ៏ល្អឆើតឆាយទាំងឡាយត្រូវបានជឿដោយអ្នកប្រវត្តិសាស្ត្រជាច្រើនថាជាសមិទ្ធផលនៃប្រព័ន្ធគ្រប់គ្រងទាសករក្នុងចំណោមប្រជាជនមិនអាចគណនាបានអស់ ដែលបានបាត់បង់ជីវិតនៅក្រោមអំណាចដ៏រឹងមាំរបស់អ្នកកាន់អំណាចដែលឆ្កួតនឹងយសស័ក្តិ ។ វាមានភាពស្របគ្នាដែលមិនអាចប្រកែកបានរវាងការបញ្ចេញទឹកមុខចំនួនពីររយដប់ប្រាំមួយនៃប្រាង្គប្រាសាទបាយ័ននិងការកាប់សម្លាប់ដែលមិនអាចចៀសវាងបាននៃអង្គការកម្ពុជាប្រជាធិបតេយ្យ ។ ការភ្ជាប់រវាងខ្មែរក្រហមនិងភាពស្មុគ-ស្មាញនៃប្រាសាទមិនគ្រាន់តែមានលក្ខណៈទ្រឹស្តីទេ ។ ថ្មីៗនេះនៅឆ្នាំ១៩៩៣ ខ្មែរក្រហមបានធ្វើការលុកលុយយ៉ាងធ្ងន់ធ្ងរនៅក្នុងតំបន់ប្រាសាទនិងបានកាន់កាប់ប្រាសាទបន្ទាយស្រីថែមទៀតផង ។

រឿងរ៉ាវនៃខេត្តសៀមរាបពិតជាធំជាងប្រាសាទនានានៃតំបន់អង្គរទៅទៀត ។ សម្រាប់អ្នករួចរស់ជីវិតរាប់ពាន់នាក់ពីរបបកម្ពុជាប្រជាធិបតេយ្យដែលរស់នៅក្នុងតំបន់ជនបទនៃខេត្តសៀមរាប ការបំផ្លិចបំផ្លាញក្នុងសម័យខ្មែរក្រហមគឺជាការពិតដ៏ឈឺចាប់ ។ ខេត្តសៀមរាបត្រូវបានដឹងថាស្ថិតក្នុងតំបន់១០៦ឬភូមិភាគពាយ័ព្យនៅក្នុងអំឡុងសម័យខ្មែរក្រហម ។ នៅឆ្នាំ១៩៧៥ ប្រជាជនកម្ពុជារាប់ពាន់នាក់ត្រូវបានបង្ខំឲ្យផ្លាស់ទៅរស់នៅក្នុងជំរំកសិកម្មនានានៅទីជនបទនៃខេត្តសៀមរាប នៅពេលដែលខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញនិងសៀមរាប ។ ការផ្តួចផ្តើមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានគូសផែនទីរណ្តៅសាកសពរាប់រយក្នុងខេត្តសៀមរាប ដែលពោរពេញទៅដោយសំណល់សាកសពជនរងគ្រោះក្នុងសម័យខ្មែរក្រហមរាប់ពាន់នាក់ដែលមិនស្គាល់អត្តសញ្ញាណ ។ យោងទៅតាមអ្នកនៅរស់ក្នុងតំបន់នេះ ខ្មែរក្រហមបានសម្លាប់សមាជិកគ្រួសារគាត់ទាំងអស់នៅពេលតែមួយនិងកប់ពួកគេនៅក្នុងរណ្តៅទាំងនេះ នៅក្នុងការប៉ុនប៉ងបំបាត់ក្រុមគ្រួសារនោះពីភាពរស់រានមានជីវិត ។ មីននិងគ្រាប់បែកចង្កោមដែលសេសសល់រាប់ទសវត្សរ៍ពីសម័យសង្គ្រាមនៅតែរំខានដល់ខេត្តនេះ ហើយជនរងគ្រោះដោយសារអាវុធមិនស្គាល់មុខទាំងនេះតែងតែត្រូវប្រទះឃើញជាញឹកញាយ ។ តំបន់នានានៃខេត្តនេះបានបន្តធ្វើឲ្យមានគ្រោះថ្នាក់សម្រាប់ការធ្វើដំណើររហូតដល់ឆ្នាំ១៩៩៨ ដោយសារតែទាហានខ្មែរក្រហមនិងក្រុមចោរប្លន់ ។

ថ្មីៗនេះ ខ្ញុំមានឱកាសបានមើលទីតាំងទេសចរណ៍ សៀវភៅប្រវត្តិសាស្ត្រ ឯកសារដែលបានរក្សាទុក និងទីជនបទនានានៃខេត្តសៀមរាបជាមួយនឹងគម្រោងជួយជនរងគ្រោះដាក់ពាក្យបណ្តឹងនិងក្រុមថតខ្សែភាពយន្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ គម្រោងជួយជនរងគ្រោះដាក់ពាក្យបណ្តឹងព្យាយាមផ្តល់ការគាំទ្រដល់ជនរងគ្រោះទាំងឡាយដែលមានបំណងចូលរួមនៅក្នុងសាលាក្តីខ្មែរក្រហម (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា) ក្នុងនាមជាអ្នកប្តឹងតវ៉ាឬដើមបណ្តឹងរដ្ឋប្បវេណី ។ គម្រោងនេះក៏ព្យាយាមស្វែងរកបុគ្គលដែលបានចុះហត្ថលេខាលើញត្តិរបស់រដ្ឋាភិបាល (ដែលមានឈ្មោះថា «ញត្តិរណសិរ្ស») នៅដើមឆ្នាំ១៩៨០ ដែលមានបំណងប្រាប់ដល់អង្គការសហប្រជាជាតិអំពីភាពឃោរឃៅនៃរបបកម្ពុជាប្រជាធិបតេយ្យដែរ ប៉ុន្តែមិនដែលបានផ្ញើទៅដល់អង្គការប្រជាជាតិទេ ហើយបច្ចុប្បន្នមិនដឹងថាតើអ្នកធ្វើញត្តិ

ទាំងនេះចង់សើរើបណ្ដឹងរបស់ពួកគេតាមរយៈសាលាក្ដីដែរឬទេ ។ ទោះបីជាគោលបំណងជាមូលដ្ឋាននៃគម្រោងជួយជនរងគ្រោះដាក់ពាក្យបណ្ដឹងជួយដល់ការងាររបស់សាលាក្ដីក៏ដោយ ក៏លទ្ធផលសំខាន់ស្មើគ្នានៃការងារនេះគឺការសរសេររៀបរាប់ពីប្រវត្តិរបស់អ្នកនៅរស់និងការថតជាខ្សែភាពយន្ត ព្រមទាំងផ្សព្វផ្សាយទៅកាន់អ្នកនៅរស់ទាំងអស់ថាការឈឺចាប់និងការនៅរស់របស់គាត់មានសារសំខាន់ណាស់ចំពោះប្រទេសជាតិនិងពិភពលោកទាំងមូល ។

អ្នកភូមិទាំងឡាយដែលខ្ញុំបានជួបមានភាពកក់ក្ដៅនិងទទួលស្វាគមន៍ ទោះជាមានបញ្ហាផ្ទាល់ខ្លួននិងការឈឺចាប់យ៉ាងជ្រាលជ្រៅក៏ដោយ ។ ទោះបីអ្នកភូមិមួយចំនួនមិនបានចាប់អារម្មណ៍ក្នុងការនិយាយអំពីបទពិសោធន៍ជីវិតរបស់គាត់ក៏ដោយ ក៏មានអ្នកភូមិផ្សេងៗទៀតនិយាយជាមួយអ្នកសម្ភាសជាច្រើនម៉ោងអំពីការបាត់បង់មិត្តភក្ដិ ក្រុមគ្រួសារ និងរឿងជីវិតផ្ទាល់នៅពេលដែលពួកគេស្គាល់អ្នកទាំងនោះដែរ ។ បុរសវ័យកណ្ដាលម្នាក់បានចង្អុលពីទីកន្លែងដែលក្រុមយើងបានអង្គុយនៅវត្តក្នុងភូមិមួយឆ្លងកាត់ដីដែលមានគន្លងនង្គ័លទៅកាន់វាលស្រែ ។ គាត់បាននិយាយថា «នៅទីនោះខ្មែរក្រហមតម្រៀបមនុស្សដប់ពីរនាក់ជាជួរ ហើយបាញ់អ្នកទាំងនោះចំខាងក្រោយក្បាលទាំងអស់» ។ បុរសម្នាក់ទៀតបានពិពណ៌នាពីកម្មាភិបាលខ្មែរក្រហមដែលសម្លាប់ក្មេងៗដោយបោះឡើងទៅលើ រួចយកចំពុះទុងចាក់ពីក្រោម ។

អ្នកនៅរស់ជាច្រើនដែលត្រូវបានសម្ភាសនៅក្បែរភ្នំទ្រង់បាត្របានប្រាប់អ្នកសម្ភាសពីពិធីសាស្ត្រដុតមនុស្សដើម្បីធ្វើជាជីសម្រាប់ដាក់ស្រែចម្ការ ។ ឧទាហរណ៍ បុរសអាយុ៥១ឆ្នាំម្នាក់បានប្រាប់ពីបទពិសោធន៍របស់គាត់ក្នុងនាមជាអ្នកទោសម្នាក់ក្នុងមន្ទីរឃុំឃាំងភ្នំទ្រង់បាត្រ ។ គាត់បាននិយាយថា មានរណ្ដៅធំមួយនៅលើភ្នំដែលពេញដោយអង្កាម ។ កម្មាភិបាលខ្មែរក្រហមបានរង់ចាំមន្ទីរឃុំឃាំងពេញ បន្ទាប់មកទើបបញ្ជូនអ្នកទោសទាំងអស់ទៅក្បែរមាត់រណ្ដៅ រួចរុញអ្នកទាំងនោះម្នាក់ៗទៅក្នុងរណ្ដៅ ហើយដុតទាំងរស់ ។ គាត់មានសំណាងបានរត់គេចពីមន្ទីរឃុំឃាំងនិងបានចៀសផុតពីភាពដ៏គួរឲ្យរន្ធត់ដែលគ្មានទីបញ្ចប់នេះ ។ ស្ត្រីម្នាក់ទៀតបានរៀបរាប់ថា គាត់បានធ្វើការនៅកសិដ្ឋានក្បែរភ្នំដែលស្រដៀងទៅនឹងវាលស្រែ ។ គាត់អាចឃើញឆ្អឹងមនុស្សនៅក្នុងដីដែលកម្មាភិបាលខ្មែរក្រហមឲ្យគាត់យកទៅបាចនៅវាលស្រែ ។

នៅពេលខ្ញុំបានឮអំពីរឿងរ៉ាវនៃការធ្វើទារុណកម្ម និងការរងទុក្ខទោសដ៏គួរឲ្យរន្ធត់នេះ ខ្ញុំមិនអាចជួយបានទេ ប៉ុន្តែខ្ញុំមើលជុំវិញខ្លួនឃើញទីជនបទដ៏ខៀវស្រងាត់ ហើយស្រមៃថាឋាននរកទើបតែបានកើតឡើងជាងសាមសិបឆ្នាំកន្លងមកហើយ ។ លើសពីនេះ នៅពេលដែលខ្ញុំមើលមនុស្សចំណាស់ៗនៅក្នុងភូមិដែលបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែសម្ភាស ខ្ញុំមិនដឹងថាពួកគេបានចែករំលែកនូវការចងចាំនិងការឈឺចាប់ជាមួយកូននិងចៅរបស់ពួកគេប៉ុន្មាននោះទេ ។ ទោះបីអ្នកនៅរស់បានរៀបរាប់យ៉ាងក្បោះក្បាយអំពីការរងទុក្ខវេទនាប្រាប់ដល់កូនរបស់ពួកគេក៏ដោយ ក៏ខ្ញុំគិតថាក្មេងជំនាន់ក្រោយម្នាក់នោះយល់ដឹងច្បាស់ពីការកាប់សម្លាប់ដែលមិនអាចគិតដល់នេះដែរឬយ៉ាងណាទេ? ទោះបីជាសាលាក្ដីមានសារសំខាន់នៅក្នុងដំណើរការព្យាបាលរបួសក្នុងសង្គមកម្ពុជាក៏ដោយ ក៏វាចាំបាច់ផងដែរសម្រាប់ការខិតខំប្រឹងប្រែងផ្នែកច្បាប់រួមជាមួយនឹងផ្នែកឯកសារដែលមានគោលបំណងលាតត្រដាងនិងចែករំលែករឿងរ៉ាវរបស់អ្នកនៅរស់និងរួមចំណែកនៅក្នុងកំណត់ត្រាប្រវត្តិសាស្ត្រឲ្យកាន់តែទូលំទូលាយថែមទៀត ។ នៅពេលដែលសាលាក្ដីបញ្ចប់នាពេលអនាគត វានឹងមានប្រជាជនកម្ពុជាវ័យក្មេងជំនាន់ក្រោយរាប់លាននាក់ព្យាយាមរកឲ្យឃើញនិងស្វែងយល់ពីអតីតកាលរបស់អ្នកទាំងនេះតាមរយៈរឿងរ៉ាវរបស់ជនរងគ្រោះដែលបានកើតឡើងដោយគ្មានភាពងឿងឆ្ងល់ ។ **អានី វ៉ែល**

# ស្ដាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្ដីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង ៧-៧:៣០ ព្រឹក និងម៉ោង៧:០០-៧:៣០ល្ងាច ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្ដល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។ **ស៊ិន សុធីតា**

# រំពូកប្រាប់ក្មេងជំនាន់ក្រោយ

នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨ ក្រុមគម្រោងជួយជនរងគ្រោះដាក់ពាក្យបណ្តឹងទៅតុលាការខ្មែរក្រហមបានទៅជួបប្រជាជននៅទីក្រុងភ្នំពេញដើម្បីបំពេញពាក្យបណ្តឹងដែលមានការខ្វះខាត ដោយសារតែពុំមានព័ត៌មានគ្រប់គ្រាន់និងមិនអាចឲ្យតុលាការប្រើប្រាស់បាន ។ នៅពេលដែលខ្ញុំចូលទៅដល់ផ្ទះរបស់គាត់ជាលើកទីពីរ គាត់មានការភ្ញាក់ផ្អើលនិងរំភើបជាខ្លាំង ។ ប៉ុន្តែអ្នកដាក់ពាក្យបណ្តឹងដែលមានវ័យចំណាស់មួយចំនួនស្ទើរតែភ្លេចថាគាត់បានដាក់ពាក្យបណ្តឹងផ្ញើទៅតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទៅហើយ ។ ទោះបីបែបនេះក្តី គាត់នៅតែរីករាយក្នុងការផ្តល់ព័ត៌មានបន្ថែមមកដល់ខ្ញុំដដែល ។ ខ្ញុំសង្កេតឃើញថាអ្នកដាក់ពាក្យបណ្តឹងមានសេចក្តីត្រេកអរជាខ្លាំង ព្រោះតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានឆ្លើយតបមកគាត់វិញ ទោះបីត្រឹមតែជាក្រដាសមួយសន្លឹកដែលជាលិខិតថ្លែងអំណរគុណក៏ដោយ ។ នៅក្នុងចំណោមអ្នកទាំងអស់នោះ ខ្ញុំឃើញព័ត៌មានរបស់អ៊ំស្រីម្នាក់ឈ្មោះ វ៉ា រស់នៅទីក្រុងភ្នំពេញបានធ្វើឲ្យខ្ញុំចាប់អារម្មណ៍ជាខ្លាំង ព្រោះគាត់បានបាត់បង់សាច់ញាតិនិងទទួលរងទុក្ខវេទនាគ្រប់បែបយ៉ាងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយខ្មែរក្រហមបានចាត់ទុកគាត់ជាអ្នកមូលធន សក្តិភូមិ និងនាយទុន ។

នៅលើផ្ទះតែម្នាក់ឯង អ៊ំស្រី វ៉ា បានរៀបរាប់ថា គាត់ជាកូនរបស់នាយទាហានរងសក្តិ២នៅក្នុងរបបសាធារណរដ្ឋខ្មែរ ។ ក្រោយជ័យជម្នះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុងភ្នំពេញ ។ ពេលគ្រួសារគាត់ធ្វើដំណើរតាមផ្លូវឆ្ពោះទៅកាន់ខេត្តតាកែវ កងទ័ពខ្មែរក្រហមបានប្រកាសប្រាប់ទៀតថា «ទៅតែរយៈពេលបីថ្ងៃប៉ុណ្ណោះនឹងបានត្រឡប់មកផ្ទះវិញហើយ» ។ នៅតាមផ្លូវធ្វើដំណើរគាត់ឃើញប្រជាជនជាច្រើនរែក លី សែងសម្ភារៈប្រើប្រាស់របស់ខ្លួនត្រឡប់ទៅរស់នៅស្រុកកំណើតវិញ ។ មកដល់ផ្សារសំរោងយ៉ាង ស្រុកបាទី កងទ័ពខ្មែរក្រហមមួយក្រុមបានស្ទាក់ចាំ ហើយធ្វើការឆែកឆេរយកសម្ភារៈមួយចំនួនរបស់ឪពុកគាត់ដូចជាថ្នាំពេទ្យនិងវិទ្យុមួយគ្រឿង ។ ឪពុកគាត់មិនហ៊ានប្រកែកជាមួយអ្នកទាំងនោះទេ ហើយសុខចិត្តប្រគល់សម្ភារៈទាំងនេះឲ្យតាមសម្រួល ។ បន្ទាប់មក គ្រួសារគាត់និងអ្នកជម្លៀសផ្សេងៗទៀតក៏ដើរដល់ទីរួមខេត្ត ។ គ្រួសារគាត់ត្រូវបានចាត់តាំងឲ្យទៅរស់នៅស្រុកព្រៃកប្បាស ខេត្តតាកែវ ។ នៅទីនោះ គាត់ត្រូវអង្គការចាត់ឲ្យធ្វើជាការងារជាច្រើនដូចជា លើកទំនប់ ធ្វើស្រែ ជីកប្រឡាយជាដើម ។ ដោយសារគាត់ជាអ្នក១៧មេសា គាត់ត្រូវបានបង្ខំឲ្យធ្វើការងារធ្ងន់ៗ ដែលនេះជាការងារលំបាកមួយធ្វើឲ្យគាត់ស្ទើរតែទ្រាំមិនបាន ។ ថ្ងៃមួយពេលដែលគាត់សុំមេកងទៅមើលប្អូនស្រីរបស់គាត់ម្នាក់ឈ្មោះ វ៉ានី ដែលធ្លាក់ខ្លួនឈឺត្រូវបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យភ្នំចកស្រុកព្រៃកប្បាស ស្រាប់តែមេកងនោះ



អ្នកភូមិកំពុងមើលកូនឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

មិនអនុញ្ញាតឲ្យគាត់ទៅទេ ។ ដូច្នេះ គាត់បានលួចចេញពីសហករណ៍មកមើលមុខប្អូនជាលើកចុងក្រោយ ប៉ុន្តែ គាត់បានត្រឹមតែសម្រក់ទឹកភ្នែកប៉ុណ្ណោះរហូតដល់ប្អូនដាច់ដង្ហើម ។ គាត់មានការសោកស្តាយណាស់ ព្រោះគាត់មិនអាចមើលថែទាំប្អូនទាំងអស់បានបន្ទាប់ពីម្តាយគាត់ស្លាប់ដោយសារជំងឺនៅឆ្នាំ១៩៧៣ ។

៦ខែក្រោយមក គាត់និងគ្រួសារត្រូវអង្គការបញ្ជូនឲ្យទៅភូមិគោកសេះ ឃុំស្រះជីក ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ។ ទៅដល់ទីនោះ កងទ័ពខ្មែរក្រហមមួយក្រុមបានដើរមកឆែកឆេរយកសម្ភារៈទាំងអស់ដែលគ្រួសាររបស់គាត់មាន ដោយទុកឲ្យតែខោអាវមួយកំប្លេនៅជាប់នឹងខ្លួនប៉ុណ្ណោះ ។ គាត់ចាំថាកម្មាភិបាលខ្មែរក្រហមម្នាក់បានសុំមើលចិញ្ចៀនពាវង់ដែលជាកេរ្តិ៍ដំណែលរបស់ម្តាយគាត់ ស្រាប់តែកម្មាភិបាលនោះយកទៅតែម្តង ។ ដោយនឹកស្តាយចិញ្ចៀនខ្លាំងពេក គាត់បានដើរទៅដល់ផ្ទះរបស់កម្មាភិបាលនោះដើម្បីទារចិញ្ចៀនយកមកវិញ ។ ប៉ុន្តែគាត់បានឃើញតែម្តាយរបស់កម្មាភិបាលនោះប៉ុណ្ណោះ ។ ម្តាយកម្មាភិបាលនោះបានឲ្យប្រហុកនិងដួកមួយកូនក្រឡមកគាត់ ហើយផ្តាំថាឈប់មកទារចិញ្ចៀននេះទៅ ប្រយ័ត្នមានរឿង ។ ពេលមកកន្លែងស្នាក់នៅវិញ អ្នកធ្វើការជាមួយគ្នាបានលួចខ្សឹបប្រាប់គាត់ថា គាត់ហ៊ានទៅតវ៉ាដល់កន្លែងនោះប្រយ័ត្នស្លាប់ ។ នៅពេលយប់ឡើងឪពុករបស់គាត់បាននិយាយខ្សឹបប្រាប់គាត់ថា «កុំសោកស្តាយចិញ្ចៀនហ្នឹងអី» ពេលនោះមានឈ្លបចំនួនពីរ-បីនាក់បានមកក្រោមផ្ទះគាត់ចាំលបស្តាប់គាត់និងឪពុកនិយាយគ្នាក្រែងមានការមិនសុខចិត្តនឹងរឿងនេះ ហើយឈ្លបទាំងនោះនិយាយខ្សឹបៗប្រាប់គ្នាថា «ល្មមៗបោសសម្អាតទៅ កុំគិតច្រើនពេក» ។



បន្ទាប់មកគ្រួសាររបស់គាត់ត្រូវបញ្ជូនឲ្យទៅរស់នៅភ្នំជ្រាប់និងបន្តដំណើរទៅដល់ខេត្តបាត់ដំបងដែលជាកន្លែងលត់ដំយ៉ាងខ្លាំងមួយសម្រាប់គ្រួសារគាត់ ។ គាត់ត្រូវធ្វើស្រែចម្ការស្ទើរគ្មានពេលសម្រាក ហើយគ្មានអាហារហូបគ្រប់គ្រាន់ទៀត ។ ថ្ងៃមួយពេលគាត់ឮដំណឹងពីអ្នកជិតខាងគាត់ប្រាប់ថាឪពុករបស់គាត់ត្រូវអង្គការហៅទៅរៀនសូត្រជាមួយកងចល័តបុរសជាច្រើននាក់ ធ្វើឲ្យគាត់ពិបាកចិត្តជាខ្លាំងព្រោះគិតថាឪពុករបស់គាត់ប្រាកដជាស្លាប់មិនខាន ។ រយៈពេលពីរសប្តាហ៍ក្រោយមកទើបគាត់ឃើញឪពុករបស់គាត់ត្រឡប់មកវិញ ចំណែកអ្នកផ្សេងទៀតពុំមានអ្នកណាម្នាក់បានរួចរស់ជីវិតឡើយ ។ គាត់បែរជាឃើញឪពុកគាត់មានទឹកមុខក្រៀមក្រំ មិនសប្បាយចិត្តទៅវិញ ហើយនិយាយនូវពាក្យដដែលថា «បដិវត្តន៍ចាស់ផ្លាស់សម្ពាយថ្មីហើយ» ។ រយៈពេលពីរសប្តាហ៍ក្រោយមក ឪពុកគាត់ក៏បាត់បង់ជីវិតដោយគ្មានមូលហេតុអ្វីទាំងអស់ ។ គាត់គិតថាការស្លាប់នេះប្រហែលជាដោយសារតែគ្មានអាហារហូបគ្រប់គ្រាន់និងគ្រាំគ្រាក្នុងខ្លួនពេលដែលគាត់ត្រូវអង្គការហៅទៅរៀនសូត្រ ។ ក្រោយមកប្អូនស្រីរបស់គាត់ឈ្មោះ វតី និងប្អូនប្រុស បុណ្ណាវែត ក៏ត្រូវខ្មែរក្រហមចាប់វាយធ្វើបាបដោយសារតែលួចរបស់របរអង្គការយកមកហូប ។ មិនយូរប៉ុន្មានប្អូនទាំងពីររបស់គាត់ក៏ធ្លាក់ខ្លួនឈឺរហូតដល់ស្លាប់ដែរ ។

អ្វីៗដែលអ៊ំស្រីព្យាយាមរំឭកប្រាប់ គឺដើម្បីឲ្យក្មេងជំនាន់ក្រោយបានដឹងរឿងរ៉ាវដែលគាត់បានឆ្លងកាត់និងចង់ចូលរួមចំណែកក្នុងការថែរក្សាប្រវត្តិសាស្ត្រផ្ទាល់មាត់ដូចដែលប្រជាជនទូទាំងប្រទេសធ្លាប់បានឆ្លងកាត់សម័យខ្មែរក្រហមដែរ ។ ទោះបីជារបបនេះធ្វើឲ្យអ៊ំស្រីបាត់បង់ឪពុកនិងប្អូនជាទីស្រឡាញ់ក៏ដោយ ក៏គាត់គ្មានគំនិតមិនចង់សងសឹកទេ បែរជាលើកទ្រឹស្តីរបស់ព្រះពុទ្ធអង្គមកបញ្ជាក់ថា «ពៀររម្ងាប់ដោយការមិនចងពៀរទៅវិញ» ។ អ្នកដែលបានចូលរួមក្នុងការដាក់ពាក្យបណ្តឹងក្នុងនាមជាជនរងគ្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅតែចងចាំនិងមិនអាចបំភ្លេចបាននូវអ្វីៗដែលរបបខ្មែរក្រហមបានបន្សល់ទុក ទោះបីជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកំពុងតែដំណើរការស៊ើបអង្កេតនិងធ្វើការចោទប្រកាន់ចំពោះមេដឹកនាំធំៗទាំងនោះក៏ដោយ ។ **ហ៊ិន សុធានី**

# ផលប៉ះពាល់ក្រោយរបបខ្មែរក្រហម

ក្រោមភ្លៀងរលឹមស្រិចៗ ស្រាប់តែមានស្ត្រីវ័យចំណាស់ខ្មែរអ៊ីស្លាមម្នាក់ឈ្មោះ ស្មះ ជីប បានដើរសំដៅមកក្រុមការងាររបស់ខ្ញុំ ខណៈពេលដែលខ្ញុំកំពុងតែនិយាយប្រាប់អំពីសិទ្ធិចូលរួមរបស់ជនរងគ្រោះក្នុងដំណើរការកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទៅស្ត្រីខ្មែរឥស្លាមម្នាក់ទៀតដែលចង់ចូលរួមដាក់ពាក្យបណ្តឹងជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោយសារកូនប្រុសរបស់គាត់បានត្រូវសម្លាប់នៅគុកទួលស្លែងកាលពីក្នុងរបបខ្មែរក្រហម ។ ជីប ជាប្រជាជនចំណូលថ្មីដែលបានចាកចេញពីស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ មករស់នៅភូមិព្រែកបាក់ ឃុំព្រែកបាក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។

ពេលខ្ញុំទៅដល់ផ្ទះរបស់ ជីប គាត់បានសម្តែងទឹកមុខត្រេកអរណាស់និងស្វាគមន៍ចំពោះវត្តមានក្រុមការងាររបស់ខ្ញុំ ។ បន្ទាប់មកខ្ញុំក៏ក្រឡេកឃើញបុរសម្នាក់ដែលមានអាយុប្រហែល៤៥ឆ្នាំកំពុងតែដេកឱបដៃ ចង្កេះជាប់ច្រវាក់ភ្ជាប់ទៅនឹងរនូតផ្ទះ នៅចំកណ្តាលផ្ទះ និងបុរសចំណាស់ម្នាក់ទៀតអាយុប្រហែលជាង៧០ឆ្នាំកំពុងសម្រាកនៅលើគ្រែក្បែរនោះ ។ ពេលនោះ ខ្ញុំមានអារម្មណ៍ភ្ញាក់ផ្អើលចំពោះទិដ្ឋភាពបែបនេះណាស់ ។ បន្តិចក្រោយមក ទើបខ្ញុំដឹងថាបុរសនោះគឺជាកូនប្រុសទី២របស់គាត់ឈ្មោះ ម៉ម អែល ដែលមានជំងឺវិកលចរិត ។ អែល បានបើកភ្នែកសម្លឹងមករកខ្ញុំទាំងទឹកមុខស្លេកស្លាំង ។ ខ្ញុំឃើញរនាបពីរបន្ទះត្រូវបានចោះប្រហោងដើម្បីសម្រួលដល់ការបន្ទោរបង់របស់ អែល ។ ស្មះ ជីប និយាយប្រាប់ថា អែល ក្លាយជាមនុស្សវិកលចរិតតាំងពីរបបខ្មែរក្រហមដួលរលំទៅ ។ សព្វថ្ងៃនេះ គាត់ព្រមទាំងប្តីជាអ្នកមើលថែ អែល ដោយផ្ទាល់ ។

ស្ថិតក្នុងជីវភាពទីទ័លក្រ ទោះបីជាគ្រួសារគាត់រវល់ប្រកបរបរធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិតក៏ដោយ ក៏ពួកគាត់មិនដែលបំភ្លេចការប្រតិបត្តិតាមគន្លងសាសនាអ៊ីស្លាមដែរ ។ អែល មានសភាពស្លេកស្លាំងហាក់ដូចជាអ្នកទោសជំនាន់ខ្មែរក្រហមអ៊ីចឹង ។ យូរៗម្តង អែល បានប្រែខ្លួនម្តងទៅឆ្វេង ម្តងទៅស្តាំ នៅលើរនាបតូចៗនៃផ្ទះបុរាណមួយដែលមានអាយុរាប់សិបឆ្នាំមកហើយ ។ ជួនកាល អែល សម្រាន្តលក់ ជួនកាលគាត់ងាកមើលមកខ្ញុំនិងម្តាយឪពុកគាត់ដែលកំពុងសន្ទនាគ្នា ។

ជីប បានរៀបរាប់ថា នៅខែមករា ឆ្នាំ១៩៧៩ អែល បានមកជួបជុំឪពុកម្តាយនៅស្រុកកំណើតវិញ ។ ប៉ុន្តែ ការជួបលើកនេះមិនដូចពីពេលមុនទេ ដោយគាត់បានក្លាយជាមនុស្សដែលមានលក្ខណៈខុសប្លែកពីមុនទាំងស្រុង ។ ជានិច្ចកាល អែល តែងតែធ្វើឲ្យអ្នកភូមិ អ្នកស្រុកខ្លាចញញើតគ្រប់ៗគ្នាព្រោះតែអាកប្បកិរិយារបស់ អែល បានផ្លាស់ប្តូរជារៀងរាល់ថ្ងៃ ។ ដោយមើលឃើញសភាពជំងឺរបស់ អែល កាន់តែធ្ងន់ធ្ងរទៅៗ ឪពុកម្តាយគាត់ក៏សម្រេចចិត្តនាំយកគាត់ទៅព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តកំពង់ធំ ។ លទ្ធផលនៃការវិភាគជំងឺរបស់គ្រូពេទ្យបានឲ្យដឹងថា អែល មានជំងឺផ្លូវចិត្តធ្ងន់ធ្ងរនិងតម្រូវឲ្យលេបថ្នាំជារៀងរាល់ថ្ងៃ ។ ដូច្នេះ ជីប បានសន្សំលុយដើម្បីទិញថ្នាំតាមវេជ្ជបញ្ជាគ្រូពេទ្យមកឲ្យកូនរបស់គាត់លេប ។ ប៉ុន្តែ ទោះជាខំព្យាយាមយ៉ាងណាក៏ដោយ ក៏ជំងឺរបស់ អែល នៅតែមានសភាពដដែលមិនធូរស្បើយឡើយ ។ និយាយបណ្តើរ ជីប ទាញយកបង្កាន់ដៃបង់ប្រាក់ចំនួនពីរសន្លឹកចេញពីថង់ផ្លាស្ទិកមួយដែលមានដាក់រូបថតជាច្រើនសន្លឹកនិងអត្តសញ្ញាណប័ណ្ណ ព្រមទាំងប័ណ្ណបោះឆ្នោតមកឲ្យខ្ញុំពិនិត្យមើល ។ បង្កាន់ដៃបង់ប្រាក់នោះពុំមានបញ្ជាក់ពីកាលបរិច្ឆេទច្បាស់លាស់ឡើយ ប៉ុន្តែ គ្រូពេទ្យបានសរសេរយ៉ាងច្បាស់នៅលើបង្កាន់ដៃទាំងពីរនោះថា «ផ្នែកជំងឺផ្លូវចិត្ត» ។

ជីប បានរៀបរាប់ថា ក្រោយមកគ្រួសារគាត់ក៏សម្រេចចិត្តចាកចេញពីស្រុកកំណើតនៅ ឃុំជ័យ ស្រុកកំពង់ ស្វាយ ខេត្តកំពង់ធំ មករស់នៅឃុំព្រែកបាក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាមវិញ ។ នៅទីនេះ គាត់លែងនាំ អែល ទៅព្យាបាលទៀតហើយ

ព្រោះគាត់ពុំមានលុយកាក់គ្រប់គ្រាន់ក្នុងការស្វែងរកគ្រូពេទ្យមកព្យាបាល និងម្យ៉ាងដោយពុំមានសង្ឃឹមថានឹងអាចព្យាបាលជាផង ។ សព្វថ្ងៃនេះ អែល មិនបានទទួលការព្យាបាលពីគ្រូពេទ្យណាម្នាក់ឡើយ ។

សកម្មភាពឡូឡានិងការរអ៊ូរទាំដដែលៗរបស់ អែល បានធ្វើឲ្យអ្នកភូមិលែងចាប់អារម្មណ៍ទៅហើយ ។ ក្មេងៗជំនាន់ក្រោយក្នុងភូមិបានចាត់ទុកសកម្មភាពនេះថាជាការរវើរវាយគ្មានការពិត ។ ទាក់ទងនឹងរឿងនេះ ម្តាយរបស់ អែល ប្រាប់ថា អ្វីដែល អែល បាននិយាយអាចជាការពិតដែលកើតមានឡើងនៅក្នុងរបបខ្មែរក្រហម ។ ឪពុករបស់ អែល បានបញ្ជាក់ថា ពេលដែលជំងឺធ្វើទុក្ខម្តងៗ អែល តែងតែស្រែកដេរ ហើយចាត់ទុកអ្នកភូមិថាជាកម្មាភិបាលខ្មែរក្រហមដែលបានវាយធ្វើបាបខ្លួន និងបានសម្លាប់សាច់ញាតិរបស់ខ្លួន ។ «ជួនកាលវា (អែល) ទាញយកចបកាប់ ឬដំបងដេញវាយគេឯងគ្រប់គ្នា ។ ជួនកាលទៀត វាបានរត់ពួនព្រោះខ្លាចគេប្រើឲ្យធ្វើការធ្ងន់ៗ» ។ និយាយដល់ត្រឹមនេះ ជីប ដកដង្ហើមធំ ព្រមទាំងនិយាយថា គាត់មានការលំបាកណាស់ក្នុងការមើលទិដ្ឋភាពបែបនេះស្ទើរតែរៀងរាល់ថ្ងៃ ។ «កូនខ្ញុំវាមិនដែលអីចឹងទេពីមុនមក ប៉ុន្តែនៅពេលដែលវាត្រឡប់មកពីលើកទំនប់និងជីកប្រឡាយនៅបញ្ញាជី ស្រាប់តែវាក្លាយទៅជាមនុស្សបែបនេះរហូតមក» ។ ជីប បាននិយាយបន្ទោសយ៉ាងច្រើនទៅលើរបបខ្មែរក្រហមដែលបានធ្វើឲ្យគ្រួសារគាត់ជួបប្រទះនូវការបាត់បង់កូនប្រុសច្បងនិងធ្វើឲ្យកូនប្រុសទី២របស់គាត់កើតមានជំងឺផ្លូវចិត្តអស់មួយជីវិតបែបនេះ ។

នៅឆ្នាំ១៩៧៦ អែល ត្រូវបានបំបែកចេញពីឪពុកម្តាយឲ្យទៅធ្វើការនៅក្នុងកងយុវជននិងយុវនារី ។ ក្រោយមក អែល បានប្រាប់ដំណឹងមកឪពុកម្តាយថា គាត់ត្រូវអង្គការបញ្ជូនឲ្យទៅលើកទំនប់នៅ «បញ្ញាជី» ដែលមានទីតាំងស្ថិតនៅក្នុងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។ តាំងពីពេលនោះមក អែល បាត់ដំណឹងរហូត ។ នៅឆ្នាំ១៩៧៩ ទើបឃើញ អែល ត្រឡប់មកផ្ទះវិញ ។ ជីប បានប្រាប់ថា «គាត់និងប្តីរីករាយណាស់ចំពោះការជួបជុំគ្នាឡើងវិញ ប៉ុន្តែគាត់ទាំងពីរនាក់មិននឹកស្មានដល់ថាត្រូវប្រឈមមុខនឹងទុក្ខសោកថ្មីមួយទៀតសោះ ។ នោះគឺជំងឺផ្លូវចិត្តដែលកើតមានមកលើកូនប្រុសទី២របស់គាត់» ។ ជីប និយាយថា អែល មិនបានរៀបរាប់ប្រាប់គាត់អំពីទុក្ខលំបាករបស់ខ្លួនក្នុងរបបខ្មែរក្រហមឡើយ ។ ប៉ុន្តែ ពួកគាត់អាចស្មានដឹងថា អែល ពិតជាបានជួបប្រទះនូវហេតុការណ៍ខ្ក្រិដ្ឋជាច្រើនតាមរយៈការផ្លាស់ប្តូរអត្តចរិតនិងការនិយាយដោយមិនដឹងខ្លួននូវសកម្មភាពដែលធ្លាប់កើតមានចំពោះខ្លួនតាមបែបអ្នកដែលកើតមានជំងឺផ្លូវចិត្ត ។

រយៈពេលជិត៣០ឆ្នាំកន្លងមកហើយ ជីប និងប្តីមានសង្ឃឹមតិចតួចណាស់ថានឹងអាចរកយុត្តិធម៌ឲ្យកូនប្រុសទាំងពីររបស់គាត់បាន ។ ប៉ុន្តែនៅពេលថ្មីៗនេះ គាត់ហាក់មានសង្ឃឹមច្រើនឡើងវិញក្នុងការផ្សះផ្សាផ្លូវចិត្តរបស់គាត់តាមរយៈដំណឹងតត្លា ក៏ដូចជាធ្លាប់បានស្តាប់វិទ្យុនិងមើលទូរទស្សន៍អំពីការផ្សព្វផ្សាយពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរ ។ កាលពីដើមឆ្នាំ២០០៨ ជីប ធ្លាប់បានស៊ើបសួរម្តងរួចមកហើយអំពី «ទម្រង់បែបបទជនរងគ្រោះ» ឬ «ពាក្យបណ្តឹង» ដែលចេញដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីប្តឹងពីទុក្ខលំបាករបស់គាត់ ។ ប៉ុន្តែការខិតខំនេះមិនបានលទ្ធផលឡើយ ។ «ខ្ញុំចង់ទៅភ្នំពេញដើម្បីស្វែងរកពាក្យបណ្តឹងនេះ ប៉ុន្តែខ្ញុំមិនបានទៅ ព្រោះគ្មានអ្នកមើលថែកូន ។ ប៉ុន្តែពេលនេះ ខ្ញុំមានឱកាសប្តឹងទៅតុលាការដោយមិនបាច់ចំណាយពេលវេលាច្រើននិងលុយកាក់ឡើយ» ។

នៅពេលខ្ញុំបានជួយបំពេញពាក្យបណ្តឹងឲ្យ ស្មះ ជីប គាត់គ្មានអារម្មណ៍ភ័យខ្លាចនឹងការប្តឹងនេះទេ ព្រមទាំងមិនស្នើសុំឲ្យមានវិធានការការពារខ្លួនសម្រាប់គាត់ឡើយ ។ ប៉ុន្តែ គាត់បានស្នើសុំឲ្យមានមេធាវីសម្រាប់គាត់ក្នុងការនិយាយជំនួសគាត់ក្នុងពេលមានសវនាការម្តងៗ ។ លើសពីនេះទៀត ជីប បានស្នើសុំឲ្យមានការជួយជ្រោមជ្រែងក្នុងការព្យាបាលកូនរបស់គាត់និងសម្រួលរាល់ការធ្វើដំណើរទៅនិងមកភ្នំពេញតាមការអញ្ជើញរបស់តុលាការ ។ «ខ្ញុំហាក់ដូចជាកើតម្តងទៀត ពេលដែលមានក្មួយជួយធ្វើពាក្យបណ្តឹងនេះផ្ញើទៅតុលាការ ព្រោះអ្វីដែលខ្ញុំទន្ទឹងរង់ចាំអស់រយៈពេលយ៉ាងយូរនោះ ឥឡូវនេះបានមកដល់ហើយ» ។

**ផេង ពង្សរ៉ាស៊ី**

# តួនាទីរបស់សហគមន៍ក្នុងការផ្សព្វផ្សាយព័ត៌មានអំពីសាលាក្តីខ្មែរក្រហម

***តួនាទីរបស់សហគមន៍ក្នុងការផ្សព្វផ្សាយព័ត៌មានអំពីសាលាក្តីខ្មែរក្រហម***

*ប្រវត្តិសង្ខេបរបស់គម្រោងឯកសាររស់*

គម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាមានកម្មវិធីអញ្ជើញតំណាងសហគមន៍មកពីគ្រប់ខេត្ត-ក្រុងទូទាំងប្រទេស ដើម្បីមកចូលរួមក្នុងដំណើរការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលហៅជាទូទៅថាតុលាការខ្មែរក្រហម ។ ក្រោយពីបញ្ចប់កិច្ចការនៅដំណាក់កាលទីមួយរបស់ខ្លួននៅពាក់កណ្តាលឆ្នាំ២០០៧ ក្រុមការងាររបស់គម្រោងឯកសាររស់បានចាប់ផ្តើមដំណើរការវគ្គទីពីរបន្តទៀត នៅខែវិច្ឆិកា ឆ្នាំ២០០៧ ដោយបានអញ្ជើញតំណាងសហគមន៍មកពីខេត្តផ្សេងៗដើម្បីមកចូលរួមស្តាប់សវនាការស្តីពីបណ្តឹងឧទ្ធរណ៍សុំនៅក្រៅឃុំរបស់កាំង ហ្គេកអ៊ាវ (ហៅ ឌុច) ដែលជាបណ្តឹងដំបូងរបស់សាលាក្តីនេះ ។ ដើម្បីឲ្យប្រជាជននៅតាមសហគមន៍ទទួលបានព័ត៌មានដោយផ្ទាល់អំពីសាលាក្តីនេះ ក្រុមការងាររបស់គម្រោងឯកសាររស់នឹងអញ្ជើញប្រធានឃុំនិងអ្នកភូមិចំនួន៥០នាក់ មកសង្កេតនិងទស្សនាសាលាក្តីដោយផ្ទាល់ ព្រមទាំងអាចទទួលយកចំណេះដឹងអំពីនីតិវិធីក្នុងពេលសវនាការ និងដឹងពីប្រវត្តិរូបរបស់ជនសង្ស័យនៅគ្រប់សវនាការទៀតផង ។ មកដល់ពេលបច្ចុប្បន្នគម្រោងបានអញ្ជើញអ្នកភូមិមកស្តាប់បណ្តឹងឧទ្ធរណ៍សុំនៅក្រៅឃុំរបស់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមចំនួន៤រូបរួចមកហើយ ។

ដើម្បីសម្រេចគោលដៅរបស់ខ្លួនក្នុងការផ្សព្វផ្សាយព័ត៌មានទៅដល់សហគមន៍ឲ្យកាន់តែមានភាពទូលំទូលាយ ក្រុមគម្រោងកំពុងធ្វើការដើម្បីបង្កើតទំនាក់ទំនងនៅក្នុងសហគមន៍ ។ អ្នកភូមិដែលធ្លាប់បានចូលរួមស្តាប់សវនាការត្រូវបានអញ្ជើញឲ្យចូលរួមកម្មវិធីប្រជុំពិភាក្សានៅក្នុងភូមិ ដើម្បីចែករំលែកការយល់ដឹងរបស់ខ្លួនទៅដល់សហគមន៍ ។ ចំពោះឃុំណាដែលមិនទាន់មានតំណាងរបស់ខ្លួនមកចូលរួមក្នុងសវនាការសាធារណៈ គម្រោងឯកសាររស់នឹងបញ្ចាំងខ្សែភាពយន្តដែលទើបនឹងផលិតក្នុងពេលខាងមុខដើម្បីជាជំនួយក្នុងការចាប់ផ្តើមការពិភាក្សា ។ តាមរយៈមធ្យោបាយនេះ គម្រោងរំពឹងថានឹងបង្កើនកម្រិតនៃការយល់ដឹងអំពីតុលាការខ្មែរក្រហមក្នុងចំណោមប្រជាជននៅតាមមូលដ្ឋាន ។ ដើម្បីសម្រេចគោលដៅនេះ នៅខែសីហា ឆ្នាំ២០០៨ ក្រុមការងាររបស់គម្រោងឯកសាររស់បានរៀបចំការប្រជុំពិភាក្សាថ្នាក់ភូមិលើកដំបូងរបស់ខ្លួន ដើម្បីឲ្យតំណាងសហគមន៍នៅឃុំត្រពាំងសាលាខាងកើត ខេត្តកំពតមានឱកាសចែករំលែកព័ត៌មានអំពីដំណើរការតុលាការខ្មែរក្រហមជាមួយប្រជាជននៅតាម


អ្នកភូមិកំពុងនិយាយរៀបរាប់ពីបទពិសោធន៍របស់ខ្លួនដែលធ្លាប់ចូលរួមសវនាការ

សហគមន៍ ។ សកម្មភាពនៃកិច្ចប្រជុំពិភាក្សានេះ នឹងមានរៀបរាប់ដូចខាងក្រោមនេះ ៖

នៅក្នុងបរិវេណធំទូលាយរបស់សាលាឃុំត្រពាំងសាលាខាងកើត ក្នុងស្រុកបន្ទាយមាស ខេត្តកំពត ដែលស្ថិតនៅចម្ងាយ ១០គីឡូម៉ែត្រពីផ្លូវជាតិឆ្ពោះទៅស្រុកកំពង់ត្រាច ប្រជាជន៦០នាក់មកពីភូមិទាំង៥ នៃឃុំត្រពាំងសាលាខាងកើត បានមកចូលរួមក្នុងការប្រជុំពិភាក្សាថ្នាក់ភូមិដែលរៀបចំនិងសម្របសម្រួលដោយគម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ការប្រជុំនេះជាការពិភាក្សាថ្នាក់ភូមិលើកដំបូងអំពីដំណើរការរបស់សាលាក្តីខ្មែរក្រហមគិតចាប់ពីអង្គបុរេជំនុំជម្រះរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបើកសវនាការជំនុំជម្រះដំបូងរបស់ខ្លួននៅខែវិច្ឆិកា ឆ្នាំ២០០៧ ។

ការប្រជុំពិភាក្សានៅថ្ងៃទី២៦ ខែសីហានេះ បានផ្តល់នូវឱកាសដ៏មានតម្លៃសម្រាប់តំណាងឃុំដែលបានទៅសង្កេតនិងទស្សនាសវនាការនៃអង្គបុរេជំនុំជម្រះរបស់ អៀង សារី កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ ដោយផ្ទាល់ដើម្បីចែករំលែកព័ត៌មានជាមួយអ្នកជិតខាង ក៏ដូចជាសហគមន៍ទាំងមូលរបស់ខ្លួន ។ ការពិភាក្សានេះមានបំណងលើកទឹកចិត្តដល់អ្នកចូលរួមឲ្យបញ្ចេញមតិយោបល់ចោទជាសំណួរនិងចែករំលែកបទពិសោធន៍ដែលខ្លួនធ្លាប់ជួបប្រទះនៅសម័យខ្មែរក្រហម ។ ក្នុងការប្រជុំរយៈពេលពីរម៉ោងនេះប្រធានបទដែលទាក់ទងនឹងសវនាការរបស់ អៀង សារី និងបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នកចូលរួមត្រូវបានលើកមកធ្វើការពិភាក្សា រួចបញ្ចប់ដោយវគ្គសំណួរនិងចម្លើយ ។ ក្រោយពីការប្រជុំនេះបានបញ្ចប់ ក្រុមការងាររបស់គម្រោងឯកសាររស់បានចំណាយពេលពេញមួយរសៀលនិងមួយថ្ងៃបន្ទាប់ទៀត ដើម្បីធ្វើការសម្ភាសជាមួយអ្នកចូលរួម ដោយថតវីដេអូដើម្បីប្រមូលរឿងរ៉ាវផ្ទាល់ខ្លួន មតិយោបល់ និងប្រតិកម្មនានាទាក់ទងនឹងការប្រជុំពិភាក្សា និងតុលាការខ្មែរក្រហម ។



ដោយមានការសហការពីលោក ណុប អួច ប្រធានឃុំត្រពាំងសាលាខាងកើត ក្រុមការងារមានលទ្ធភាពអញ្ជើញប្រជាជនចំនួន៥៦នាក់មកពីភូមិពោន ភូមិលៀប ភូមិខ្សើម ភូមិទីតស្តេច និងភូមិតាង៉ើត មកចូលរួមនៅក្នុងកម្មវិធីនេះ ។ ក្នុងចំណោមអ្នកទាំងអស់ មានអ្នកភូមិចំនួន១០នាក់ដែលបានទៅចូលរួមសវនាការអង្គបុរេជំនុំជម្រះរបស់ អៀង សារី បានរៀបរាប់ពីអ្វីដែលខ្លួនបានអង្កេតដោយផ្ទាល់នៅក្នុងសវនាការប្រាប់ទៅអង្គប្រជុំ ។ ដោយមានការជួយជ្រោមជ្រែងពីសំណាក់ស្មៀនឃុំ ក្រុមការងារគម្រោងមានលទ្ធភាពប្រមូលឈ្មោះនិងអាសយដ្ឋានរបស់អ្នកចូលរួមទាំងអស់ ដើម្បីទំនាក់ទំនងនៅថ្ងៃក្រោយទៀត ។ ជាមួយគ្នានោះដែរ ទស្សនាវដ្តីស្វែងរកការពិតចំនួន៨០ក្បាលត្រូវបានចែកជូនដល់អ្នកចូលរួមនិង២០ក្បាលទៀតត្រូវបានរក្សាទុកនៅនឹងសាលាឃុំ ។ ការប្រជុំពិភាក្សានេះត្រូវបានថតជាខ្សែភាពយន្តដោយក្រុមថតកុនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីរក្សាទុកជាឯកសារនិងផលិតជាខ្សែភាពយន្តឯកសារខ្នាតខ្លី ។

អ្នកចូលរួមក្នុងសវនាការអង្គបុរេជំនុំជម្រះ អៀង សារី បានចែករំលែកការយល់ដឹងទៅដល់សហគមន៍របស់ខ្លួន ក្រោយពី

ក្រុមការងាររៀបចំគម្រោងឯកសាររស់បានណែនាំអំពីកិច្ចការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានិងពន្យល់ពីគោលបំណងនៃការប្រជុំពិភាក្សានេះ  តំណាងសហគមន៍ទាំង១០នាក់ត្រូវបានអញ្ជើញឲ្យពិពណ៌នាអំពីអ្វីដែលខ្លួនបានរៀនសូត្រពីដំណើរទស្សនកិច្ចនិងពីសវនាការ អៀង សារី ប្រាប់ទៅដល់អ្នកចូលរួមទាំងអស់ ។ តំណាងសហគមន៍ទាំងអស់បានផ្លាស់ប្តូរវេនគ្នាមានប្រសាសន៍ពីការយល់ដឹងរបស់ខ្លួនអំពីតុលាការខ្មែរក្រហម និងដំណើរទស្សនកិច្ច រួមមានប្រវត្តិផ្ទាល់ខ្លួន និងប្រវត្តិការងាររបស់ អៀង សារី ការរៀនសូត្រពីដំណើរការរបស់អង្គជំនុំជម្រះ  ការអង្កេតដោយផ្ទាល់ចំពោះសាលាក្តី  អារម្មណ៍របស់ខ្លួនចំពោះជនជាប់ចោទ  ព្រមទាំងបញ្ហាសំខាន់ៗមួយចំនួនដែលបានពិភាក្សានៅក្នុងសវនាការ ។

លោក  សំ  លីមហាន  ជាអ្នកដឹកនាំក្រុមតំណាងសហគមន៍ទាំង១០នាក់ដែលបានធ្វើដំណើរមកភ្នំពេញដើម្បីអង្កេតមើលសវនាការ  អៀង  សារី  បានចាប់ផ្តើមពិពណ៌នាដោយសង្ខេបពីប្រវត្តិរូបរបស់ អៀង សារី ។ បន្ទាប់មក លីមហាន បានរៀបរាប់ពីភ័ព្វសំណាងរបស់ខ្លួនដែលមានឱកាសចូលរួមអង្កេតនៅក្នុងបន្ទប់សវនាការ  បើគិតពីភាពតឹងរ៉ឹងផ្នែកសន្តិសុខនៅច្រកទ្វារចូលរបស់សាលាក្តី ។  លីមហាន បានគូសបញ្ជាក់ពីការយកចិត្តទុកដាក់របស់អង្គជំនុំជម្រះអំពីសុវត្ថិភាពរបស់អ្នកទស្សនានិងបុគ្គលដទៃទៀតនៅក្នុងអគារជំនុំជម្រះ ។  បន្ទាប់មក  លីមហាន  និង  តំណាងសហគមន៍៩នាក់ទៀត  បន្តរៀបរាប់ពីទិដ្ឋភាពនៅក្នុងបន្ទប់សវនាការរួមមានកន្លែងដែលជនសង្ស័យ  ចៅក្រម  មេធាវី  និង  អ្នកអង្កេតការណ៍អង្គុយនិងរបៀបរៀបចំនៅក្នុងសាលាក្តី ។

តំណាងសហគមន៍ខ្លះបានរៀបរាប់ពីឧបសគ្គក្នុងការស្វែងយល់ពីភាសាដែលបានប្រើប្រាស់នៅក្នុងសវនាការ  ព្រមទាំងឧបករណ៍ប្រើប្រាស់សម្រាប់ស្តាប់ការបកប្រែភាសា ។  ដូចដែលលោក  ង៉ែត  ផាត  គូសបញ្ជាក់អំពីភាពស្មុគស្មាញនៃភាសាដែលបានប្រើប្រាស់នាក្នុងសវនាការធ្វើឲ្យការបកប្រែមានការលំបាកយល់ បើទោះជាភាសាទាំងបីដែលបានប្រើប្រាស់នៅក្នុងតុលាការរួមមានភាសាខ្មែរ អង់គ្លេស  និងបារាំងអាចឲ្យអ្នកមានវត្តមាននៅក្នុងតុលាការរួមទាំងបុគ្គលិកបរទេសអាចតាមដានពីដំណើរការនៃអង្គសវនាការក៏ដោយ ។   អ្នកខ្លះទៀតពន្យល់ពីរូបរាងទន់ខ្សោយរបស់  អៀង  សារី  និង  បង្ហាញពីការខកចិត្តដែលសវនាការបានពន្យារការកាត់ក្តីរយៈពេលមួយថ្ងៃផ្អែកទៅលើមូលហេតុសុខភាពរបស់  អៀង  សារី ។  ទាំងតំណាងសហគមន៍  និងអ្នកចូលរួមទាំងអស់បានសម្តែងក្តីបារម្ភចំពោះដំណើរការដ៏យឺតយ៉ាវរបស់សាលាក្តីនេះនិងចំពោះជនជាប់សង្ស័យដែលមានអាយុកាន់តែច្រើននិងមានជំងឺ ។  លីមហាន បញ្ជាក់ថា តាមការសង្កេតរបស់គាត់ ដំណើរការនៃការអង្កេតតុលាការពិតជាត្រូវចំណាយពេលច្រើន ។  ជាឧទាហរណ៍ លីមហាន បានលើកយកអត្ថបទមួយនៅក្នុងទស្សនាវដ្តីស្វែងរកការពិតមកពិភាក្សាពីដំណើរការនៃការបកប្រែឯកសារនៅតុលាការខ្មែរក្រហម ។

ការប្រជុំនេះបន្តការពិភាក្សា  ដោយផ្តោតទៅលើបញ្ហាយុត្តាធិការដែលបានលើកឡើងនៅក្នុងសវនាការដូចជា  ការកាត់ទោសពីរដងនិងការលើកលែងទោស ។ លោក  អៀង  ឆៅ  បានពន្យល់ថា  អៀង  សារី  ធ្លាប់ត្រូវកាត់ទោសប្រហារជីវិតដោយកំបាំងមុខពីបទប្រល័យពូជសាសន៍មួងរួចហើយដោយតុលាការប្រជាជនបដិវត្តន៍កម្ពុជា ។  ប៉ុន្តែបើយោងតាមការយល់ដឹងរបស់គាត់  សាលាក្តីកូនកាត់នេះគួរតែអាចចោទប្រកាន់  អៀង  សារី ពីបទល្មើសផ្សេងៗទៀត ។  ការពន្យល់យ៉ាងច្បាស់លាស់របស់ឆៅ  បានរំសាយមន្ទិលសង្ស័យរបស់អ្នកភូមិពីលទ្ធភាពក្នុងការបញ្ជូនជនសង្ស័យរូបនេះទៅកាត់សេចក្តី ។  បន្ទាប់មក លីមហាន បានរៀបរាប់ពីមូលហេតុរបស់តុលាការក្នុងការដាក់ជនសង្ស័យឲ្យនៅជាប់ឃុំបណ្តោះអាសន្ននិងការអះអាងរបស់មេធាវីការពារជនជាប់ចោទសុំឲ្យមានការដោះលែងឲ្យនៅក្រៅឃុំ ។  គាត់ពន្យល់ថាសុវត្ថិភាពផ្ទាល់ខ្លួនរបស់  អៀង  សារី  ការធានាវត្តមានរបស់គាត់នៅចំពោះមុខតុលាការ  សណ្តាប់ធ្នាប់សាធារណៈនិងការភៀសខ្លួនចេញពីប្រទេសគឺជាការបារម្ភដ៏សំខាន់បំផុតរបស់តុលាការ នៅពេលដែលបញ្ហាសុខភាពរបស់  អៀង  សារី  គឺជាអំណះអំណាងចម្បងដែលមេធាវីការពារក្តីប្រើប្រាស់ដើម្បីសុំឲ្យមានការដោះលែង ។

ការប្រជុំនេះបន្តរយៈពេលមួយម៉ោងទៀត   ដើម្បីផ្តល់ឱកាសឲ្យអ្នកចូលរួមសួរសំណួរ  បញ្ចេញយោបល់  និងតំណាងសហគមន៍ឆ្លើយសំណួរ ។  សំណួរចម្លើយភាគច្រើនផ្តោតសំខាន់ទៅលើការចំណាយពេលរបស់សវនាការ  និងដំណើរយឺតយ៉ាវ

របស់តុលាការខ្មែរក្រហម ។ សំណួរខ្លះទៀតសង្កត់ធ្ងន់ទៅលើការស្លាប់របស់ជនសង្ស័យនិងបទឧក្រិដ្ឋដែលជនសង្ស័យត្រូវបានចោទប្រកាន់ ។ អ្នកចូលរួមបញ្ចប់វគ្គសំណួរចម្លើយដោយសំណូមពរថា តុលាការនេះនឹងបង្កើនសន្ទុះរបស់ខ្លួន ដើម្បីធានាឲ្យបានភាពយុត្តិធម៌ទាន់ពេលវេលា ។

**អ្នកចូលរួមប្រជុំរៀបរាប់ពីបទពិសោធន៍ផ្ទាល់ខ្លួននៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ**

នៅរសៀលថ្ងៃដដែលនិងថ្ងៃបន្ទាប់ក្រោយពីការប្រជុំចប់ ក្រុមការងារគម្រោងឯកសាររស់បានឆ្លៀតឱកាសប្រមូលរឿងរ៉ាវនិងមតិយោបល់របស់អ្នកចូលរួមប្រជុំ ។ ប្រជាជនមួយចំនួនដែលបានចូលរួមការប្រជុំមានសេចក្តីត្រេកអរដោយបានចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួន និងមតិយោបល់អំពីតុលាការខ្មែរក្រហមជាមួយក្រុមការងារ ។ អ្នកភូមិបីនាក់មកពីភូមិតាង៉ើត និងភូមិលៀបស្ម័គ្រចិត្តរៀបរាប់រឿងរ៉ាវជីវិតឆ្លងកាត់របបខ្មែរក្រហមប្រាប់ដល់ក្រុមការងារយើង ។ ទោះបីជាគាត់រស់នៅក្នុងភូមិស្រុកជាមួយគ្នាក៏ដោយ ប៉ុន្តែសាច់រឿងរបស់គាត់ផ្សេងៗពីគ្នា ។ អ្នកភូមិម្នាក់ធ្លាប់ធ្វើជាទាហានខ្មែរក្រហមនិងធ្លាប់ចេញប្រយុទ្ធពេញមួយរបបកម្ពុជាប្រជាជាធិបតេយ្យ រីឯអ្នកភូមិពីរនាក់ផ្សេងទៀតគឺជាប្រជាជនសាមញ្ញរស់នៅតាមភូមិ ។ ទោះបីជាយ៉ាងនេះក៏ដោយ អ្នកភូមិមានទស្សនៈយោបល់ស្រដៀងគ្នាចំពោះសាលាក្តីខ្មែរក្រហម ។

លោកតា ឆឹង កប មានអាយុ៧៨ឆ្នាំ រស់នៅក្នុងភូមិលៀប ធ្លាប់ធ្វើជាអ្នកនេសាទនៅក្នុងរបបខ្មែរក្រហម ។ គាត់ត្អូញត្អែរពីការលំបាករស់នៅជាមួយរបបអាហារដ៏តិចតួច និងរស់នៅក្នុងភាពភ័យខ្លាច ក្រោមការចោទប្រកាន់ថាជាខ្មាំងរបស់អង្គការ ។ កប រៀបរាប់ពីហេតុការណ៍សម្លាប់មនុស្សដែលគាត់ជួបប្រទះដោយផ្ទាល់ភ្នែកនៅពេលគាត់កំពុងនេសាទត្រីនៅបឹងមួយក្បែរភូមិ ។ គាត់រំឭកថា ឈ្លបខ្មែរក្រហមម្នាក់បានវាយជនរងគ្រោះដោយដំបងឈើ ហើយផ្តាច់ជីវិតដោយរុញទម្លាក់ចូលក្នុងរណ្តៅ ។

តាមបទពិសោធន៍របស់ កប យល់ថានេះជាខ្សែសង្វាក់



អ្នកភូមិកំពុងស្តាប់ការពន្យល់របស់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាអំពីតុលាការខ្មែរក្រហម

បញ្ហារបស់ខ្មែរក្រហម ។ គាត់និយាយថា កម្មាភិបាលខ្មែរក្រហមថ្នាក់ទាបពុំមានអំណាចសម្រាប់អ្នកស្លូតត្រង់ដោយគ្មានបញ្ជាពីថ្នាក់ដឹកនាំជាន់ខ្ពស់នោះទេ ។ កប ដាក់ទម្ងន់ក្នុងការទទួលខុសត្រូវទៅលើមេដឹកនាំកំពូលខ្មែរក្រហម ដោយសំណូមពរថា តុលាការខ្មែរក្រហមនឹងនាំមេដឹកនាំទាំងនោះមកកាត់ទោស ។ គាត់បញ្ជាក់ពីការខកចិត្តចំពោះដំណើរដ៏យឺតយ៉ាវរបស់តុលាការយ៉ាងដូច្នេះថា «ខ្ញុំរង់ចាំមើលដំណើរស្វែងរកយុត្តិធម៌អស់ជាច្រើនឆ្នាំមកហើយ មកដល់ពេលនេះខ្ញុំនៅតែមិនទាន់ឃើញតុលាការនាំយកមេដឹកនាំទាំងនោះមកកាត់ទោសទៀត» ។ ដូចអ្នកផ្តល់បទសម្ភាសន៍មួយចំនួនដែរ កប មានការព្រួយបារម្ភចំពោះអាយុនិងវ័យចំណាស់របស់ជនសង្ស័យដែលកំពុងជាប់ឃុំឃាំង ។

អ្នកស្រី ប្រាក់ សាមុត អាយុ៦៤ឆ្នាំ សព្វថ្ងៃរស់នៅភូមិតាផ្ទើត ពិការជើងនៅក្នុងហេតុការណ៍ទម្លាក់គ្រាប់បែកកាលពីសម័យសង្គ្រាមនៅស្រុកចម្ការលើ ខេត្តកំពង់ចាម នៅពេលគាត់កំពុងដើរតាមប្តីគាត់ទៅធ្វើការនៅចម្ការកៅស៊ូ ។ សាមុត បញ្ចេញកំហឹងរបស់គាត់ទៅលើខ្មែរក្រហមនិងចង់ឲ្យតុលាការប្រជាជនបដិវត្តន៍កម្ពុជាកាត់ទោសមេដឹកនាំទាំងនោះជំនួសតុលាការខ្មែរក្រហមសព្វថ្ងៃ ។ គាត់បានផ្លាស់ទៅរស់នៅភូមិកំណើតនៅឃុំត្រពាំងសាលាខាងកើតវិញ មុនពេលខ្មែរក្រហមចូលមកកាន់កាប់ភូមិរបស់គាត់ទាំងស្រុង ក៏ប៉ុន្តែបងប្អូនប្រុសស្រីរបស់គាត់ពីរនាក់ត្រូវខ្មែរក្រហមស្នើសុំយកទៅបម្រើកងទ័ពដើម្បីវាយរំដោះប្រជាជន ។ ចាប់តាំងពីពេលនោះមក សាមុត មិនដែលឮដំណឹងពីបងប្អូនគាត់ទៀតឡើយ ។ ការឈឺចាប់ក្នុងការបាត់បង់បងប្អូនរបស់គាត់មិនបានបញ្ចប់នៅពេលនោះទេ ។ សោកនាដកម្មបានយាយីគាត់ម្តងទៀតនៅពេលដែលខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងទៅកាន់ភូមិរបស់គាត់ ។ ក្នុងចំណោមប្រជាជនថ្មីទាំងនោះ ក៏មានឪពុកមានិងគ្រួសាររបស់គាត់ផងដែរ ។ ដោយហេតុថា សាមុត មានជាប់ពាក់ព័ន្ធជាមួយប្រជាជនថ្មីមកពីភ្នំពេញ គាត់ត្រូវរស់នៅក្រោមការឃ្លាំមើលពីអង្គការជានិច្ច ។ ដោយមូលហេតុនេះទើបការធ្វើការងារធ្ងន់តែមួយមុខមិនអាចឲ្យ សាមុត ទទួលបានការទុកចិត្តពីអង្គការទេ ថែមទាំងត្រូវលះបង់ទ្រព្យសម្បត្តិផ្ទាល់ខ្លួនយកទៅដាក់នៅសហករណ៍ និងប្រយ័ត្នពាក្យសម្តីមិនហ៊ានរអ៊ូរទាំអ្វីឡើយ ។ ទោះបីជា សាមុត អាចការពារខ្លួនគាត់ឲ្យផុតពីការចោទប្រកាន់នានារបស់ខ្មែរក្រហមក៏ដោយ ក៏គាត់មិនអាចការពារឪពុកមារបស់គាត់បានឡើយ ។ ឪពុកមារបស់ សាមុត ត្រូវខ្មែរក្រហមចោទប្រកាន់ថាខ្ជិលក្នុងការថែទាំសត្វចិញ្ចឹមនិងត្រូវទទួលទណ្ឌកម្មដល់ស្លាប់ដោយគ្មានការតវ៉ាអ្វីទាំងអស់ ។ ហេតុនេះ សាមុត សំណូមពរទៅតុលាការឲ្យរកយុត្តិធម៌ជូនឪពុកមានិងបងប្អូនរបស់គាត់និងសុំកុំឲ្យមានការពន្យារពេលកាត់ទោសតទៅទៀត ។

ក្រោយពីបានចូលរួមប្រជុំ សាមុត អាចយល់ដឹងបានច្រើននិងមានការយកចិត្តទុកដាក់ចំពោះតុលាការខ្មែរក្រហមច្រើនជាងមុន ។ សាមុត រំឮកថា គាត់ធ្លាប់ឮអំពីតុលាការនេះតាមរយៈវិទ្យុក្នុងស្រុក ប៉ុន្តែមិនបានចាប់អារម្មណ៍ចំពោះព័ត៌មាននេះទេ ។ ទោះបីជាយ៉ាងណាក៏ដោយ ការប្រជុំពិភាក្សានេះ អាចធ្វើឲ្យគាត់ដឹងថា ការស្វែងរកយុត្តិធម៌តាមផ្លូវច្បាប់មិនអាចបង្ហាញលទ្ធផលតាមសេចក្តីត្រូវការរបស់ជនរងគ្រោះបានភ្លាមៗទេ ។ ផ្ទុយទៅវិញ យុត្តិធម៌តាមផ្លូវច្បាប់ត្រូវការចាំបាច់នូវការស៊ើបអង្កេតនិងជាដំណើរការដែលត្រូវចំណាយពេលវេលាច្រើន ។

លោក លឿង គុញ អាយុ៥១ឆ្នាំ រស់នៅភូមិលៀប ឃុំត្រពាំងសាលាខាងកើត ធ្វើជាទាហានខ្មែរក្រហមអស់រយៈពេល ១០ឆ្នាំចាប់តាំងពីគាត់ទើបមានអាយុ១២ឆ្នាំ ។ ខ្មែរក្រហមបានបញ្ជូនគាត់ឲ្យទៅប្រយុទ្ធនៅសមរភូមិមុខនៅឆ្នាំ១៩៧២ ហើយត្រឡប់មករួមរស់ជាមួយប្រជាជនវិញនៅឆ្នាំ១៩៧៩ ។ គាត់រៀបរាប់ពីជីវិតរបស់គាត់នៅសមរភូមិមុខ ដោយលើកឡើងថា ក្រៅពីប្រថុយជីវិតប្រយុទ្ធជាមួយកងទ័ពវៀតណាម គាត់មានរបបអាហារនិងជម្រកត្រឹមត្រូវ ។ ដោយហេតុនេះគាត់មិនបានដឹងពីការឈឺចាប់ដែលគ្រួសារនិងអ្នកភូមិរបស់គាត់បានរងគ្រោះទេ ។ គាត់មានចំណាប់អារម្មណ៍ខ្លាំងអំពីតុលាការខ្មែរក្រហម ទើបតែនៅពេលដែលតំណាងសហគមន៍ទាំង១០នាក់យកសៀវភៅទស្សនាវដ្តីស្វែងរកការពិតមកអាននៅក្នុងភូមិឃុំនិងក្រោយការចូលរួមប្រជុំរបស់គាត់ប៉ុណ្ណោះ ។

**ទស្សនៈរបស់អ្នកចូលរួមប្រជុំអំពីតុលាការខ្មែរក្រហមនិងការប្រជុំពិភាក្សា**

សវនាការអង្គបុរេជំនុំជម្រះបានទទួលការយកចិត្តទុកដាក់

យ៉ាងខ្លាំងពីអ្នកចូលរួមប្រជុំ ទោះបីជាអ្នកភូមិមិនបានទៅចូលរួមអង្កេតដោយផ្ទាល់ក៏ដោយ ។ ប្រជាជនមួយចំនួនថ្លែងថា ខ្លួនចង់ចូលរួមសង្កេតដោយផ្ទាល់ប្រសិនបើគាត់មានលទ្ធភាព ។ ព័ត៌មានដែលអ្នកភូមិទទួលបាននៅឯសវនាការបានធ្វើឲ្យគាត់មានចំណាប់អារម្មណ៍ចំពោះដំណើរប្រព្រឹត្តទៅនៃអង្គជំនុំជម្រះព្រមទាំងសំណួរផ្សេងៗដែលបានលើកឡើងនៅសាលាក្ដី ។ អ្នកមានវត្តមាននៅក្នុងការប្រជុំមានចំណាប់អារម្មណ៍ដូចខាងក្រោម ៖

លឿង គុញ ដែលធ្លាប់រស់នៅនិងបម្រើខ្មែរក្រហមអស់រយៈពេលជាច្រើនឆ្នាំ មានសេចក្ដីត្រេកអរចំពោះដំណឹងអំពីតុលាការខ្មែរក្រហម ដោយសារតែតុលាការនេះបានបង្ហាញពីការរីកចម្រើនទៅមុខ ។ គាត់មានយោបល់ថា តុលាការនេះនឹងធ្វើជាឧទាហរណ៍សម្រាប់អ្នកជំនាន់ក្រោយថាឧក្រិដ្ឋជននឹងមិនមានឱកាសរួចផុតពីការដាក់ទោសទេ ។ បន្ថែមពីលើនេះ កុមារក៏នឹងមានឱកាសរៀនសូត្រអំពីរបបនេះដែរ ។

ហង្ស អឿន អាយុ៥២ឆ្នាំ រស់នៅក្នុងភូមិពោន សម្ដែងការត្រេកអរក្នុងការឃើញមេដឹកនាំទាំង៥នាក់ជាប់ក្នុងមន្ទីរឃុំឃាំងបណ្ដោះអាសន្ន ។ គាត់ជឿជាក់ថា ប្រសិនបើតុលាការមានការរីកចម្រើនទៅមុខ ប្រជាជនកម្ពុជានឹងរសាយកំហឹងដែលមានជាច្រើនឆ្នាំមកហើយ ។

ទោះជាយ៉ាងនេះក៏ដោយ ហង្ស អឿន, លឿង គុញ និងអ្នកចូលរួមប្រជុំដទៃទៀត នៅមានការបារម្ភចំពោះលទ្ធភាពក្នុងការនាំយកមេដឹកនាំទាំងនោះមកកាត់ទោសមុនពេលអ្នកទាំងនោះស្លាប់បាត់បង់ជីវិត ។ កែ ហៀង សំណូមពរឲ្យដំណើរការស៊ើបអង្កេតប្រព្រឹត្តទៅដោយឆាប់រហ័ស ដើម្បីនាំយកជនត្រូវចោទមកកាន់តុលាការឲ្យទាន់ពេលវេលា ។

ផ្ទុយទៅនឹងទស្សនៈរបស់អ្នកចូលរួមផ្សេងៗទៀត ឃុត ទៀយ អាយុ៥២ឆ្នាំ ដែលអះអាងថា ធ្លាប់ឃើញ អៀង សារី នៅម៉ាឡៃ (ភាគពាយ័ព្យប្រទេសកម្ពុជា) ក្នុងអំឡុងពេលតស៊ូរបស់ខ្មែរក្រហមនៅទសវត្សរ៍៨០ មានអារម្មណ៍ថា អៀង សារី ក៏ដូចជាមេដឹកនាំដទៃទៀត មិនគួរនាំយកមកកាត់ទោសទេ ដោយសារគាត់មានវ័យចំណាស់ទៅហើយ ។ គាត់បង្ហាញពីទឹកចិត្តអាណិតអាសូរចំពោះមេដឹកនាំខ្មែរក្រហម ហើយសំណូមពរឲ្យមានការដោះលែងមេដឹកនាំនេះឲ្យរួចផុតពីការឃុំឃាំងបណ្ដោះអាសន្ន ។

បន្ថែមទៅលើទស្សនៈចំពោះសវនាការនិងតុលាការ អ្នកចូលរួមមួយចំនួនបានបញ្ចេញយោបល់ដ៏គួរឲ្យចាប់អារម្មណ៍ ។ ក្រុមការងាររគម្រោងឯកសាររស់កត់សម្គាល់ថា ការប្រជុំពិភាក្សាបែបនេះគឺជាមធ្យោបាយមួយដ៏មានប្រសិទ្ធភាពក្នុងការចែករំលែកព័ត៌មាននៅតាមមូលដ្ឋាន ។ អ្នកចូលរួមប្រជុំខ្លះចាប់អារម្មណ៍ថាការប្រជុំនេះមានប្រយោជន៍ក្នុងការផ្សព្វផ្សាយព័ត៌មានថ្មីៗអំពីតុលាការ ។ ណុប គួច ដែលមានអាយុ៤៨ឆ្នាំ រស់នៅភូមិពោន បញ្ជាក់ថា ការប្រជុំនេះជួយផ្ដល់ព័ត៌មានច្បាស់អំពីតុលាការខ្មែរក្រហមបានច្រើនជាងប្រភពផ្សេងៗទៀត ។ គាត់មានអារម្មណ៍ថាព័ត៌មានដែលបានមកពីសមាជិកភូមិឃុំរបស់គាត់ ធ្វើឲ្យគាត់មានទំនុកចិត្តកាន់តែខ្លាំង ។ គួច បានសម្ដែងការដឹងគុណដល់តួនាទីរបស់តំណាងសហគមន៍ទាំង១០នាក់ ដែលបាននាំយកព័ត៌មាននេះមកដល់សហគមន៍របស់គាត់ ។ កែ ហៀង រស់នៅភូមិលៀប មានយោបល់ថា ព័ត៌មានទាំងនេះនឹងបានទៅដល់អ្នកភូមិកាន់តែទូលំទូលាយតាមរយៈការប្រជុំបែបនេះ ជាពិសេសអ្នកដែលមិនបានសង្កេតមើលសវនាការដោយផ្ទាល់ ។

**ការសន្និដ្ឋាន**

ការប្រជុំពិភាក្សាថ្នាក់ភូមិនៅឃុំត្រពាំងសាលាខាងកើតនេះពិតជាបានឆ្លុះបញ្ចាំងពីតួនាទីរបស់សហគមន៍ក្នុងការផ្សព្វផ្សាយព័ត៌មានពីសាលាក្ដីខ្មែរក្រហម ។ ភាពមោះមុតរបស់អ្នកតំណាងសហគមន៍ទាំង១០នាក់ ដែលបានចូលរួមសង្កេតសវនាការ អៀង សារី ព្រមទាំងពង្រឹងចំណេះដឹងរបស់ខ្លួនដើម្បីផ្ដល់ព័ត៌មាននិងបង្រៀនដល់សមាជិកសហគមន៍ ។ អ្នកទាំង១០រូបមានលទ្ធភាពបញ្ចេញគំនិតនិងចំណេះដឹងរបស់ខ្លួនចំពោះសវនាការនេះ ព្រមទាំងចែករំលែកទស្សនៈយោបល់ផ្ទាល់ខ្លួនទៅដល់អ្នកភូមិដទៃទៀត ។ ការកើនឡើងក្នុងការយកចិត្តទុកដាក់អំពីដំណើរការនៃអង្គជំនុំជម្រះបញ្ជាក់ពីផលល្អរបស់ដំណើរទស្សនកិច្ចនេះ ។ ការប្រជុំពិភាក្សាបែបនេះក៏បានរួមចំណែកឲ្យមានការចូលរួមរបស់ប្រជាជនក្នុងឆាកនយោបាយ ក៏ដូចជាការលើកកម្ពស់វិស័យយុត្តិធម៌និងការផ្សះផ្សាថ្នាក់មូលដ្ឋានដែរ ។

**ស៊ុំ សាឌីណា**

# របាយការណ៍ពីខេត្តសៀមរាប : គម្រោងជួយជនរងគ្រោះដាក់ពាក្យបណ្តឹងទៅតុលាការខ្មែរក្រហម

## ១) ប្រវត្តិការងារស្តីពីគម្រោងចូលរួមរបស់ជនរងគ្រោះក្នុងខេត្តសៀមរាប

### ប្រវត្តិខេត្តសៀមរាប

ខេត្តសៀមរាបស្ថិតនៅតាមច្រាំងបឹងទន្លេសាបទិសពាយ័ព្យនៃប្រទេសកម្ពុជានិងមានព្រំប្រទល់ខាងកើតជាប់ខេត្តព្រះវិហារនិងកំពង់ធំ ខាងលិចជាប់ខេត្តបន្ទាយមានជ័យនិងបាត់ដំបង ខាងជើងជាប់ខេត្តឧត្តរមានជ័យ និងខាងត្បូងជាប់បឹងទន្លេសាប មានផ្ទៃដីសរុប១០.២៩៩គីឡូម៉ែត្រការ៉េ ។ ខេត្តនេះមាន១២ស្រុករួមមានស្រុកអង្គរជុំ អង្គរធំ បន្ទាយស្រី ជីក្រែង ក្រឡាញ់ ពួកប្រាសាទបាខែង សៀមរាប សូត្រនិគម ស្រីស្នំ ស្វាយលើ និងវ៉ារិន ។ ខេត្តនេះមានប្រជាជនប្រហែល៦៩៦.១៦៨នាក់ ។

ពីឆ្នាំ១៩៧៥-១៩៧៧ ខេត្តសៀមរាបគឺជាតំបន់ឯករាជ្យមួយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់មក ខេត្តនេះត្រូវបានចាត់បញ្ចូលទៅក្នុងភូមិភាគឧត្តរនៅឆ្នាំ១៩៧៧ ។ ដោយយោងទៅលើការបង្ហាញថ្មីៗដែលបកស្រាយដោយគម្រោងគូសផែនទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺថាមានទីតាំងសម្ងាប់ចំនួន២៨កន្លែង (ដែលក្នុងនោះមានរណ្តៅជាង២៨០កន្លែងនិងសាកសពប្រមាណ៨២.០០០នាក់) គុកចំនួន១៣កន្លែង និងបូជនីយដ្ឋាន៨កន្លែងនៅក្នុងខេត្តសៀមរាប ។

ខេត្តសៀមរាបមានសារសំខាន់ណាស់សម្រាប់ការងារគម្រោងចូលរួមរបស់ជនរងគ្រោះ ។ អ្នកស្រុកខេត្តសៀមរាបពីឆ្នាំ១៩៨២-១៩៨៣ បានធ្វើញត្តិរំលាសិរ្សជាច្រើនដោយរក្សាទុកនៅក្នុងបណ្ណសារដ្ឋានរបស់មជ្ឈមណ្ឌល ។ ដូចនេះ វាអាចផ្តល់នូវព័ត៌មានដ៏មានប្រយោជន៍ស្តីអំពីដំណើរការជុំវិញការចុះហត្ថលេខា



បុគ្គលិកមជ្ឈមណ្ឌលកំពុងជួយបំពេញពាក្យបណ្តឹងប្រជាជននៅខេត្តសៀមរាប

លើញត្តិ ។ ផ្ទុយពីញត្តិដែលយើងប្រមូលបាននៅខេត្តកំពង់ធំ ញត្តិដែលយើងទទួលបានពីខេត្តសៀមរាប គឺមានហត្ថលេខារបស់បុគ្គលម្នាក់ៗដែលធ្វើឲ្យយើងយកចិត្តទុកដាក់ទៅលើអ្នកធ្វើញត្តិ និងដើម្បីទាក់ទងជាមួយអ្នកធ្វើញត្តិដែលមានចំនួនច្រើនលើសលប់នៅកំឡុងពេលចុះទៅតាមខេត្ត ។

### ប្រវត្តិនៃញត្តិរណសិរ្សនៅខេត្តសៀមរាប

មជ្ឈមណ្ឌលបានរក្សាទុកនៅក្នុងបណ្ណសារដ្ឋានរបស់ខ្លួននូវ «ញត្តិរណសិរ្ស» នេះ ។ នៅអំឡុងឆ្នាំ ១៩៨២-១៩៨៣ រដ្ឋាភិបាលក្រោយរបបខ្មែរក្រហមបានប្រមូលញត្តិចំនួន១.២៥០ ដែលរៀបរាប់ពីឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យលើប្រជាជនខ្មែរជាង១លាន១សែននាក់ ។ គម្រោងនេះគ្រោងនឹងប្រើញត្តិទាំងនេះដើម្បីស្វែងរកអ្នកដាក់ពាក្យបណ្តឹងនិងដើមបណ្តឹងរដ្ឋប្បវេណីជាសំខាន់ ។ ធ្វើដូច្នេះ គម្រោងនេះនឹងបង្កើតឡើងវិញនូវគណៈកម្មការស្វែងរកការពិតមិនផ្លូវការមួយដែលចាប់ផ្តើមឡើងដោយរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ នៅពេលបង្ហាញដល់អ្នកដាក់ពាក្យបណ្តឹងថា ចម្លើយសក្ខីភាពមុនមិនត្រូវបានបំភ្លេចចោល គម្រោងនេះនឹងរួមចំណែកក្នុងដំណើរការផ្សះផ្សាជាតិ ។ ខណៈពេលដែលគម្រោងនេះផ្តោតជាសំខាន់ទៅលើការស្វែងរកនិងជួយដល់អ្នកធ្វើញត្តិរណសិរ្ស ក្រុមនេះមានគោលបំណងជួយដល់អ្នកនៅរស់ទាំងអស់ដែលចាប់អារម្មណ៍ក្នុងការបំពេញទម្រង់បែបបទព័ត៌មានជនរងគ្រោះរបស់តុលាការ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាមានញត្តិចំនួន២៨៧មកពីខេត្តសៀមរាប ។ ជាធម្មតា អ្នកតំណាងម្នាក់ឬពីរនាក់បានសរសេរញត្តិមួយតំណាងឲ្យក្រុមធំមួយដែលមានមនុស្សប្រមាណពី២០ ទៅ៣០០នាក់ ហើយម្នាក់ៗបានចុះហត្ថលេខា ឬផ្តិតមេដៃលើញត្តិដែលរួមមានឈ្មោះរបស់គាត់ទៀតផង (ក្នុងករណីខ្លះមានទាំងភេទនិងអាយុ) ។ ដូច្នេះ ញត្តិដែលមកពីខេត្តសៀមរាបគឺមិនដូចញត្តិដែលមកពីខេត្តកំពង់ធំទេ ញត្តិមកពីខេត្តនេះមានឈ្មោះនិងហត្ថលេខាឬស្នាមមេដៃរបស់អ្នកតំណាងទាំងអស់ ។

### ២) សកម្មភាពរបស់បុគ្គលិកគម្រោងនៅថ្ងៃទី១៦-៣០ ខែមិថុនា

### គោលបំណង

គោលបំណងនៃគម្រោងនេះ គឺដើម្បីផ្តល់ព័ត៌មានដល់អ្នកនៅរស់ពីរបបកម្ពុជាប្រជាធិបតេយ្យអំពីសិទ្ធិចូលរួមនៅក្នុងការកាត់ក្តីនៅមុនអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងជួយគាត់ក្នុងការបំពេញទម្រង់បែបបទបើសិនជាគាត់មានបំណងចូលរួម ។ គម្រោងនេះបានស្វែងរកនិងជួបប្រជាជនក្នុងខេត្តដែលបានបំពេញញត្តិរណសិរ្សក្នុងឆ្នាំ១៩៨២-១៩៨៣ ។ គោលបំណងសំខាន់នៃគម្រោងនេះគឺដើម្បីប្រែក្លាយការបណ្តុះបណ្តាលនាពេលថ្មីៗឲ្យក្លាយទៅជាការអនុវត្ត ។

### ដំណើរការនាពេលថ្មីៗនេះ

នៅថ្ងៃទី២០ ខែមិថុនា ក្រុមនេះបាននាំយកបណ្តឹងរដ្ឋប្បវេណីទៅកាន់ទីក្រុងភ្នំពេញដើម្បីជួបជាមួយអង្គភាពជនរងគ្រោះនិងពិភាក្សាអំពីការតំណាងស្របច្បាប់ ។ លោក ជី ទេរិទ្ធិ (អ្នកដឹកនាំក្រុម) និង សារ៉ា ថូម៉ាស់ (សហការីច្បាប់) រួមជាមួយដើមបណ្តឹងរដ្ឋប្បវេណីបានទៅជួបជាមួយនឹង គៀត បូផល និង លោក បាលាស់ ម៉ា នៃអង្គភាពជនរងគ្រោះ ។ អ្នកទាំងពីរបានណែនាំឲ្យដើមបណ្តឹងរដ្ឋប្បវេណីជ្រើសរើសអ្នកតំណាងស្របច្បាប់ម្នាក់និងផ្តល់ឲ្យគាត់នូវតារាងឈ្មោះមេធាវីមួយដែលធ្វើការដោយមិនយកកម្រៃ ។ សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានសម្រេចថា គម្រោងនេះត្រូវតែស្វែងរកមេធាវីនិងជួយដល់ដើមបណ្តឹងរដ្ឋប្បវេណីដើម្បីជ្រើសរើសអ្នកតំណាងផ្នែកច្បាប់ម្នាក់ ។ ថ្មីៗនេះគម្រោងនេះបានទាក់ទងជាមួយមេធាវីមួយចំនួនដើម្បីរកការតំណាងដ៏សមរម្យមួយសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានជួយ ។ គម្រោងនេះនឹងមិនផ្តល់ប្រាក់សម្រាប់ការតំណាងស្របច្បាប់ទេ ។

នៅថ្ងៃទី២៨ ខែមិថុនា សារ៉ា ថូម៉ាស និងលោក វ៉ាន់ថាន់ ពៅដារ៉ា (នាយករង) បានជួបជាមួយនឹងអង្គភាពជនរងគ្រោះដើម្បីយកសំបុត្រទទួលស្គាល់សម្រាប់ចែកទៅដល់អ្នកដាក់ពាក្យបណ្តឹងនិងដើមបណ្តឹងរដ្ឋប្បវេណីចំនួន៣៩៥នាក់ ដែលបានបំពេញទម្រង់បែបបទចប់នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៧ ។ គាត បូផល (ប្រធានអង្គភាព) ត្រូវការឲ្យគម្រោងនេះជួយដល់អង្គភាពតាមរយៈការចែកសំបុត្រនិងទទួលព័ត៌មានបន្ថែមទៀតពីអ្នកដាក់ពាក្យបណ្តឹងនិងអ្នកធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី ដែលទម្រង់បែបបទរបស់គាត់ត្រូវបានគេគិតថាមិនមានព័ត៌មានគ្រប់គ្រាន់ ។ គម្រោង

នេះបានបញ្ជូនត្រឡប់មកវិញនូវសំបុត្រទទួលស្គាល់ទៅឲ្យអ្នកដាក់ពាក្យបណ្តឹងចំនួន៥នាក់និងបានប្រមូលព័ត៌មានបន្ថែមទៀតពីអ្នកដាក់ពាក្យបណ្តឹងម្នាក់នៅខេត្តកំពង់ធំ ។

បន្ថែមពីលើនេះទៀត គម្រោងនេះបានជួយសាច់ញាតិអ្នកជាប់នៅគុកទួលស្លែងចំនួន៧នាក់បន្ថែមទៀត ដើម្បីបំពេញទម្រង់បែបបទជាមួយនឹងអង្គភាពជនរងគ្រោះ ដែលរួមមានទាំងជនជាតិអាមេរិកាំងម្នាក់ទៀតផង ។ សាច់ញាតិ៣នាក់បានសម្រេចចិត្តបំពេញពាក្យបណ្តឹងប្រាប់ទៅសហព្រះរាជអាជ្ញាស្តីអំពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តមកលើសាច់ញាតិរបស់ពួកគេ នៅខណៈដែលសាច់ញាតិ៤នាក់ទៀតសម្រេចចិត្តបំពេញពាក្យបណ្តឹងរដ្ឋប្បវេណីដើម្បីឲ្យពួកគេអាចចូលរួមជាក្រុមក្នុងការប្តឹង ។ ថ្មីៗនេះ អង្គភាពជនរងគ្រោះនេះបានបន្តផ្ញើទម្រង់បែបបទដើមបណ្តឹងរដ្ឋប្បវេណីជាមូលដ្ឋានដំបូង ដើម្បីឲ្យអ្នកទាំងអស់នេះអាចបញ្ជូនទម្រង់បែបបទទាំងនោះទៅសហចៅក្រមស៊ើបអង្កេតបានឆាប់រហ័ស ។

ចាប់តាំងពីថ្ងៃទី៣០ ខែមិថុនា ដល់ថ្ងៃទី៣ ខែកក្កដា សមាជិកជាច្រើននៃគម្រោងនេះបានចូលរួមក្នុងសវនាការបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងការឃុំឃាំងជាបណ្តោះអាសន្នមុនអង្គបុរេជំនុំជម្រះ ។ នៅថ្ងៃទី១ និងទី២ ខែកក្កដា ចៅក្រមបានចេញសេចក្តីសម្រេចដោយផ្ទាល់មាត់ដ៏គួរឲ្យភ្ញាក់ផ្អើលចំនួនពីរដែលហាមឃាត់ដើមបណ្តឹងរដ្ឋប្បវេណីថាតើត្រូវតំណាងឬមិនតំណាងដោយស្មាគ្គីតាមរយៈការនិយាយដោយផ្ទាល់នៅអំឡុងពេលបើកសវនាការដំបូង ។ ទោះបីជាការសម្រេចចិត្តទាំងនេះបានកំណត់តាំងពីពេលបើកសវនាការកាត់ទោសលើកដំបូងក៏ដោយក៏ការសម្រេចចិត្តនេះបានធ្វើឲ្យបណ្តឹងរដ្ឋប្បវេណីដែលមិនមានអ្នកតំណាងមិនមានសិទ្ធិនិយាយ ហើយនឹងប៉ះទង្គិចទៅលើសិទ្ធិនៃបណ្តឹងរដ្ឋប្បវេណីដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានជួយ ។ ស្របពេលដែលអង្គជំនុំជម្រះបានគាំទ្រការចូលរួមរបស់ជនរងគ្រោះពីមុនមក ការសម្រេចចិត្តនេះគឺជាសញ្ញាដ៏សំខាន់មួយនៃយុត្តិសាស្ត្រដែលបានកម្រិត ។

នៅថ្ងៃទី៣ ខែកក្កដា សារ៉ា ថូម៉ាស បានសរសេរអត្ថបទបញ្ចេញមតិមួយថា នេះជាការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃឥរិយាបថនៅក្នុងអង្គជំនុំជម្រះ ដែលយើងអាចសន្និដ្ឋានបានថាជាការព្យាយាមដ៏ធំមួយដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីកញ្ញា សេង ធារី ដែលគាត់បាននិយាយនៅអំឡុងពេលដំណើរនិងការរៀបចំប្តឹងដ៏ទន់ខ្សោយនៃអង្គជំនុំជម្រះខ្លួនឯង ។ នៅថ្ងៃទី៤ ខែកក្កដា កាសែតខេមបូឌៀដេលីបានបោះពុម្ពអត្ថបទរបស់គាត់ជាសំបុត្រទៅកាន់អ្នកទទួលខុសត្រូវក្នុងការបោះពុម្ពនេះ ។ ចាប់តាំងពីនោះមក គាត់ត្រូវបានស្នើឲ្យបង្ហាញអត្ថបទនេះនៅក្នុងប្លុកច្បាប់អន្តរជាតិដែលជាប្លុកមួយសម្រាប់និស្សិតស្រីនិងអ្នកដែលមានវិជ្ជាជីវៈនៅក្នុងច្បាប់អន្តរជាតិ ។

នៅថ្ងៃទី៤ ខែកក្កដា គម្រោងនេះបានសរសេរសំបុត្រមួយច្បាប់ផ្ញើជូនអង្គភាពជនរងគ្រោះនិងអង្គបុរេជំនុំជម្រះដោយបានស្នើថា ដើមបណ្តឹងរដ្ឋប្បវេណីដែលមានជំនួយពីមជ្ឈមណ្ឌលឯកសារកម្ពុជាបានចូលរួមនៅក្នុងរឿងក្តីទី១ត្រូវបានអនុញ្ញាតឲ្យឆ្លើយតបចំពោះសំណើពិចារណាឡើងវិញនៃការសម្រេចចិត្តរបស់អង្គជំនុំជម្រះរបស់កញ្ញា សេង ធារី ។

## សេចក្តីលម្អិតនៃការរៀបចំនិងបុគ្គលិក

ក្រុមគម្រោងជួយជនរងគ្រោះដាក់ពាក្យបណ្តឹងទៅកាន់តុលាការបានជួលផ្ទះមួយខ្នងនៅក្នុងខេត្តសៀមរាបនៅអំឡុងពេលបំពេញការងារ ។ ការបំពេញការងារនេះមានរយៈពេល១៥ថ្ងៃ គឺចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី៣០ ខែមិថុនា ។ ទោះបីជាគម្រោងនេះគិតថានឹងចំណាយរយៈពេល២០ថ្ងៃក៏ដោយ ក៏អ្នកដឹកនាំក្រុមបានសម្រេចចិត្តថានឹងបន្ថយរយៈពេលបំពេញការងារដោយគិតថាមិនសូវមានការសហការពីសំណាក់ប្រធានភូមិព្រោះការបោះឆ្នោតជិតមកដល់ ។ បុគ្គលិក១៩នាក់ រួមទាំងក្រុមថតខ្សែភាពយន្ត៤នាក់ទៀត បានចូលរួមបំពេញការងារនេះ ។ សហការីច្បាប់ និងអ្នកស្រាវជ្រាវបរទេសម្នាក់ឈ្មោះ ពេកគី វ៉ុង មកពីសកលវិទ្យាល័យ ប៊ឺឃ្លីនៃសហរដ្ឋអាមេរិកបានចូលរួមនៅក្នុងក្រុមដើម្បីបំពេញការងារនេះ ។ ថ្មីៗនេះ សហការីផ្នែកច្បាប់ឈ្មោះ អានី ជេ បានសរសេរអត្ថបទមួយស្តីអំពីបទពិសោធន៍របស់គាត់សម្រាប់ទស្សនាវដ្តីស្វែងរកការពិត ។

មុនបំពេញការងារ សមាជិកគម្រោងបានជ្រើសរើសភូមិជាច្រើនដោយយោងទៅលើញត្តិរណសិរ្សដែលបានពីភូមិទាំង

នោះ ។

### លទ្ធផលនៃការបំពេញការងារ

### សមិទ្ធផលរបស់ក្រុមនៅក្នុងការកំណត់ចំនួន

នៅអំឡុងពេលបំពេញការងារ ក្រុមគម្រោងទទួលបានជោគជ័យនៅក្នុងស្រុកចំនួន៣ក្នុងចំណោមស្រុកទាំង១២នៅខេត្តសៀមរាប ដូចជាស្រុកសៀមរាប ក្រឡាញ់ និងពួក ។ ដោយឡែកក្រុមគម្រោងបានរៀបចំការប្រជុំនៅក្នុងភូមិចំនួន១៨នៃឃុំចំនួន១១ផ្សេងទៀត ។ សមាជិកគម្រោងបានផ្តល់ព័ត៌មានដល់អ្នកនៅរស់ពីរបបកម្ពុជាប្រជាប្រជាធិបតេយ្យស្តីពីសិទ្ធិចូលរួមរបស់គាត់ និងបានជួយបំពេញទម្រង់ព័ត៌មានជនរងគ្រោះដល់អ្នកនៅរស់ចំនួន១៣៩នាក់ ។

លោក ជី ទេរិទ្ធិ បានប្រមូលទម្រង់បែបបទព័ត៌មានជនរងគ្រោះចំនួន១៣៩ពីខេត្តសៀមរាប ជាមួយនឹងទម្រង់បែបបទមួយបន្ថែមទៀតពីសហរដ្ឋអាមេរិកប្រគល់ទៅឲ្យអង្គភាពជនរងគ្រោះនៅឯកិច្ចប្រជុំមួយកាលពីថ្ងៃទី១១ ខែកក្កដា ។

### ជោគជ័យរបស់ក្រុមក្នុងការជួបនឹងអ្នកធ្វើញត្តិរណសិរ្ស

តិចជាងពាក់កណ្តាលនៃទម្រង់បែបបទព័ត៌មានជនរងគ្រោះដែលប្រមូលបានត្រូវបានបំពេញចប់ដោយអ្នកធ្វើញត្តិរណសិរ្សដែលមានចំនួន៦៣ទម្រង់បែបបទក្នុងចំណោម១៣៩នៃអ្នកធ្វើញត្តិ ។ ខណៈដែលអ្នកធ្វើញត្តិភាគច្រើនបានសម្រេចចិត្តបំពេញទម្រង់បែបបទនេះ ប្រធានភូមិជាច្រើននៅក្នុងខេត្តសៀមរាបទំនងជាមិនសហការនិងមិនបានទាក់ទងជាមួយឈ្មោះអ្នកធ្វើញត្តិដែលមាននៅក្នុងបញ្ជីបានចែកដោយសមាជិកគម្រោងទេ ។ ដូច្នេះខេត្តសៀមរាបផ្ទុយពីខេត្តពោធិ៍សាត់ដែលមានតែចំនួនអ្នកធ្វើញត្តិដែលបានកំណត់ប៉ុណ្ណោះបានចូលរួមការប្រជុំ ។ អាស្រ័យហេតុនេះ ខណៈដែលសិទ្ធិជាអាទិភាពត្រូវបានអនុញ្ញាតចំពោះតែអ្នកធ្វើញត្តិ ក្រុមគម្រោងក៏បានជួយអ្នកមិនបានធ្វើញត្តិយ៉ាងច្រើន ។

ក្រុមគម្រោងបានរកឃើញថា ចំនួនអ្នកធ្វើញត្តិដ៏ច្រើនលើសលប់ ដំបូងមិនបានចងចាំនូវហត្ថលេខានៅលើញត្តិនោះទេ ។ នៅក្នុងករណីជាច្រើនទៀត បន្ទាប់ពីបង្ហាញញត្តិនិងហត្ថលេខាគាត់បានចងចាំឡើងវិញ ហើយច្រើននាក់ទៀតមិនបានចាំច្បាស់ពីការប្រជុំដែលគាត់បានចុះហត្ថលេខាទេ ។ វាបានបង្ហាញថា ញត្តិទាំងនោះត្រូវបានចុះហត្ថលេខាតាមរយៈការប្រជុំឬធ្វើនៅតាមផ្ទះក្នុងអំឡុងពេលដែលប្រធានភូមិឬក៏មេឃុំចុះមកបំពេញការងារ ។ ក្រុមគម្រោងបានរកឃើញថា អ្នកធ្វើញត្តិមិនបានចងចាំពីទិដ្ឋភាពពេលប្រជុំឬផលប៉ះពាល់ផ្នែកនយោបាយលើញត្តិទាំងនោះទេ ។

### ការព្យាយាមស្វែងរកផលប៉ះពាល់ទៅលើសហគមន៍បណ្តាលមកពីការធ្វើទារុណកម្មនៅគុកភ្នំទ្រងំបាត្រ

អំឡុងពេលបំពេញការងារ អ្នកដាក់ពាក្យបណ្តឹងចំនួន២៥នាក់និងដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានធ្វើសេចក្តីបញ្ជាក់ចំពោះអំពើឃោរឃៅដែលបានប្រព្រឹត្តនៅគុកភ្នំទ្រងំបាត្រនៅស្រុកក្រឡាញ់ ខេត្តសៀមរាប ដោយគាត់បានផ្តល់នូវរឿងរ៉ាវដើមនិងរឿងដែលឮពីគេស្តីពីស្ថានភាពពិតនេះ ។ ដោយយោងទៅតាមរឿងរបស់គាត់បានបញ្ជាក់ថា ខ្មែរក្រហមបានបញ្ជូនអ្នកដែលចាប់ខ្លួនបាននៅក្នុងតំបន់ភ្នំទ្រងំបាត្រមកកាន់គុកនេះ ។ បន្ទាប់មក ខ្មែរក្រហមបានសម្លាប់អ្នកទោសទាំងនោះនិងដុតរំលាយសាកសពសម្រាប់ធ្វើជីឬក៏ដុតទាំងរស់ ។ ចម្លើយសាក្សីនៅក្នុងញត្តិរណសិរ្សទាំងនេះបានជួយដល់អ្នកដែលនៅរស់ ។ យោងតាមការវិភាគដែលធ្វើឡើងដោយលោក ឆាំង យុ បានអះអាងថា ញត្តិទាំងនោះចង់និយាយថា «ប៉ុល ពត បានជីកស្រះនិងដាក់ចំបើងប្រើប្រាស់ដូចជាឡដើម្បីដុតមនុស្សទាំងរស់សម្រាប់ធ្វើជាជីដាក់នៅក្នុងវាលស្រែ» ។

យោងតាមទម្រង់បែបបទទាំងនោះបង្ហាញថា ស្ថានភាពនៅគុកនេះពិបាកខ្លាំងណាស់ ។ អ្នកជាប់គុកត្រូវបានផ្តល់នូវរបបអាហារមិនគ្រប់គ្រាន់ ហើយត្រូវបង្ខំឲ្យវាយបំបែកថ្មដើម្បីសង់ស្ពាន ។ នៅឆ្នាំ១៩៧៦ គុកនេះត្រូវបានរៀបចំធ្វើជាកន្លែងសម្រាប់សម្លាប់ក្នុងគោលបំណងដុតអ្នកទោសធ្វើជី ។ តំបន់នេះមានរណ្តៅធំៗជាច្រើន ។ រណ្តៅទាំងនេះ សម្រាប់ដាក់អង្កាមនិងដុតបំភ្លឺ ។ មានអ្នកទោសចំនួន១០០នាក់ទាំងអ្នកស្លាប់និងអ្នកនៅរស់ត្រូវបានអ្នកយាមគុកបោះចូលទៅក្នុងរណ្តៅភ្លើងនេះ ។ ករណីខ្លះទៀតអ្នកទោសទាំងនោះត្រូវបានបង្ខំឲ្យដើរតាមមាត់រណ្តៅទាំងនោះឆ្ពោះទៅកន្លែងសម្លាប់ ។ បន្ទាប់មក ខ្មែរក្រហមបានយកសំណល់ដែលនៅសេសសល់ទាំងនោះមកធ្វើជី ។ នៅក្នុងទម្រង់បែបបទ

ព័ត៌មានទាំងនេះ អ្នកដាក់ពាក្យបណ្តឹងបានអះអាងថា គេបានទទួលដីពីភ្នំទ្រង់បាត្រដែលមានលាយបំណែកឆ្អឹងជាច្រើន ។

ក្រុមគម្រោងបានជួបជាមួយអ្នកនៅរស់ចំនួន៣នាក់នៅតំបន់នេះ ដែលត្រូវបានអ្នកស៊ើបអង្កេតមកពីតុលាការជ្រើសរើសយកធ្វើជាសាក្សី ។ ការពិតសាក្សី២នាក់ក្នុងចំណោមនោះធ្លាប់ធ្វើជាសាក្សីមុនពេលតុលាការប្រជាជនបដិវត្តន៍កម្ពុជាឆ្នាំ ១៩៧៩ ។ យោងតាមចរិតឃោរឃៅនៃទារុណកម្មនិងលក្ខខណ្ឌនៅក្រោមការស៊ើបអង្កេតក្រុមគម្រោងបានបំបែកទម្រង់បែបបទព័ត៌មានទាំងនោះដែលទាក់ទងជាមួយនឹងគុកភ្នំទ្រង់បាត្រ រួចសរសេរសំបុត្រមួយច្បាប់ស្តីអំពីបញ្ហានេះផ្ញើទៅអង្គភាពជនរងគ្រោះដោយជំរុញឲ្យអង្គភាពនេះផ្តល់អាទិភាពលើទម្រង់បែបបទព័ត៌មានទាំងនេះ ។

## ផលវិជ្ជមានអំឡុងពេលបំពេញការងារ

១) ការប្រជុំរបស់ក្រុមបានផ្តល់ឱកាសដ៏ល្អដល់អ្នកនៅរស់ដើម្បីឲ្យគាត់អាចនិយាយរឿងរ៉ាវផ្ទាល់ខ្លួនប្រាប់ក្រុមដែលចាប់អារម្មណ៍ ធ្វើដូច្នេះគាត់អាចមានអារម្មណ៍ធូរស្រាលបានច្រើន ។

២) ជាឱកាសសម្រាប់បំពេញទម្រង់ព័ត៌មានជនរងគ្រោះនិងជួយបង្កើតកំណត់ត្រាប្រវត្តិសាស្ត្រដែលអាចធ្វើឲ្យអ្នកដែលនៅរស់សប្បាយចិត្ត ពីព្រោះមនុស្សជាច្រើនបានសម្តែងការព្រួយបារម្ភថា អ្នកជំនាន់ក្រោយនឹងមិនជឿពីអំពើឃោរឃៅនៅក្នុងរបបខ្មែរក្រហមទេ ។

៣) ការប្រជុំរបស់ក្រុមក៏បានផ្តល់នូវឱកាសដ៏មានសារ-ប្រយោជន៍សម្រាប់ជម្រាបដល់អតីតខ្មែរក្រហមថ្នាក់ក្រោមថាតុលាការនឹងកាត់ទោសតែមេដឹកនាំជាន់ខ្ពស់និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតប៉ុណ្ណោះ ។ ដូច្នេះ វាអាចជួយឲ្យគាត់ស្ងប់ចិត្តនិងបង្កើតការសហការជាមួយតុលាការ ។

៤) ការចុះទៅបំពេញការងារនេះបានបង្ហាញពីតម្លៃនៃញត្តិរណសិរ្សក្នុងការចងក្រងបង្ហាញចម្លើយសាក្សីនៃអ្នកដាក់ពាក្យបណ្តឹងនិងដើមបណ្តឹងរដ្ឋប្បវេណី ។ ទាក់ទងទៅនឹងគុកភ្នំទ្រង់បាត្រ ក្រុមគម្រោងបានរកឃើញថា ការនិយាយបំផ្លើសជាច្រើនដែលធ្វើឡើងនៅក្នុងទម្រង់បែបបទញព័ត៌មានទាំងនេះបានឆ្លុះបញ្ចាំងពីប្រជាជនដែលបានធ្វើញត្តិអស់រយៈពេលជាង២០ឆ្នាំមកហើយ ។

៥) ក្រុមគម្រោងបានរកឃើញទៀតថា អ្នកនៅរស់មួយចំនួនធំមិនបានព្រួយបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួនរបស់គេទេ ហើយមានតែប្រជាជនមួយចំនួនតូចប៉ុណ្ណោះដែលសំណូមពរឲ្យមានការចាត់វិធានការពារ ។

៦) គម្រោងមានចំនួនបុគ្គលិកគ្រប់គ្រាន់ក្នុងការបំពេញការងារនេះ ដើម្បីជួយអ្នកនៅរស់ទាំងអស់ដែលមានបំណងចង់បំពេញទម្រង់បែបបទព័ត៌មាននេះ ។

## ផលវិបាកដែលបានជួបប្រទះនិងដំណោះស្រាយចំពោះមុខ

១) ការយល់ច្រឡំទៅលើអំណោយ ៈ អ្នកនៅរស់មួយចំនួនដែលបានចូលរួមនៅក្នុងកិច្ចប្រជុំរបស់គម្រោងយល់ច្រឡំថា គាត់នឹងទទួលបានអំណោយត្រឡប់ទៅវិញ សម្រាប់ការមកចូលរួមរបស់គាត់និងជាពិសេសសម្រាប់ការបំពេញពាក្យបណ្តឹង ។

**អនុសាសន៍ ៖** គោលការណ៍ចម្បងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺមិនផ្តល់ជាអំណោយឬក៏លុយសម្រាប់ការអញ្ជើញមកចូលរួមរបស់អ្នកដែលនៅរស់ទាំងនោះទេ ។

២) ការលំបាកនៃអ្នកដែលនៅរស់ដើម្បីលើកឡើងពីសំណងជំងឺចិត្តសម្រាប់ជនរងគ្រោះ ៈ ដូចជានៅក្នុងខេត្តដទៃទៀតដែរ អ្នកនៅរស់ដ៏ច្រើនសន្ធឹកសន្ធាប់បានព្យាយាមស្នើសុំឲ្យមានសំណងដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់លាក់របស់ជនរងគ្រោះដោយសារខ្មែរក្រហម ។ ជាធម្មតា សំណូមពររបស់គាត់គឺត្រូវបានកំណត់ដោយភ្ជាប់ទៅនឹងតម្រូវការដែលទាក់ទងជាមួយនឹងការអភិវឌ្ឍដូចជា សាងសង់សាលារៀន ផ្លូវ និងមន្ទីរពេទ្យជាដើម ។ ផលប្រយោជន៍នេះមិនត្រឹមតែបានផ្តល់ដល់ជនរងគ្រោះទាំងនោះទេ ថែមទាំងបានដល់អ្នកដែលមិនមែនជាជនរងគ្រោះក៏ដូចជាជនដៃដល់ផងដែរ ។ ទាំងនេះជាការលំបាកចំពោះអ្នកដែលនៅរស់ដើម្បីលើកឡើងពីសំណងជំងឺចិត្តដែលអាចជួយសម្រួលដល់ជីវភាពរបស់គាត់ ហើយម្យ៉ាងសមាជិកគម្រោងក៏មិនសូវយល់ដឹងពីសារសំខាន់នៃសំណងសម្រាប់ជនរងគ្រោះដែរ ។

**អនុសាសន៍ ៖** ដឹកនាំការបណ្តុះបណ្តាលដល់សមាជិកក្រុមស្តីពីសារសំខាន់នៃសំណងសម្រាប់ជនរងគ្រោះនិងលើកទឹកចិត្តដល់អ្នកដែលនៅរស់ឲ្យគិតពីគម្រោងសំណងដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ជនរងគ្រោះ ។

៣) ការខ្វះការសហការពីសំណាក់ប្រធានភូមិដែលធ្វើឲ្យការងាររបស់គម្រោងបរាជ័យ ៖ ផ្ទុយស្រឡះពីខេត្តពោធិ៍សាត់ ក្រុមគម្រោងបានរកឃើញថា ប្រធានភូមិមួយចំនួននៅខេត្តសៀមរាបមិនបានសហការនិងរៀបចំសម្រាប់ការចុះបំពេញការងាររបស់យើងទេ ។ ដូចជានៅក្នុងករណីខ្លះប្រធានភូមិថែមទាំងស្រវឹងស្រាទៀតផង ។ ទោះបីជាក្រុមរបស់យើងបានចែកបញ្ជីឈ្មោះអ្នកធ្វើញត្តិទៅឲ្យប្រធានភូមិមុនយ៉ាងណាក៏ដោយ ក៏ប្រធានភូមិនៅតែមិនបានទាក់ទងទៅអ្នកធ្វើញត្តិឬក៏អញ្ជើញអ្នកភូមិដែរ ។ ដូច្នេះ បានជាការប្រមូលទម្រង់បែបបទព័ត៌មានមិនសូវបានលទ្ធផលល្អព្រោះមិនសូវមានអ្នកចូលរួម ។ ការខ្វះការសហការនេះបណ្តាលមកពីកត្តា៣យ៉ាងគឺ ១) សំខាន់បំផុតមកពីមេឃុំនិងប្រធានភូមិជាប់រវល់ឃោសនាបោះឆ្នោតសម្រាប់ការបោះឆ្នោតដែលជិតមកដល់ ២) ប្រធានភូមិមួយចំនួនជាប់រវល់ក្នុងជំនួញដោយសារតែភាពសម្បូរទ្រព្យធននៅខេត្តសៀមរាប ៣) ការរៀបចំគម្រោងសម្រាប់បំពេញការងារមានរយៈពេលខ្លី ។

**អនុសាសន៍** ៖ ជៀសវាងចុះទៅបំពេញការងារតាមខេត្តនៅពេលជិតបោះឆ្នោត កុំធ្វើសហប្រតិបត្តិការនៅក្នុងខេត្តណាដែលសម្បូរទ្រព្យធននិងប្រាកដក្នុងចិត្តថាការចុះបំពេញការងារតាមខេត្តធ្វើឡើងដោយម៉ត់ចត់ ។

៤) ការមិនពេញចិត្តក្នុងការបំពេញទម្រង់បែបបទ ៖ ផ្ទុយពីខេត្តពោធិ៍សាត់ ក្រុមរបស់យើងបានរកឃើញថាអ្នកនៅរស់ក្នុងខេត្តសៀមរាបទំនងជាមិនពេញចិត្តក្នុងការបំពេញទម្រង់បែបបទទេ ។ ខណៈដែលមនុស្សភាគច្រើនមានការរំភើបអំពីគោលបំណងរបស់គម្រោងនេះ មានមនុស្សជាច្រើនបានសម្រេចចិត្តមិនបំពេញទម្រង់បែបបទព័ត៌មានពីព្រោះគាត់ជាប់រវល់ច្រើន ។ វាបានស្តែងឡើងថា ប្រជាជនមមាញឹកជាខ្លាំងពីព្រោះជាប់រវល់រឿងបោះឆ្នោតនិងជំនួញ ។

**អនុសាសន៍** ៖ ជៀសវាងចុះទៅតាមខេត្តនៅអំឡុងបោះឆ្នោត និង កុំធ្វើសហប្រតិបត្តិការនៅក្នុងខេត្តណាដែលសម្បូរទ្រព្យធន ។

**សេចក្តីសន្និដ្ឋាន**

ការចុះទៅធ្វើការនៅខេត្តសៀមរាបបានបង្ហាញពីជោគជ័យដ៏តិចតួចក្នុងការចុះទៅបំពេញការងាររបស់គម្រោង ព្រោះថាក្រុមរបស់យើងបានប្រមូលទម្រង់បែបបទបានត្រឹមតែ១៣៩ ប៉ុណ្ណោះនៅក្នុងរយៈពេល១៥ថ្ងៃ ។ ការណ៍នេះបានបង្ហាញពីចំនួនដ៏តិចតួចនៃទម្រង់បែបបទព័ត៌មានដែលប្រមូលបានក្នុងរយៈពេល១ថ្ងៃ ហើយអត្រាដែលប្រមូលបានទាបជាងនៅក្នុងខេត្តពោធិ៍សាត់ ។ អត្រាប្រមូលបានដ៏តិចតួចនេះអាចសន្និដ្ឋានបានថា ដោយសារខ្វះការសហការពីសំណាក់ប្រធានភូមិ និងបណ្តាលមកពីជីវិតដ៏មមាញឹករបស់អ្នករស់នៅខេត្តសៀមរាបនិងភាពប្រញាប់ប្រញាល់រៀបចំចុះទៅបំពេញការងារតាមខេត្ត ។


អ្នកភូមិកំពុងអានទស្សនាវដ្តីស្វែងរកការពិត ក្នុងខេត្តសៀមរាប

ទោះបីជាអត្រាប្រមូលបានមានចំនួនតិចយ៉ាងណាក៏ដោយ ក៏វាបានបង្ហាញថាទម្រង់បែបបទដែលប្រមូលបានជាច្រើននឹងផ្តល់សារប្រយោជន៍ដល់ការងារនៅតុលាការ ។ ជាពិសេសក្រុមគម្រោងសង្ឃឹមថាទម្រង់បែបបទព័ត៌មានដែលប្រមូលបានទាក់ទងទៅនឹងអំពើឃោរឃៅដែលប្រព្រឹត្តនៅគុកភ្នំទ្រង់បាត្រនឹងជួយដល់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតពីព្រោះយើងជឿជាក់ថាស្ថានភាពនេះស្ថិតនៅក្រោមការស៊ើបអង្កេត ។

**សារ៉ា ថូម៉ាស និង ឌី ឆេរិទ្ធិ**

# ដំណើរទស្សនកិច្ចរបស់សិស្សវិទ្យាល័យ និងយុវជនមូស្លីម

នៅព្រឹកថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានដឹកនាំសិស្សចំនួន៤០០នាក់ មកពីវិទ្យាល័យហ៊ុនសែនអន្លង់ស្នួល១៥០នាក់ វិទ្យាល័យបឹងត្របែក ២០០នាក់ និងយុវជនអ៊ីស្លាមមកពីឫស្សីជ្រោយ៥០នាក់ ដោយជួបប្រជុំគ្នានៅក្នុងបរិវេណនៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ២ បន្ទាប់មក ដំណើរទស្សនកិច្ចរបស់សិស្សវិទ្យាល័យទាំងពីរនិងយុវជនមូស្លីមបានចេញដំណើរទៅទស្សនាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វាលពិឃាដជើងឯក និងសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ។

**គោលបំណង**

មជ្ឈមណ្ឌលឯកសារបង្កើតកម្មវិធីនេះឡើងគឺដើម្បីផ្សព្វផ្សាយ ប្រមែប្រមូលព័ត៌មាននិងអប់រំសិស្ស ក៏ដូចជាយុវជនទាំងអស់នៅទូទាំងប្រទេសកម្ពុជាឲ្យដឹងពីអំពីរបបខ្មែរក្រហមនិងដំណើរការរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ដើម្បីរកយុត្តិធម៌ជូនជនរងគ្រោះដែលបានស្លាប់និងអ្នកដែលរស់រានមានជីវិតពីរបបនេះ ។

គម្រោងទស្សនកិច្ចនេះបានអញ្ជើញលោក ហេង ណាត ដែលជាអតីតអ្នកទោសជាប់ឃុំឃាំងនៅទួលស្លែងមករៀបរាប់ពីប្រវត្តិនិងបទពិសោធន៍របស់គាត់ផ្ទាល់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យប្រាប់ទៅដល់អង្គប្រជុំ ។ លោក ពូ ណាត មានប្រសាសន៍ថា គាត់ត្រូវអង្គការបានចាប់ខ្លួននៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៧៧ នៅសហករណ៍២ ឃុំអូរមុន្នី ស្រុក៤១ តំបន់៤ ដោយចោទប្រកាន់ថាជាសេអ៊ីអា កាហ្សេបេ និងភ្នាក់ងារសម្ងាត់របស់យួន ។ គាត់ត្រូវអង្គការបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងរយៈពេល២ខែ ប៉ុន្តែដោយសារគាត់មានជំនាញជាជាងគំនូរ ក្រោយមកអង្គការក៏ដោះលែងគាត់ឲ្យគូរគំនូរប្រចាំនៅក្នុងគុកនេះវិញ ។ ណាត ក៏បានរៀបរាប់ផងដែរពីអ្វីដែលគាត់បានជួបប្រទះដូចជា វិធីសាស្ត្រសួរចម្លើយ ការធ្វើទារុណកម្ម ការសម្លាប់របស់ខ្មែរក្រហមមកលើអ្នកទោសស្លូតត្រង់ជាដើម ។

ក្រោយរំដោះឆ្នាំ១៩៧៩ លោកពូ ណាត បានគូររូបគំនូរជាច្រើនដែលរៀបរាប់ពីជីវិតពិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយបានដាក់តាំងនៅរោងភាពយន្តបុប្ផាណា ក្នុងទីក្រុងភ្នំពេញ ក្រុងបាងកកប្រទេសថៃ និងសហរដ្ឋអាមេរិក ។ គាត់បានបន្ថែមថា គោលបំណងសំខាន់នៃពិព័រណ៍នេះ គឺដើម្បីអប់រំក្មេងជំនាន់ជាន់ក្រោយឲ្យបានដឹងពីទុក្ខលំបាករបស់ឪពុកម្តាយ បងប្អូន និងពូមីងដែលបានស្លាប់ទៅ ។

បន្ទាប់មកលោក វ៉ាន់ ថាន់ពៅដារ៉ា នាយករងរបស់មជ្ឈ-មណ្ឌលឯកសារកម្ពុជាបានពន្យល់ពីវិធីសាស្ត្រប្រមែប្រមូលឯកសាររបស់មជ្ឈមណ្ឌលដែលជាកម្លាំងជំរុញឲ្យមានតុលាការខ្មែរក្រហម ។ គាត់បន្ថែមថា ចាប់តាំងពីការបង្កើតមជ្ឈមណ្ឌលដំបូង



លោកគ្រូបង្ហាញសិស្សានុសិស្សពីភ័ស្តុតាងដែលបន្សល់ទុកនៅគុកទួលស្លែង

នៅឆ្នាំ១៩៩៥ យើងមិនបានគិតថានឹងមានតុលាការនេះទេ ប៉ុន្តែបុគ្គលិករបស់មជ្ឈមណ្ឌលនៅតែខិតខំប្រឹងប្រែងធ្វើការ ដែលមកដល់សព្វថ្ងៃនេះមជ្ឈមណ្ឌលមានឯកសារខ្មែរក្រហមចំនួន៨សែនទំព័រ រូបថតរបស់មេដឹកនាំខ្មែរក្រហម និងកម្មាភិបាលខ្មែរក្រហមប្រមាណ៦០០០សន្លឹក ។ លើសពីនេះទៅទៀត មជ្ឈមណ្ឌលប្រមូលបានខ្សែភាពយន្តប្រមាណ២០០ និងបទសម្ភាសជាមួយអតីតខ្មែរក្រហមជាង៤០០០នាក់ រកឃើញរណ្តៅសាកសពរួមជាង២០០០០រណ្តៅ បូនីយដ្ឋានដែលសង់ក្រោយរបបខ្មែរក្រហម៨១កន្លែង និងមន្ទីរឃុំឃាំងនៅទូទាំងប្រទេសកម្ពុជាចំនួន១៩៦កន្លែង ។

បន្ទាប់ពីស្តាប់ប្រសាសន៍របស់លោកពូ ណាត និងលោក វ៉ាន់ ថាន់ពៅដារ៉ា មជ្ឈមណ្ឌលបានបញ្ចាំងខ្សែភាពយន្តដែលមានចំណងជើងថា «ក្រោយជញ្ជាំងមន្ទីរស-២១» បង្ហាញពីអតីតអ្នកយាមគុកស-២១ និងអតីតអ្នកទោសពីរនាក់ ។

នៅម៉ោង៩:៣០នាទី លោក អានី តំណាងប្រធានការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានលើកឡើងពីអំពើប្រល័យពូជសាសន៍នៅកម្ពុជានិងតួនាទីរបស់តុលាការដែលត្រូវតែសហការជាមួយយុវជនដែលជាទំពាំងស្នងឫស្សី ។ លោកបានបន្ថែមថា ប្រជាជនកម្ពុជានឹងមើលឃើញបុគ្គលិកកម្ពុជានិងបុគ្គលិកអង្គការសហប្រជាជាតិធ្វើការរួមគ្នាដើម្បីស្វែងរកភ័ស្តុតាងបន្ថែមទៀតមកកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនិងវិធីទប់ស្កាត់មិនឲ្យរបបនេះកើតឡើងនៅពេលអនាគត ។ បន្ទាប់មក លោក រាជ សម្បត្តិ ដែលជាមន្ត្រីទទួលបន្ទុកកិច្ចការព័ត៌មាននិងជាអ្នកនាំពាក្យរបស់សាលាក្តីបានពន្យល់ពីរូបភាពតំណាងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលមានព្រះរាជាអង្គុយកាន់ព្រះខ័ននៅក្នុងរង្វង់ក្អួរស្លឹកអូលីវនិងរចនាសម្ព័ន្ធនៅក្នុងតុលាការដែលមានបុគ្គលិកជាតិនិងអន្តរជាតិជាង៣០០នាក់ ។ គាត់បានលើកពីបំណងសំខាន់បីរបស់សាលាក្តីគឺ ទី១) ផ្តល់យុត្តិធម៌ជូនជនរងគ្រោះ ទី២) ថែរក្សាសន្តិសុខ ស្ថិរភាពនយោបាយនិងឯកភាពជាតិ ទី៣) គោរពដល់អធិបតេយ្យភាពជាតិ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារួមមានចៅក្រមខ្មែរនិងបរទេសដែលធ្វើការកាត់ទោសមេដឹកនាំខ្មែរក្រហមពីបទឧក្រិដ្ឋដែលបានកើតឡើងចាប់ពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ៦ ខែមករា ឆ្នាំ១៩៧៩ ។ នៅក្រោយពេលកាត់ក្តីចប់ តុលាការនេះនឹង ១) ជួយឲ្យប្រជាជនកម្ពុជាបានធូរស្បើយក្នុងចិត្ត ហើយជាពិសេសអ្នករស់រានមានជីវិតក្រោយរបបប៉ុល ពត ទី២) ជួយឲ្យយុវជនជំនាន់ក្រោយដឹងពីប្រវត្តិសាស្ត្ររបស់ខ្លួន ៣) លុបបំបាត់និទ្ទណ្ឌភាព ៤) តុលាការខ្មែរក្រហមជាគំរូដល់តុលាការកម្ពុជា ។

ក្រោយពីបានពន្យល់ប្រាប់សិស្សទាំងអស់រួចហើយ មន្ត្រីរបស់អង្គជំនុំជម្រះក៏ផ្តល់ឱកាសដល់សិស្សទាំងអស់សួរសំណួរទាក់ទងនឹងដំណើរការរបស់តុលាការនេះមានដូចជា យុវសិស្ស រ័ត្ន បញ្ញា មកពីសាលាបឹងត្របែកសួរថា នៅពេលតុលាការរកឃើញកំហុសរបស់មេដឹកនាំខ្មែរក្រហម តើតុលាការកាត់ក្តីដូចម្តេច? ប្រាក់ កែវគន្ធា សួរថាតើនរណាជាអ្នកសងសំណងជំងឺចិត្តសម្រាប់ជនរងគ្រោះ? ។ ការសាកសួរនិងឆ្លើយសំណួរនៅអង្គជំនុំជម្រះវិសាមញ្ញបានបញ្ចប់នៅវេលាម៉ោង១២ថ្ងៃត្រង់ ។

## ទស្សនៈរបស់សិស្សចំពោះដំណើរទស្សនកិច្ច

របបខ្មែរក្រហមជារបបដ៏ឃោរឃៅដែលសម្លាប់ប្រជាជនខ្មែរជិត២លាននាក់ ។ ក្មេងៗជំនាន់ក្រោយដែលកើតក្រោយរបបនេះភាគច្រើនបានដឹងថាមានរបបខ្មែរក្រហមតែតាមរយៈការរៀបរាប់របស់ឪពុកម្តាយ បងប្អូន ឬសាច់ញាតិប៉ុណ្ណោះ ។ ប៉ុន្តែទោះបីមិនបានឃើញហេតុការណ៍ជាក់ស្តែងដែលបានកើតឡើងនៅក្នុងរបបនោះក៏ដោយ ក៏ការរៀបរាប់ដ៏តិចតួចនេះបានជួយឲ្យក្មេងៗបានយល់ដឹងខ្លះពីរបបខ្មែរក្រហមដែរ ។

ឡៅ ទាហឺ រៀននៅវិទ្យាល័យបឹងត្របែក និយាយថា «ខ្ញុំធ្លាប់ឮថាមានរបបខ្មែរក្រហមតាមរយៈឪពុកម្តាយនិយាយប្រាប់ នៅពេលឃើញផ្ទាល់នៅទីតាំងវាលពិឃាដជើងឯក និងសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ធ្វើឲ្យខ្ញុំកាន់តែជឿថាពិតជាមានកាប់សម្លាប់ប្រាកដមែន» ។ ទាហឺ បន្តថា «យើងត្រូវតែដឹងពីការសម្លាប់នេះ និងត្រូវតែសាមគ្គីគ្នាដើម្បីកុំឲ្យរបបនេះកើតឡើងម្តងទៀត» ហើយបានលើកឡើងទៀតថា «តុលាការកាត់ទោសមេដឹកនាំតែ៥នាក់ វាមិនមានយុត្តិធម៌គ្រប់គ្រាន់ទេ ព្រោះខ្មែរក្រហមបានសម្លាប់មនុស្សអស់ច្រើនណាស់» ។

ប៉ុន្តែ ពេលខ្លះការរៀបរាប់របស់ឪពុកម្តាយមិនបានធ្វើឲ្យក្មេងជឿជាក់ទាំងស្រុងនោះទេ ព្រោះពួកគេគ្រាន់តែគិតថាទាំងអស់នេះគឺជាការដាស់តឿនរំឭកនិងនិយាយបន្ទុះបន្ទាប់របបមុនដែលបានបាត់បង់ទៅហើយ ។ ដូច្នេះ លុះត្រាដែលអ្នកទាំងអស់នេះបានមើលឃើញទីកន្លែងដែលខ្មែរក្រហមសម្លាប់មនុស្សនិងបានបន្សល់ទុក ទើបធ្វើឲ្យការជឿរបស់គេកើនឡើងថាជារឿងពិតមិនមែនជាការប្រឌិតទេ ។

ម៉ាក់ ចេង រៀនថ្នាក់ទី១២ នៅវិទ្យាល័យបឹងត្របែកនិយាយថា «កាលពីមុនពេលខ្ញុំឮឪពុកម្តាយប្រាប់ថារបបខ្មែរក្រហមមានការកាប់សម្លាប់ ខ្ញុំមិនមានសូវជឿទេ ប៉ុន្តែនៅពេលមកឃើញជាក់ស្តែងនិងផ្អែកទៅលើឯកសារដែលធ្លាប់រៀន ខ្ញុំជឿថាហេតុការណ៍នោះពិតជាកើតមានមែន ហើយត្រូវតែចងចាំទុកជាប្រវត្តិសាស្ត្រដើម្បីដាស់អារម្មណ៍ទាំងអស់គ្នាថាកុំបំភ្លេចចោលរឿងនេះ បើមិនអ៊ីចឹងវានឹងអាចកើតឡើងម្តងទៀតនៅថ្ងៃណាមួយជាមិនខាន» ។ ចេង បន្ថែមថា «ខ្ញុំមិនដែលឮថាមានសាលាក្តីខ្មែរក្រហមទេ ទើបតែពេលនេះបានមកឃើញផ្ទាល់ភ្នែក និងសង្ឃឹមថា សាលាក្តីនេះពិតជាអាចរកយុត្តិធម៌ជូនប្រជាជនបាន» ។ ចេង បានបន្តថា «ខ្ញុំនឹងនិយាយប្រាប់អំពីដំណើរទស្សនកិច្ចនេះដល់ប្អូនខ្ញុំ ឬក្មួយ និងអ្នកផ្សេងទៀត ហើយបើសិនជាខ្ញុំមានពេល ខ្ញុំនឹងនាំប្អូនខ្ញុំមកឲ្យឃើញកន្លែងនេះផ្ទាល់តែម្តង» ។

សៀង ស៊ីណា អាយុ១៨ឆ្នាំ រៀនថ្នាក់ទី១១ នៅវិទ្យាល័យអង្គស្នួលបាននិយាយថា នៅពេលចាស់ៗនិយាយប្រាប់ពីការកាប់សម្លាប់សម្លាប់នៅក្នុងរបបខ្មែរក្រហមដំបូង ខ្ញុំមិនបានជឿទេ ។ ថ្ងៃមួយគាត់បាននិយាយពីប្រវត្តិរបស់ពូខ្ញុំថា «ពូខ្ញុំជាគ្រូបង្រៀន ។ គាត់ត្រូវខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅខេត្តពោធិ៍សាត់ ។ នៅទីនោះ គាត់ត្រូវធ្វើការជាទម្ងន់រហូតធ្លាក់ខ្លួនឈឺ ក្រោយមកក៏ស្លាប់នៅទីនោះ ។ ចំណែកឪពុកខ្ញុំត្រូវធ្វើការនៅកងចល័តតាំងពីព្រឹកព្រលឹមរហូតដល់ព្រលប់» ។ ស៊ីថា បន្តថា «ប្អូនៗរបស់ខ្ញុំមិនជឿថាមានរបបនេះទេ ដូច្នេះត្រូវថែរក្សាទីតាំងវាលពិឃាដជើងឯកនិងសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងទុកឲ្យក្មេងជំនាន់ក្រោយបានឃើញ» ហើយ «ដើម្បីថែរក្សាប្រវត្តិសាស្ត្រនេះយើងគួរចាក់ផ្សាយតាមទូរទស្សន៍និងបោះពុម្ពសៀវភៅដើម្បីបង្រៀននៅតាមសាលាចាប់ពីថ្នាក់ទី៧ឡើងទៅ ព្រោះសិស្សអាចអាននិងយល់ដឹងបានច្រើន» ។

រំសាន រៀនថ្នាក់ទី៧ នៅមជ្ឈមណ្ឌលឥស្លាមកម្ពុជា បាននិយាយថា ខ្ញុំធ្លាប់បានដឹងពីរបបខ្មែរក្រហមខ្លះៗដែរតាមរយៈឪពុកម្តាយនិងយាយតា ។ មុនពេលបានមកចូលរួមក្នុងទស្សនកិច្ចសាន មិនជឿថាមានរបបខ្មែរក្រហមកើតឡើងនៅក្នុងប្រទេសកម្ពុជាទេ ព្រោះគិតថាចាស់ៗគ្រាន់តែនិយាយដើម្បីបន្លាចក្មេងៗប៉ុណ្ណោះ ។ ប៉ុន្តែនៅពេលបានមកឃើញផ្ទាល់ភ្នែកនូវរូបភាពជាក់ស្តែងដូចជា រូបថត លលាដ៍ក្បាល ទើបធ្វើឲ្យខ្ញុំជឿ ។ សាន មានការសោកស្តាយចំពោះយាយនិងតាដែលបានស្លាប់នៅជំនាន់ខ្មែរក្រហម ហើយសង្ឃឹមថាតុលាការនិងកាត់ទោសឲ្យបានឆាប់ដើម្បីរកយុត្តិធម៌ជូនគាត់ ។ សាន បានលើកឡើងថា បើតាមសាសនាឥស្លាមមិនឲ្យសម្លាប់គ្នាទេ ប៉ុន្តែបើនៅពេលមានសង្គ្រាម នៅក្នុងទ្រឹស្តីសាសនាអាចឲ្យយើងសងសឹកបាន ។ សាន បន្ថែមថា យើងទាំងអស់គ្នាគួរថែរក្សាប្រវត្តិសាស្ត្រខ្មែរទុកឲ្យក្មេងជំនាន់ក្រោយ


លោកគ្រូនិងសិស្សានុសិស្សចូលទៅទស្សនាអាគារ នៅគុកទួលស្លែង

បានដឹងនិងយល់កាន់តែច្បាស់ថា ខ្មែរក្រហមធ្វើបាបបងប្អូនខ្មែរ និងគ្រប់ជនជាតិទាំងអស់ដែលរស់នៅក្នុងស្រុកខ្មែរ ។ ប្រជាជនយើងត្រូវចេះសាមគ្គីគ្នា ដូច្នេះយើងនឹងលែងមានសង្គ្រាមទៀតហើយ ។ សាន បានបន្ថែមថា ទស្សនកិច្ចអាចប្រាប់ដល់ក្មេងជំនាន់ក្រោយឲ្យដឹងថា ខ្មែរក្រហមធ្វើបាបបងប្អូនយើង ។

## ទស្សនៈរបស់គ្រូបង្រៀនចំពោះដំណើរទស្សនកិច្ច

ក្រៅពីការបង្រៀនសិស្សពីចំណេះទូទៅតាមកម្មវិធីសិក្សារបស់សាលា លោកគ្រូ-អ្នកគ្រូក៏បានឆ្លៀតឱកាសដឹកនាំសិស្សរបស់គាត់ឲ្យចូលរួមនៅក្នុងដំណើរទស្សនកិច្ចដើម្បីឲ្យបានយល់ដឹងអំពីដំណើរការរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ជាពិសេសអំពើឃោរឃៅនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលបានសម្លាប់ប្រជាជនស្លូតត្រង់របស់ខ្លួនអស់ប្រមាណជិតពីរលាននាក់ ។

លោក ជីវ សុខន ជាគ្រូបង្រៀននៅវិទ្យាល័យបឹងត្របែក បានមានប្រសាសន៍ថា «ដំណើរទស្សនកិច្ចនេះមានផលប្រយោជន៍ល្អណាស់ ព្រោះធ្វើឲ្យក្មេងជំនាន់ក្រោយដឹងពីរបបខ្មែរក្រហម និងជឿជាក់យ៉ាងពិតប្រាកដថា អ្វីដែលឪពុកម្តាយរបស់គេបានរៀបរាប់គឺជាការពិត» ។ លើសពីនេះទៅទៀត ដើម្បីបញ្ជាក់ថាមេដឹកនាំដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍នេះត្រូវតែទទួលទោសតាមបទឧក្រិដ្ឋដែលខ្លួនបានធ្វើ មិនអាចមានការលើកលែងទោសបានទេ ។ ដូច្នេះ ដើម្បីឲ្យសិស្សយល់កាន់តែច្បាស់ពីអំពើប្រល័យពូជសាសន៍នេះគឺត្រូវតែដាក់ប្រវត្តិសាស្ត្រខ្មែរក្រហមបញ្ចូលទៅក្នុងកម្មវិធីសិក្សានៅតាមសាលាដើម្បីឲ្យសិស្សជំនាន់ក្រោយបានដឹង ។



ស ម៉េង ជានាយករងនៅវិទ្យាល័យហ៊ុនសែនអង្គស្នួល បានមានប្រសាសន៍ថា «ដំណើរទស្សនកិច្ចនេះ គឺចង់បង្ហាញពីអ្វីដែលប្រទេសរបស់យើងបានជួបប្រទះកាលពីអំឡុងឆ្នាំ១៩៧៥-១៩៧៩ និងដើម្បីឲ្យយើងបានរៀបចំខ្លួនសម្រាប់ថ្ងៃអនាគត ហើយប្រជាជនខ្មែរនឹងមិនបង្កើតរឿងបែបនេះម្តងទៀតទេ ។ ចំពោះសិស្សានុសិស្សរឿងរ៉ាវទាំងនោះវាគ្រាន់តែជារឿងនិទានប៉ុណ្ណោះ ប៉ុន្តែក្រោយពីបានឃើញស្ថានភាពពិតប្រាកដតាមរយៈការធ្វើដំណើរទស្សនកិច្ចសិក្សាបានធ្វើឲ្យអ្នកទាំងអស់នោះជឿថាខ្មែរពិតជាបានសម្លាប់ខ្មែរគ្នាឯងមែន» ។ ស ម៉េង បានបន្ថែមទៀតថា «ខ្ញុំមានអារម្មណ៍ក្តុកក្តួលនិងសង្វេគណាស់ពេលដែលឃើញបន្ទប់ដាក់អ្នកទោស កន្លែងសួរចម្លើយទាំងអស់នេះ វាហួសពីការគិតរបស់ខ្ញុំ» ។

ដំណើរទស្សនកិច្ចនេះមិនត្រឹមតែឲ្យសិស្សបានទស្សនាទីតាំងអគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វាលពិឃាដជើងឯកនិងសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងប៉ុណ្ណោះទេ ថែមទាំងធ្វើឲ្យសិស្សទាំងអស់ដែលមកពីទីកន្លែងផ្សេងគ្នាដូចជា សិស្សវិទ្យាល័យបឹងត្របែក វិទ្យាល័យអង្គស្នួល និងមជ្ឈមណ្ឌលឥស្លាមកម្ពុជាបានស្គាល់គ្នាទៀតផង ។ លើសពីនេះសិស្សអាចយល់ដឹងកាន់តែច្បាស់ពីរបបកម្ពុជាប្រជាធិបតេយ្យដើម្បីយកចំណេះដឹងទាំងនេះមកធ្វើជាបទពិសោធន៍ផ្ទាល់ខ្លួនក្នុងការរស់នៅនិងដឹកនាំសង្គមជាតិឆ្ពោះទៅរកសន្តិភាពនិងការអភិវឌ្ឍន៍នាពេលអនាគត ។

**សោម ប៊ុនថន និង គាត លក្ខិណា**

# ដំណើរទស្សនកិច្ចរបស់សិស្សវិទ្យាល័យ និងយុវជនមូស្លីម វាលពិឃាដជើងឯក និងសារមន្ទីរប្រល័យពូជសា







# ទៅកាន់អគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
# ាសន៍ទួលស្លែង នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨







**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**
**សំណុំរឿងព្រហ្មទណ្ឌ**
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**
**លេខស៊ើបសួរ/Investigation/Instruction**
**លេខ/No: 002/19-09-2007-ECCC-OCIJ**

**ដីកាសម្រេចអំពីការបន្តរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន**
**Order on Extension of Provisional Detention**
**Ordonnance sur la prolongation de la détention provisoire**

យើង **យូ ប៊ុនឡេង** និង **Marcel LEMONDE** (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤

បានឃើញវិធាន ៦៣(៧) នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

បានឃើញការបើកការស៊ើបសួរលើឈ្មោះ **នួន ជា** និងជនផ្សេងទៀត
ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានធ្ងន់ធ្ងរលើសន្ធិសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

បានឃើញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៧

បានឃើញសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០៨

បានឃើញសេចក្តីជូនដំណឹងចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ ២០០៨ ដែលក្នុងនោះយើងបានជូនដំណឹងដល់ជនត្រូវចោទ និងមេធាវីរបស់ខ្លួនអំពីគោលបំណងរបស់យើងក្នុងការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ដែលនឹងត្រូវផុតរលត់នៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៨ ហើយនិងបានឲ្យជាដំណឹងដល់ពួកគេថា ពួកគេមានរយៈពេល ១៥ ថ្ងៃ ដើម្បីធ្វើការកត់សម្គាល់ ឬតវ៉ាមកយើង

បានឃើញការតវ៉ាជំទាស់របស់ជនត្រូវចោទ ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ ២០០៨

យល់ឃើញថាការតវ៉ាជំទាស់របស់ជនត្រូវចោទពាក់ព័ន្ធជាសំខាន់នឹងល័ក្ខខ័ណ្ឌ ដែលមានកំណត់នៅក្នុងវិធាន ៦៣(៣)(ក) នៃវិធានផ្ទៃក្នុង។ តាមរយៈដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៧ សហចៅក្រមស៊ើបអង្កេតយល់ថា មានហេតុផលសមស្រប ដែលនាំឲ្យជឿថា នួន ជា បានប្រព្រឹត្តឧក្រិដ្ឋកម្មដូចដែលបានចោទប្រកាន់។ ក្នុងសេចក្តីសម្រេចរបស់ខ្លួន ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០៨ ឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះយល់ថា ភ័ស្តុតាងដែលមាននៅក្នុងសំណុំរឿងក្នុងដំណាក់កាលនោះ (ជាពិសេសសូមមើល កថាខណ្ឌ ៤៣-៥៨) មានលក្ខណៈគ្រប់គ្រាន់ ដើម្បីបង្ហាញអំពីការជឿជាក់នេះ។ ក្រោយមក ការស៊ើបសួរលើជនត្រូវចោទក៏នៅតែបន្ត។ សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់លើភ័ស្តុតាងបន្ថែមនានាដែលប្រមូលបាន និងបានដាក់បញ្ចូលភ័ស្តុតាងទាំងនោះទៅក្នុងសំណុំរឿង ជាពិសេសរួមមានចម្លើយចំនួន ២៣ របស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ទាក់ទងទៅនឹងបរិបទ និងដំណើរការនៃមន្ទីរ ស-២១ ក៏ដូចជាតួនាទីរបស់ជនត្រូវចោទ នួន ជា នៅក្នុងបញ្ហាទាំងនោះផងដែរ។ ដូច្នេះសហចៅក្រមស៊ើបអង្កេតយល់ថាល័ក្ខខ័ណ្ឌ ដែលមានកំណត់នៅក្នុងវិធាន ៦៣(៣)(ក) នៃវិធានផ្ទៃក្នុង នៅតែត្រូវបានបំពេញ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

យល់ឃើញថា លក្ខខណ្ឌនានាដែលមានកំណត់នៅក្នុងវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង ក៏នៅតែត្រូវបានបំពេញ ហើយថាសំអាងហេតុនៅក្នុងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០៨ នៅតែមានសុពលភាពដដែល

## អាស្រ័យហេតុនេះ

សម្រេចឲ្យមានការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ នួន ជា ក្នុងរយៈពេលអតិបរមាចំនួនមួយឆ្នាំបន្ថែមទៀត ដោយអនុលោមតាមបទប្បញ្ញត្តិនៃវិធាន ៦៣(៦)(ក) នៃវិធានផ្ទៃក្នុង។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០០៨

**សហចៅក្រមស៊ើបអង្កេត**

**Co-Investigating Judges**

**Co-juges d'instruction**

# ការវិភាគទៅលើដីកាដំណោះស្រាយបញ្ជូនសំណុំរឿង កាំង ហ្កេកអ៊ាវ ទៅជំនុំជម្រះ

នៅថ្ងៃទី១២ ខែសីហាឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចេញដីកាដំណោះស្រាយមួយ ដោយបញ្ជូនសំណុំរឿង កាំង ហ្កេកអ៊ាវ ហៅ ឌុច ទៅកាន់អង្គជំនុំជម្រះអំពីបទល្មើសមួយចំនួនក្នុងនាម ឌុច ជាអនុប្រធាននិងជាប្រធានមន្ទីរសន្តិសុខ ស-២១ ឬគុកទួលស្លែង ។ ទោះជាយ៉ាងណាក៏ដោយ វិសាលភាពនៃអង្គហេតុនិងអង្គច្បាប់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះតិចតួចជាងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាដែលបានដាក់នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨ ដែរ ។ អាស្រ័យហេតុនេះ ទើបនៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានប្រកាសពីគោលបំណងរបស់ខ្លួនដើម្បីប្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយនេះ ។

ដោយអនុលោមទៅតាមវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅពេលបញ្ចប់ការស៊ើបអង្កេតទៅលើចុងចោទ សហចៅក្រមស៊ើបអង្កេតត្រូវតែចេញដីកាដំណោះស្រាយ ដោយបញ្ជូនសំណុំរឿងរបស់ភាគីចុងចោទទៅជំនុំជម្រះមុនពេលបើកសវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ បន្ទាប់ពីបញ្ចប់ការជំនុំជម្រះ សេចក្តីវិនិច្ឆ័យរបស់អង្គជំនុំជម្រះត្រូវធ្វើឡើងស្របតាមអង្គហេតុដែលបានដាក់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ ជាងនេះទៅទៀត ទោះបីជាអង្គជំនុំជម្រះកែប្រែការកំណត់អង្គច្បាប់នៃបទល្មើសដែលបានដាក់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះក៏ដោយ វាក៏មិនអាចបង្ហាញឲ្យឃើញពីភស្តុតាងថ្មីអ្វីដែរ ។ ដូច្នេះ ដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ គឺជាចំណុចសំខាន់មួយក្នុងការកំណត់វិសាលភាពនៃការជំនុំជម្រះ ។

អាស្រ័យហេតុនេះ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការកំណត់ការចោទប្រកាន់ ឌុច នៅក្នុងដីកាដំណោះស្រាយនិងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាបង្កឲ្យមានការព្រួយបារម្ភយ៉ាងតិចចំនួនបីចំពោះផ្លូវច្បាប់ ។ ទីមួយអនុលោមតាមច្បាប់អន្តរជាតិ សេចក្តីសម្រេចមិនចោទប្រកាន់ ឌុច ដោយច្បាប់កម្ពុជារបស់សហចៅក្រមស៊ើបអង្កេតហាក់ដូចជាធ្វើឡើងមុនពេលនិងមិនត្រឹមត្រូវតាមច្បាប់ ។ ទីពីរ សហព្រះរាជអាជ្ញាបានជំទាស់នឹងការខកខានមិនបាននិយាយអំពីមូលដ្ឋាន «សហកម្មឧក្រិដ្ឋកម្មរួម» (ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយមនុស្សច្រើននាក់) នៃការទទួលខុសត្រូវ ។ ដីកាដំណោះស្រាយមានលក្ខណៈមិនសូវពេញលេញ ពីព្រោះដីកានេះមិនបានរួមបញ្ចូលសេចក្តីសម្រេចសមហេតុសមផលទៅលើចំណុចនេះទេ ។ វាមានសារសំខាន់ណាស់ដើម្បីបញ្ជាក់ថាតើសហកម្មឧក្រិដ្ឋកម្មរួមត្រូវតែបញ្ចូលទៅ ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះឬក៏អត់ ។ ទីបី ដីកាដំណោះស្រាយបានកំណត់ពីវិសាលភាពនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលចោទប្រកាន់ទៅលើ ឌុច តែមិនបានបញ្ជាក់ថាហេតុអ្វីបានជា ឌុច គឺជាមនុស្សម្នាក់ក្នុងចំណោមអ្នកដែលត្រូវទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ ។

### ១) ការខកខានមិនបានរួមបញ្ចូលការចោទប្រកាន់តាមច្បាប់ព្រហ្មទណ្ឌកម្ពុជា

នៅក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា ទោះបីជាសកម្មភាពរបស់ ឌុច «គឺជាបទល្មើសមនុស្សឃាតនិងទារុណកម្មក្នុងស្រុក» ដោយអនុលោមទៅតាមច្បាប់ព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ក៏ «សកម្មភាពទាំងនេះត្រូវតែស្របទៅតាមការចោទប្រកាន់ក្រោមការកំណត់ប្រភេទបទល្មើសដែលមានលក្ខណៈខ្ពស់ជាងគេ» ដែរ ។ ក្រោយមក ចៅក្រមយល់ឃើញថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩ គឺជាការចោទប្រកាន់ក្រោមការកំណត់ប្រភេទបទល្មើសដែលមានលក្ខណៈខ្ពស់ជាងគេ

*ហើយក៏បានបដិសេធចោលនូវការចោទប្រកាន់តាមច្បាប់ជាតិពីបទមនុស្សឃាតនិងទារុណកម្មរបស់សហព្រះរាជអាជ្ញា ។*

### ***ក) មានការអនុញ្ញាតឲ្យធ្វើការចោទប្រកាន់ត្រួតគ្នា (ពីរដង)***

*នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ គេអាចធ្វើការចោទប្រកាន់ពីបទល្មើសពីរដង ។ បទល្មើសត្រួតគ្នាសំដៅទៅលើបទល្មើសដែលត្រូវបានចោទប្រកាន់យោងទៅតាមលក្ខខណ្ឌបទបញ្ញត្តិផ្សេងគ្នា ប៉ុន្តែស្របទៅតាមការអនុវត្តដូចគ្នា ។ រាល់សេចក្តីសម្រេចទៅលើបទល្មើសត្រួតគ្នានឹងធ្វើឡើងយ៉ាងត្រឹមត្រូវដោយអង្គជំនុំជម្រះ ហើយអង្គជំនុំជម្រះអាចនឹងពិចារណាទៅដល់បទឧក្រិដ្ឋដែលបានផ្តល់សក្ខីកម្មហួសពីវិមតិសង្ស័យនៅពេលសវនាការ ។ ជាងនេះទៅទៀត តុលាការអន្តរជាតិបានរកឃើញថា អង្គជំនុំជម្រះអាចសម្រេចចោទប្រកាន់ជនត្រូវចោទពីបទល្មើសត្រួតគ្នា ប្រសិនបើច្បាប់ចង់ការពារផលប្រយោជន៍សង្គមផ្សេងគ្នា ។*

*អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលជាតុលាការកូនកាត់បានគាំទ្រការចោទប្រកាន់ត្រួតគ្នាពីបទរំលោភបំពានទៅលើច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ ។ ដោយគ្រាន់តែអនុញ្ញាតឲ្យមានការចោទប្រកាន់បែបនេះ តើតុលាការអាចកំណត់វិសាលភាពនៃឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយមេដឹកនាំខ្មែរក្រហមនិងការមិនគោរពច្បាប់កម្ពុជានៅក្នុងរបបខ្មែរក្រហមដែរឬទេ?*

### ***ខ) ការចោទប្រកាន់តាមច្បាប់កម្ពុជានិងច្បាប់អន្តរជាតិមិនមែនជាការចោទប្រកាន់ត្រួតគ្នាទេ***

*មនុស្សឃាតនិងទារុណកម្មដែលបានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌឆ្នាំ១៩៥៦ មិនអាចរួមបញ្ចូលជាមួយឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងការរំលោភបំពានទៅលើអនុសញ្ញាក្រុងហ្សឺណែវ ដើម្បីប្រែក្លាយទៅជាការចោទប្រកាន់តាមអង្គច្បាប់ «ដែលមានលក្ខណៈខ្ពស់ជាងមុន» ដូចដែលសហចៅក្រមស៊ើបអង្កេតបានស្នើនោះទេ ។ នៅក្រោមច្បាប់អន្តរជាតិ ការចោទប្រកាន់ត្រូវធ្វើឡើងទៅតាមច្បាប់ព្រហ្មទណ្ឌផ្សេងគ្នា ប៉ុន្តែអាចផ្អែកទៅលើការអនុវត្តបទឧក្រិដ្ឋដូចគ្នា ប្រសិនបើច្បាប់ឬក៏បទបញ្ញត្តិព្រហ្មទណ្ឌនីមួយៗរួមមានភស្តុតាងជាក់ស្តែងផ្សេងគ្នា ។ មានន័យថា បទបញ្ញត្តិព្រហ្មទណ្ឌនីមួយៗត្រូវតែមានអំណះអំណាងពីអង្គហេតុច្បាស់លាស់ ហើយដែលមិនយោងទៅតាមបញ្ញត្តិផ្សេងទៀត ។*

*ចំពោះការសម្រេចទៅលើធាតុផ្សំច្បាប់ខុសប្លែក ធាតុផ្សំយុត្តាធិការនៃបទល្មើសអន្តរជាតិត្រូវតែយកមកពិចារណា ។ ធាតុផ្សំយុត្តាធិការគឺជាធាតុផ្សំទាំងឡាយណាដែលប្រែក្លាយបទល្មើសព្រហ្មទណ្ឌធម្មតាទៅជាការរំលោភបំពានច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។ ជាឧទាហរណ៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺជាសកម្មភាពប្រព្រឹត្តឡើងដែលជាផ្នែកមួយនៃការវាយប្រហារយ៉ាងធ្ងន់ធ្ងរឬជាប្រព័ន្ធទៅលើប្រជាជនស៊ីវិលដោយមូលហេតុជាតិ នយោបាយ ជាតិសាសន៍ ពូជសាសន៍ ឬក្រុមសាសនា ។ ចំពោះបទល្មើសរំលោភបំពានទៅលើអនុសញ្ញាក្រុងហ្សឺណែវត្រូវតែជាសកម្មភាពប្រព្រឹត្តឡើងនៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធអន្តរជាតិនិងការប្រឆាំងប្រជាជន ឬទ្រព្យសម្បត្តិដែល «ត្រូវបានការពារ» ដោយអនុសញ្ញាក្រុងហ្សឺណែវ ។*

*មិនមានធាតុយុត្តាធិការទាក់ទងនឹងបទល្មើសប្រឆាំងច្បាប់អន្តរជាតិណាតំណាងឲ្យធាតុផ្សំដែលតម្រូវតាមច្បាប់ជាតិទេ ។ ជាងនេះទៅទៀត បទល្មើមនុស្សឃាតនិងការធ្វើទារុណកម្មនៅក្រោមច្បាប់កម្ពុជាមានធាតុផ្សំខុសប្លែកពីច្បាប់អន្តរជាតិ ។*

*ក្នុងករណីមានអង្គហេតុដូចគ្នា ច្បាប់កម្ពុជានិងអន្តរជាតិសុទ្ធតែអាចចោទប្រកាន់បទល្មើសការធ្វើទារុណកម្ម បើដូច្នេះ តើការបង្ហាញតាមផ្លូវច្បាប់មួយណាគឺជាធាតុផ្សំជាក់ស្តែងដើម្បីសម្គាល់បទល្មើស ។ ការវិភាគទៅលើធាតុផ្សំបង្ហាញថា នៅក្រោមច្បាប់កម្ពុជាដើម្បីអះអាងការចោទប្រកាន់ពីបទធ្វើទារុណកម្ម វាចាំបាច់ត្រូវតែបង្ហាញភស្តុតាងនៃការអនុវត្តដោយចេតនាក្នុងគោលបំណងទទួលយកព័ត៌មាននិងធ្វើបាប ។ នៅក្រោមច្បាប់អន្តរជាតិ ភស្តុតាងនៃការមិនចាត់វិធានការក៏គ្រប់គ្រាន់សម្រាប់ចោទប្រកាន់ការធ្វើទារុណកម្មដែរ ។ ធាតុផ្សំចេតនាមានលក្ខណៈជាក់ស្តែងដូចគ្នា បើភស្តុតាងយោងតាមច្បាប់អន្តរជាតិស្តីពីចេតនានៃការរើសអើងត្រូវបានយកមកបង្ហាញ ។ ស្រដៀងគ្នានេះដែរ នៅក្រោមច្បាប់ព្រហ្មទណ្ឌកម្ពុជា បទល្មើសមនុស្សឃាតតម្រូវឲ្យមានភស្តុតាងទាក់ទងនឹងសកម្មភាពច្បាស់លាស់ ដែលខុសពីបទល្មើសមនុស្សឃាតដូចមានចែងនៅក្នុងច្បាប់អន្តរជាតិកំណត់ថា ការមិនចាត់វិធានការអាចជាភស្តុតាងគ្រប់គ្រាន់សម្រាប់ការចោទប្រកាន់ ។ តាមការវែកញែកដែលសមស្របនិងធាតុយុត្តាធិការរបស់បទ*

ល្មើសអន្តរជាតិអាចបង្ហាញថា ចុងចោទជាប់ទោសពីបទមនុស្សឃាតនិងការធ្វើទារុណកម្មស្របតាមច្បាប់តែមួយ មានន័យថាស្របតាមច្បាប់អន្តរជាតិឬច្បាប់កម្ពុជា ។ បទឧក្រិដ្ឋអន្តរជាតិប្រហែលជាមិនអាចតំណាងឲ្យការចោទប្រកាន់ក្រោមការកំណត់ប្រភេទបទល្មើសដែលមានលក្ខណៈខ្ពស់នៃឧក្រិដ្ឋកម្មជាតិទេ ។

អាស្រ័យដូចនេះ សហចៅក្រមស៊ើបអង្កេតមានកំហុសក្នុងការខកខានមិនបានបញ្ជូនរឿង ឌុច ទៅជំនុំជម្រះស្របតាមក្រមច្បាប់ព្រហ្មទណ្ឌកម្ពុជា ។ ដីកាបញ្ជូនរឿងក្តីទៅជំនុំជម្រះខកខានមិនបានពិចារណាទៅដល់បញ្ហានៃការចោទប្រកាន់ត្រួតគ្នា ប៉ុន្តែការចោទប្រកាន់នោះក៏មិនមែនជាការចោទប្រកាន់ត្រួតគ្នាដែរ ។ ជាងនេះទៅទៀត បទល្មើសហាក់ដូចជាបម្រើផលប្រយោជន៍សង្គមផ្សេងគ្នាដូចដែលតុលាការបានផ្តល់សិទ្ធិឲ្យកាត់ទោសមេដឹកនាំខ្មែរក្រហមពីបទរំលោភបំពានទៅលើច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ ។ ទោះបីជាសេចក្តីវិនិច្ឆ័យដែលមានយុត្តិធម៌និងភាពមិនលម្អៀងតម្រូវថា ចៅក្រមមិនត្រូវមើលរំលងបទល្មើសខ្វះ ប៉ុន្តែរាល់ការយល់ឃើញទាំងអស់ក៏នឹងត្រូវយកមកនិយាយនៅពេលកាត់ក្តីដែរ ។



កាំងហ្គេចអ៊ាវ ហៅ ឌុច នៅសវនាការ

## ៧) ការខកខានមិនបាននិយាយពីការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួម

នៅក្រោមវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា «ដីកាបញ្ជូនរឿងទៅតុលាការគួរតែកែប្រែដោយសារកំហុសខាងនីតិវិធីមិនបានរួមបញ្ចូលអត្តសញ្ញាណរបស់ចុងចោទស្តីពីការរៀបរាប់អំពីអង្គហេតុជាក់ស្តែង និងការបង្ហាញតាមអង្គច្បាប់ដែលរួមបញ្ចូលទាំងបទបញ្ញត្តិព្រហ្មទណ្ឌដែលជាប់ពាក់ព័ន្ធព្រមទាំងការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋកម្ម» ។ មុនពេលមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតនិងសហព្រះរាជអាជ្ញាត្រូវតែជួបពិភាក្សាជាមួយគ្នា ។ នៅពេលបញ្ចប់ការស៊ើបអង្កេតនិងមុនពេលចេញដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតត្រូវតែទទួល «ដីកាសន្និដ្ឋានស្ថាពរដែលមានហេតុផលត្រឹមត្រូវ» របស់សហព្រះរាជអាជ្ញា ។ រីឯដីកាដំណោះស្រាយត្រូវតែមានរៀបរាប់ពីមូលហេតុនៃសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ។ ដំណើរការទាំងនេះឆ្លុះបញ្ចាំងពីគោលការណ៍មូលដ្ឋាននៃ «យុត្តិធម៌និងដំណើរការបង្ហាញភ័ស្តុតាងទៅកាន់ភាគីចុងចោទ» ព្រមទាំង «ការទទួលខុសត្រូវផ្សេងគ្នារបស់អ្នកធ្វើការចោទប្រកាន់និងអ្នកធ្វើការវិនិច្ឆ័យ» ។ ដំណើរការទាំងនេះមានសារសំខាន់ដើម្បី «ធានាឲ្យមានការជឿទុកចិត្តខាងផ្លូវច្បាប់និងតម្លាភាព» ដែលត្រូវផ្តល់កំណត់សម្គាល់ការចោទប្រកាន់ទៅលើភាគគីចុងចោទ ព្រមទាំងបង្កើតជាយុត្តិវិធីនៃការចោទប្រកាន់ស្រដៀងគ្នា ។

យ៉ាងណាមិញ នៅក្នុងដីកាដំណោះស្រាយ ឌុច សហចៅក្រមស៊ើបអង្កេតមិនបាននិយាយពី «បទបញ្ញត្តិឧក្រិដ្ឋកម្មដែលជាប់ពាក់ព័ន្ធ» និង «ការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ» ទាក់ទងនឹងដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាទេ ។ ជាក់ស្តែង ចៅក្រមមិនបានបង្ហាញថាតើ ឌុច ត្រូវទទួលខុសត្រូវចំពោះសហកម្មឧក្រិដ្ឋកម្មរួមឬក៏អត់ ។ បើទោះជាសហចៅក្រមស៊ើបអង្កេតមានសិទ្ធិបដិសេធការអះអាងរបស់សហព្រះរាជអាជ្ញា ប៉ុន្តែវិធានច្បាប់ចែងយ៉ាងច្បាស់ថារាល់ការសម្រេចចិត្តត្រូវតែភ្ជាប់ជាមួយមូលហេតុ ។ នេះគឺជាចំណុចមូលដ្ឋាននៃតួនាទីមួយក្នុងការវិនិច្ឆ័យទៅលើដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញានិងចៅក្រម ។ ដោយមើលរំលងទៅលើសេចក្តី

អះអាងនៅក្នុងដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ចៅក្រមស៊ើបអង្កេតបានបដិសេធនិងមិនអើពើជំហានសំខាន់នៃនីតិវិធីដែលចែងនៅក្នុងវិធានផ្ទៃក្នុង ។

ដូចដែលបានកំណត់ដោយច្បាប់អន្តរជាតិ សហកម្មឧក្រិដ្ឋកម្មរួមកើតមានឡើងនៅពេលដែលមានប្រជាជនពីរឬបីនាក់ប៉ុនប៉ងប្រព្រឹត្តឧក្រិដ្ឋកម្ម ដោយមានគោលបំណងឧក្រិដ្ឋកម្ម ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីផ្តល់ហេតុផលថា «ការកាត់ទោសជនដៃដល់ដែលប្រព្រឹត្តឧក្រិដ្ឋកម្មជាក់ស្តែងអាចនឹងមើលរំលងតួនាទីរបស់សហចារីដែលបានរួមគំនិតជាមួយជនដៃដល់ដែលអាចបង្កឲ្យមានអំពើឧក្រិដ្ឋកម្ម» ។ ការមើលរំលងនេះមានជាប់ពាក់ព័ន្ធនឹងអំពើឃោរឃៅផ្សេងទៀតដែលកើតមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅក្រោមទស្សនៈនេះ ដោយពិនិត្យទៅលើឧក្រិដ្ឋកម្ម បុគ្គលម្នាក់ៗអាចប្រព្រឹត្តឧក្រិដ្ឋកម្មជាមួយគ្នានិងតាមរយៈអ្នកដទៃដែលមានន័យថា ការទទួលខុសត្រូវរបស់បុគ្គលនីមួយៗត្រូវតែយកមកពិចារណា ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានយល់ឃើញថា «ទម្ងន់នៃចិត្តសាស្ត្រក្នុងការចូលរួមនៅក្នុងសហកម្មរួមជាញឹកញាប់គឺមិនស្រាល ឬពេលខ្លះមិនខុសពីទម្ងន់នៃអ្នកដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មទេ» ។

តុលាការអន្តរជាតិបានរកឃើញថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវតែសរសេរអំពីសហកម្មឧក្រិដ្ឋរួមយ៉ាងត្រឹមត្រូវដើម្បីផ្តល់កំណត់សម្គាល់នៃគោលបំណងរបស់ការចោទប្រកាន់ទៅលើភាគីចុងចោទនិងអង្គជំនុំជម្រះ ។ ដោយការខកខានមិនបាននិយាយពីដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានបន្សល់ទុកបទល្មើសសហកម្មឧក្រិដ្ឋកម្មរួម ដែលមិនទាន់មានការសម្រេចដែលធ្វើឲ្យដីកាដំណោះស្រាយមានសភាពមិនពេញលេញ អាស្រ័យហេតុនេះដីកានេះនៅខ្វះចន្លោះ ។

### ៣) សេចក្តីសម្រេចដើម្បីកំណត់វិសាលភាពនៃការ «វាយប្រហារ» ប្រឆាំងនឹងប្រជាជនស៊ីវិល

ធាតុផ្សំជាក់ស្តែងមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺជាវិសាលភាពនៃការវាយប្រហារយ៉ាងធ្ងន់ធ្ងរនិងជាប្រព័ន្ធ ។ នៅក្នុងដីកាដំណោះស្រាយដែលខុសពីដីកាសន្និដ្ឋានស្តាពររបស់សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេតបានកំណត់វិសាលភាពនៃការវាយប្រហារនៅមន្ទីរស-២១ ដោយអះអាងថា «ឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅមន្ទីរស-២១ បង្កើតជាការវាយប្រហារយ៉ាងធ្ងន់ធ្ងរប្រឆាំងនឹងប្រជាជនស៊ីវិលដែលត្រូវបានឃុំឃាំងនៅទីនោះ» ។ ការកំណត់នេះអាចកាត់បន្ថយអំណាចរបស់តុលាការក្នុងការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនិងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត ។ លើសពីនេះទៅទៀត ប្រសិនបើមានការបន្ធូរបន្ថយការចោទប្រកាន់លើករណី ឌុច នោះការកំណត់វិសាលភាពនឹងមិនមានសារសំខាន់ទេនៅក្រោមច្បាប់អន្តរជាតិហើយអាចនឹងមិនសមស្របចំពោះទស្សនៈនយោបាយដែរ ។

តុលាការអន្តរជាតិបានរកឃើញថា អត្ថន័យនៃ «ការវាយប្រហារ» និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានលក្ខណៈទូលំទូលាយ ។ ជាការពិត ការវាយប្រហារអាចត្រូវបានកំណត់ថាជាការធ្វើបាបទៅលើប្រជាជនស៊ីវិល ។ អាស្រ័យហេតុដូច្នេះអំពើរបស់ចុងចោទត្រូវតែចាត់ទុកជាផ្នែកមួយនៃការវាយប្រហារ ។

ដោយសង្កត់ទៅលើតួនាទីជាក់ស្តែងរបស់ ឌុច នៅមន្ទីរស-២១ ស្របតាមគម្រោងរបស់បក្សនិងឋានានុក្រមនៃមន្ទីរសន្តិសុខ ឌុច បានគ្រប់គ្រងគុកនេះពេញមួយរបបខ្មែរក្រហម ។ យោងទៅតាមតួនាទីនិងមុខតំណែងរបស់ ឌុច នៅក្នុងបក្ស វិសាលភាពនៃការវាយប្រហាររបស់បក្សកុម្មុយនីស្តកម្ពុជា និង ឌុច គឺជាផ្នែកមួយដែលយល់ដឹងពីគម្រោងរបស់បក្សយ៉ាងច្បាស់លាស់ព្រមទាំងតួនាទីជានាយករងនិងប្រធានមន្ទីរស-២១របស់ ឌុច ត្រូវបានចាត់ទុកថាជាផ្នែកមួយនៃការវាយប្រហារ ។ ប្រសិនបើឧក្រិដ្ឋកម្មទាំងអស់ដែលបានកើតឡើងនៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យមិនត្រូវបានរួមបញ្ចូលជាផ្នែកមួយនៃការវាយប្រហារទេ ដូច្នេះវានឹងមានសភាពមិនច្បាស់ក្នុងការបង្ហាញថា ឌុច មានជាប់ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរបស់របបកម្ពុជាប្រជាធិបតេយ្យដោយរបៀបណា ហើយហេតុអ្វីបានជាត្រូវកាត់ទោសតែ ឌុច មិនមែនប្រធានគុកផ្សេងទៀតក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីបទរំលោភបំពានទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិនៅក្នុងអង្គជំនុំជម្រះ ។

**ម៉ាហ្គារីតា ក្លារ៉េន**

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

*ថ្ងៃសុក្រ ទី១៩ ខែកញ្ញា ឆ្នាំ២០០៨*

# សេចក្តីប្រកាសព័ត៌មាន

*ទីស្តីការគណៈរដ្ឋមន្ត្រីបានចេញសេចក្តីប្រកាសព័ត៌មានដូចតទៅ ៖*

*អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានដំណើរការល្អប្រសើរ ហើយកំពុងតែបន្តទទួលបាននូវជោគជ័យជាបន្តបន្ទាប់ បំពេញកាតព្វកិច្ចរបស់ខ្លួនដើម្បីផ្តល់យុត្តិធម៌ដល់ប្រជាពលរដ្ឋកម្ពុជាដែលបានទទួលរងអំពើឧក្រិដ្ឋកម្មប្រមាណជាង៣០ឆ្នាំកន្លងមក ។ ជនជាប់ចោទទាំង៥រូប ដែលមានឈ្មោះនៅក្នុងបញ្ជីត្រូវចោទប្រកាន់ដំបូងកាលពីខែកក្កដា ឆ្នាំ២០០៧ បានត្រូវចាប់ខ្លួនយកមកឃុំឃាំង តាមនីតិវិធីរង់ចាំការស៊ើបអង្កេតការចោទប្រកាន់ ហើយនឹងការកាត់ក្តីនៅក្នុងរយៈវេលាតែ៤ខែតែប៉ុណ្ណោះ ដោយពុំមានឧប្បត្តិហេតុអ្វីឡើយ ។ ដំណើរការស៊ើបអង្កេតមានដំណើរការប្រព្រឹត្តទៅដោយភាពរលូន ហើយដំណើរការជំនុំជម្រះក្តីជនជាប់ចោទទី១ត្រូវបានរំពឹងថានឹងធ្វើឡើងនៅឆ្នាំ២០០៩ ខាងមុខ ។ ប្រៀបធៀបទៅនឹងតុលាការជំនុំជម្រះដូចគ្នា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានដំណើរការលឿនជាង អស់ថវិកាតិចជាងគួរឲ្យកត់សម្គាល់មានតម្លាភាព មានការចូលរួមយ៉ាងសកម្មពីសាធារណជន ហើយជាពិសេសពីជនរងគ្រោះខ្លួនគេតែម្តង ។ ចាប់តាំងពីចុងខែកក្កដាមក មានទំនាក់ទំនងនិងការប្តូរលិខិតស្នាមរវាងការិយាល័យកិច្ចការច្បាប់នៃអង្គការសហប្រជាជាតិ ហើយ នឹងឯកឧត្តម* **សុខ អាន** *ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកនៃទីស្តីការគណៈរដ្ឋមន្ត្រីនិងជាប្រធានក្រុមការងារនៃរាជរដ្ឋាភិបាលដើម្បីសាលាក្តីខ្មែរក្រហមស្តីអំពីបណ្តឹងដែលបានចោទឡើងពាក់ព័ន្ធទៅនឹងមន្ត្រីរដ្ឋបាលនិងចៅក្រមផ្នែកកម្ពុជានៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ បណ្តឹងទាំងនេះត្រូវបាននាំយកផ្ទាល់ដៃទៅអង្គការសហប្រជាជាតិក្រុងញូវយ៉កដោយមន្ត្រីអង្គការសហប្រជាជាតិ ។ ទីស្តីការគណៈរដ្ឋមន្ត្រីសូមគូសបញ្ជាក់ថា ៖ សេចក្តីព្រមព្រៀងរវាងអង្គការសហប្រជាជាតិហើយនឹងរាជរដ្ឋាភិបាលកម្ពុជាស្តីអំពីការយកមកកាត់ទោសក្រោមច្បាប់កម្ពុជា ក្នុងអំពើឧក្រិដ្ឋកម្មប្រព្រឹត្តទៅនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ (ឬខ្មែរក្រហម) ខែតុលា ឆ្នាំ២០០៦ បានដាក់ការទទួលខុសត្រូវចំពោះការគ្រប់គ្រងរដ្ឋបាលលើផ្នែកមន្ត្រីនិងចៅក្រមកម្ពុជាមកលើរាជរដ្ឋាភិបាលកម្ពុជា ។ រហូតមកដល់បច្ចុប្បន្ននេះ ពុំមានការចោទប្រកាន់ណាមួយត្រូវបានដាក់ជូនទៅឲ្យអាជ្ញាធរមានសមត្ថកិច្ចរបស់កម្ពុជាឡើយ ។ ព្រមជាមួយនោះដែរ មានកិច្ចការមិនសមស្របទៅនឹងនីតិវិធី ដូចជាការចោទប្រកាន់ចំឈ្មោះចំពោះបុគ្គលដោយពុំមានផ្តល់ព័ត៌មាននៃការចោទប្រកាន់នោះទៅឲ្យជនដែលត្រូវបានចោទប្រកាន់ដែលជានីតិវិធីគតិយុត្តិជាក់ស្តែង ។*

*ឯកឧត្តម* **សុខ អាន** *ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកនៃទីស្តីការគណៈរដ្ឋមន្ត្រីបានសន្យាជាឧឡារិកច្រើនលើកច្រើនសាមកហើយថា បើសិនណាការប្តឹងផ្តល់ចោទប្រកាន់ទាំងនេះ ឬការប្តឹងផ្តល់ចោទប្រកាន់ដទៃទាំងឡាយទៀតត្រូវបានដាក់ជូនដល់អាជ្ញាធរសមត្ថកិច្ចកម្ពុជាតាមនីតិវិធីមានស្រាប់ នោះវិធានការជាក់ស្តែងសមស្របនឹងត្រូវអនុវត្តយ៉ាងពិតប្រាកដ ។*

*នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៨ ឯកឧត្តម* **សុខ អាន** *ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកនៃទីស្តីការគណៈរដ្ឋមន្ត្រី បានចេញសារាចរណែនាំស្តីពីការរាយការណ៍ប្រព្រឹត្តខុសក្រមសីលធម៌ កំណត់យន្តការដើម្បីឆ្លើយតប និងដោះស្រាយរាល់បណ្តឹងចោទប្រកាន់ដែលអាជ្ញាធរសមត្ថកិច្ចកម្ពុជាបានទទួល ហើយបច្ចុប្បន្ននេះ ឯកឧត្តម* **សុខ អាន** *ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកនៃទីស្តីការគណៈរដ្ឋមន្ត្រីកំពុងអនុវត្តខ្លឹមសារនៃសារាចរណែនាំ ដូចបានជម្រាបខាងលើចំពោះបណ្តឹងចោទប្រកាន់ទី១ ដែលទើបបានទទួលថ្មីៗនេះ ។ រាល់ចំណាត់ការទៅលើបណ្តឹងដែលបានទទួលនឹងត្រូវបានដំណើរការសមស្របតាមនីតិវិធីគតិយុត្តិ ធ្វើយ៉ាងណាដើម្បីកាត់បន្ថយជាអតិបរមានូវអ្វីដែលអាចជាឧបសគ្គដល់ដំណើរការដ៏ប្រពៃនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលជាតុលាការចម្រុះទី១ក្នុងប្រវត្តិតុលាការអន្តរជាតិ កាត់ក្តីឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍ ។* **ទីស្តីការគណៈរដ្ឋមន្ត្រី**

# សត្រូវខាងក្នុងនិងខាងក្រៅ : បទពិសោធន៍ឆ្លងកាត់សម័យខ្មែរក្រហមរបស់ជនជាតិវៀតណាម

ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ចំនួនប្រជាជនវៀតណាមនៅតែស្ថិតក្រោមការស្រាវជ្រាវនៅឡើយ ។ សហគមន៍អ្នកសិក្សាបានផ្តល់សេចក្តីលម្អិតខ្លះៗទាក់ទងទៅនឹងម៉ាក្រូព័ត៌មានស្តីអំពីគោលនយោបាយរបស់ខ្មែរក្រហមមកលើពូជសាសន៍វៀតណាមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែប្រធានបទនេះកម្រនឹងទទួលបានការចាប់អារម្មណ៍ពីសំណាក់ការស៊ើបអង្កេតរបស់អ្នកស្រាវជ្រាវណាស់ ។ បើពិចារណាទៅលើការវាយតម្លៃជាពិសេសលើទំនាក់ទំនងផ្នែកប្រវត្តិសាស្ត្រ នយោបាយ និងជាតិសាសន៍រវាងប្រជាជនខ្មែរនិងវៀតណាម គឺថាសហគមន៍វៀតណាមត្រូវទទួលការតាមដានយ៉ាងតឹងរ៉ឹងបំផុតរបស់កម្ពុជាប្រជាធិបតេយ្យដើម្បីចាប់ខ្លួន ។ អត្ថបទនេះមានបំណងអនុវត្តនូវមុខងារពីរយ៉ាងទាក់ទងទៅនឹងការចែករំលែកនូវរឿងរ៉ាវរបស់ជនជាតិវៀតណាម ១) បង្ហាញពីការយល់ដឹងដែលមានអំពីទំនាក់ទំនងរបស់ខ្មែរក្រហមជាមួយនឹងរដ្ឋាភិបាលនិងប្រជាជនវៀតណាម ២) ចែករំលែករឿងរ៉ាវផ្ទាល់ខ្លួនរបស់ជនជាតិវៀតណាមប្រាំពីរគ្រួសារដែលរស់នៅក្នុងសម័យខ្មែរក្រហម ។

## ស្ថានភាពប្រវត្តិសាស្ត្រ

ទំនាក់ទំនងប្រវត្តិសាស្ត្ររបស់កម្ពុជានិងវៀតណាមមានសភាពច្របូកច្របល់បន្តិច ។ អ្នកស្រាវជ្រាវមួយចំនួនបានធ្វើការពិភាក្សាទៅលើភាពអយុត្តិធម៌ជាច្រើនកាលពីអតីតកាលដែលប្រព្រឹត្តដោយមេដឹកនាំខ្មែរនិងវៀតណាម ។ ក្នុងឧប្បត្តិហេតុមួយនៅឆ្នាំ១៧៥១ ព្រះមហាក្សត្រខ្មែរបានបញ្ជាឲ្យសម្លាប់រង្គាលជនជាតិវៀតណាមទាំងអស់ដែលរស់នៅក្នុងទឹកដីកម្ពុជា ។ ឧប្បត្តិហេតុមួយទៀត គឺក្នុងរាជវង្សវៀតណាម ង្វៀង ព្រះចៅអធិរាជ មិញម៉ាង បានកប់ជនជាតិខ្មែរទាំងរស់ដោយទុកត្រឹមតែក្បាលមកក្រៅប៉ុណ្ណោះ ដើម្បីបង្ហាញថាជាមុមចង្ក្រានសម្រាប់ដាំស្ល ។ ជាច្រើនសតវត្សរ៍ក្រោយមក ខ្មែរក្រហមបានសរសេរអំពីភាពសាហាវឃោរឃៅទាំងនេះចូលក្នុងសៀវភៅខ្មៅមួយដែលចេញផ្សាយក្នុងខែកញ្ញា ឆ្នាំ១៩៧៨ ក្រោមចំណងជើងថា «ការពិតនិងភស្តុតាងនៃសកម្មភាពឈ្លានពាននិងលេបត្របាក់ទឹកដីរបស់ជនជាតិវៀតណាមមកលើកម្ពុជា» ។ ឯកសារទាំងអស់នោះចង់បញ្ជាក់ថា សកម្មភាពរបស់ មីញម៉ាង ជា «ឧក្រិដ្ឋកម្មដ៏កាចសាហាវ» ហើយជនជាតិវៀតណាមត្រូវអ្នកទាំងនោះចាត់ទុកជា «យួនជាអ្នកធ្វើទារុណកម្ម» ។ ពាក្យប្រមាថដែលហៅថា «យួន» នេះចង់រៀបរាប់ពីការលេចមុខរបស់ជនជាតិវៀតណាមក្នុងសៀវភៅខ្មៅ និងដើម្បីបញ្ចេញនូវការខឹងសម្បាររបស់ខ្មែរក្រហមចំពោះអំពើខុសឆ្គងកាលពីអតីតរបស់ជនជាតិវៀតណាម ។

កម្ពុជានិងវៀតណាមក៏ធ្លាប់មានទំនាស់ទឹកដីស្តីពីដីសណ្តទន្លេមេគង្គនៅវៀតណាម ដែលជាតំបន់មួយប្រជាជនខ្មែរគ្រប់រូបជឿជាក់ថាជាទឹកដីដែលវៀតណាមដណ្តើមពីកម្ពុជាទៅ ។ ខ្មែរក្រហមបានលើកឡើងពីអំពើចោរកម្មនេះក្នុងសៀវភៅខ្មៅក្រោមចំណងជើងថា វៀតណាមដណ្តើមយកព្រៃនគរ (សព្វថ្ងៃហៅថាសៃហ្គនឬក្រុងហូជីមិញ) និងតំបន់ទំនាបមេគង្គ (កម្ពុជាក្រោម) ដើម្បីធ្វើជាភស្តុតាងបញ្ជាក់ពីសកម្មភាពរបស់ជនជាតិវៀតណាមថាជា «ជនឈ្លានពាននិងអ្នកលេបយកទឹកដី» ។ បើយោងទៅតាមអ្នកស្រាវជ្រាវតំបន់ភូមិភាគអាស៊ីអាគ្នេយ៍ អាឡិច ហីនតុន បានឲ្យដឹងថា ជម្លោះទឹកដីនេះបានធ្វើឲ្យជនជាតិខ្មែរទាំងអស់សម្គាល់ថាជនជាតិវៀតណាមគឺជាបិសាច ។ ទោះបីជាទាំងជនជាតិថៃនិងវៀតណាមបានលេបយកទឹកដីកម្ពុជាក៏ដោយ ក៏ជនជាតិវៀតណាមនៅតែត្រូវបានខ្មែរចាត់ទុកថាជាជនជាតិដែលមានគ្រោះថ្នាក់បំផុត ។ ចុងបញ្ចប់ ជនជាតិខ្មែរក៏មានផ្នត់គំនិតមួយថាជនជាតិវៀតណាមជា «សត្រូវប្រវត្តិសាស្ត្រ» របស់ខ្លួន ។

ការធ្វើចំណាកស្រុកនិងការតាំងទីលំនៅរបស់ជនជាតិវៀតណាមនៅក្នុងទឹកដីកម្ពុជាតាំងពីយូរលង់ណាស់មកហើយ ក៏ធ្វើឲ្យមានភាពតានតឹងខាងវណ្ណៈរវាងខ្មែរនិងវៀតណាមផងដែរ ។ ប្រជាជនវៀតណាមខ្លះដែលរស់នៅក្នុងរបបកម្ពុជាប្រជាធិប

គេយល់ថ្លាប់ជាអ្នកចងការប្រាក់ ដែលជាមុខរបរមួយគេងប្រវ័ញ្ចពីអ្នកក្រ ។ ជនជាតិភាគតិចវៀតណាមជាច្រើនបានបម្រើការងារជាអ្នកដឹកនាំសំខាន់ៗក្នុងជួរកងទ័ពនិងរដ្ឋាភិបាលកម្ពុជា ដែលទាំងនេះជាហេតុធ្វើឲ្យមានការបែងចែកវណ្ណៈរវាងជនជាតិខ្មែរនិងវៀតណាម ។ យ៉ាងណាមិញ ជនជាតិភាគតិចវៀតណាមនៅក្នុងប្រទេសកម្ពុជាក៏ជួបប្រទះនូវការសម្លាប់រង្គាលទូទាំងប្រទេសផងដែរ ។ នៅឆ្នាំមុនពេលដែលខ្មែរក្រហមកាន់កាប់អំណាច ជនជាតិភាគតិចវៀតណាមក៏ទទួលរងការវាយប្រហារជាច្រើនលើកពីសំណាក់រដ្ឋាភិបាលលន់ នល់ ។ ចាប់ពីខែមីនា រហូតដល់ខែមេសា ឆ្នាំ១៩៧០ របប លន់ នល់ បានសម្លាប់រង្គាល ដែលគោលដៅសំខាន់ផ្តោតទៅលើជនជាតិវៀតណាមរស់នៅក្នុងទីកដីកម្ពុជា បណ្តាលឲ្យមានមនុស្សស្លាប់ជាងបួនពាន់នាក់ ។ យោងទៅតាមអតីតព្រះមហាក្សត្រខ្មែរព្រះបាទនរោត្តម សីហនុ «ក្នុងឆ្នាំ១៩៦៩ ជនជាតិភាគតិចវៀតណាមក្នុងប្រទេសកម្ពុជាមានជាង៤សែននាក់ ។ ក្រោយពីរដ្ឋប្រហាររបស់លន់ នល់នៅឆ្នាំ១៩៧០ (ទម្លាក់សម្តេចនរោត្តមសីហនុចេញពីតំណែង) លន់ នល់ និងអ្នកគាំទ្ររបបរបស់គាត់បានលុបបំបាត់និងនិរទេសជនជាតិយួនយ៉ាងហោចណាស់អស់ជិតពាក់កណ្តាលនៃចំនួនប្រជាជនវៀតណាមទាំងអស់នោះដើម្បីបញ្ជូនទៅប្រទេសវៀតណាមខាងត្បូងវិញ ។ ជាការពិតណាស់ ទំនាក់ទំនងរវាងជនជាតិខ្មែរនិងវៀតណាមគឺពិតជាត្រូវបានបំផ្លិចបំផ្លាញដោយសារការមិនជឿទុកចិត្តគ្នា ទំនាស់និងអំពើហិង្សាផ្សេងៗ ។

## ទំនាក់ទំនងផ្នែកនយោបាយរវាងខ្មែរក្រហមនិងគណបក្សពលករវៀតណាម

ខ្មែរក្រហមនិងគណបក្សពលករវៀតណាមក៏មានទំនាក់ទំនងនយោបាយច្របូកច្របល់ជាមួយគ្នាផងដែរ ។ ដោយសារតែទាំងប្រទេសកម្ពុជានិងវៀតណាមសុទ្ធតែស្ថិតក្រោមការគ្រប់គ្រងរបស់គណបក្សកុម្មុយនីស្ត ដូច្នេះវាអាចមានលទ្ធភាពដែរក្នុងការក្លាយជាសម្ព័ន្ធមិត្តផណ្តួចិន ។ មុនពេលដែលខ្មែរក្រហមឡើងកាន់កាប់អំណាច លេខាធិការនៃគណៈកម្មការមជ្ឈិមរបស់គណបក្សពលករវៀតណាមលោក ហ័ង អាញ់ បានបញ្ជាក់ពីចំណាប់អារម្មណ៍របស់ខ្លួននៅក្នុងប្រទេសកម្ពុជា ព្រមទាំងបានប្រកាសក្នុងអង្គប្រជុំគណៈកម្មការឆ្នាំ១៩៧១ ថា «គណបក្សពលករវៀតណាមយើងគួរតែពង្រឹងមូលដ្ឋានបដិវត្តន៍ក្នុងប្រទេសកម្ពុជា ហើយដឹកនាំប្រទេសនេះតាមមាគ៌ាសង្គមនិយម ។ នេះជាគោលនយោបាយរបស់គណបក្សយើង» ។ សេចក្តីថ្លែងការណ៍របស់ ហ័ង អាញ់ គឺចង់បង្ហាញពីបំណងភ្ជាប់ស្ពានមេត្រីរវាងវៀតណាមនិងខ្មែរក្រហម ។ គណបក្សពលករវៀតណាមចង់បង្កើតចំណងមិត្តភាព អាន់-អេម (ភាសាវៀតណាម) ឬ «បងប្អូន» ជាមួយខ្មែរក្រហម ក្នុងន័យថា វៀតណាមនឹងអាចក្លាយជាបងធំរបស់ខ្មែរក្រហមបាន ។ ចំណែកឯមេដឹកនាំខ្មែរក្រហមនិងបក្សកុម្មុយនីសកម្ពុជាហាក់ដូចជាមានចិត្តទទួលយកបំណងរបស់គណបក្សពលករវៀតណាម ។ ប៉ុល ពត បានប្រកាសក្នុងអង្គប្រជុំអ្នកយកព័ត៌មានវៀតណាមឆ្នាំ១៩៧៥ ថា ៖

*«នៅពេលទំនាក់ទំនងមិត្តភាពនិងសាមគ្គីភាពរវាងកម្ពុជាប្រជាធិបតេយ្យនិងវៀតណាមបានរឹងប៉ឹង នោះការធ្វើបដិវត្តន៍ក្នុងប្រទេសរបស់យើងក៏អាចប្រព្រឹត្តទៅបានយ៉ាងពេញលេញ ។ វាគ្មានជម្រើសផ្សេងទៀតទេ ។ អ៊ីចឹងហើយបានជាយើងត្រូវតែគោរពនូវគោលការណ៍នេះ យើង (ខ្មែរក្រហម) បានពិចារណាថា គណបក្សទាំងពីរនិងខ្លួនយើងផ្ទាល់គួរតែថែរក្សានូវសាមគ្គីភាពនិងភាពជាបងប្អូននេះឲ្យបានស្ថិតស្ថេរ ហើយត្រូវប្រាកដថាទំនាក់ទំនងនេះនឹងលូតលាស់យ៉ាងរឹងមាំជារៀងរាល់ថ្ងៃ» ។*

ទោះបីជាមានគម្រោងចង់ភ្ជាប់សម្ពន្ធ័មិត្តជាមួយផណ្តួចិននេះហើយក៏ដោយ ក៏ទំនាក់ទំនងរវាងគណបក្សពលករវៀតណាមនិងខ្មែរក្រហមបានបែកបាក់ក្នុងពេលដែលខ្មែរក្រហមឡើងកាន់អំណាចដែរ ។ ដោយសារតែមិនពេញចិត្តនឹងមេដឹកនាំវៀតណាមនិងរបៀបវីរៈជាបិតុនិយមរបស់ ហ័ង អាញ់ គឺបានធ្វើឲ្យខ្មែរក្រហមគិតថានឹងជ្រើសយកការធ្វើបដិវត្តន៍ដោយឯករាជ្យសម្រាប់កម្ពុជាប្រជាធិបតេយ្យ ។ ប៉ុល ពត បានធ្វើការប្រកែកជាបន្ទាន់ថា «បងប្អូនវៀតណាមមិនគួរជ្រៀតជ្រែកក្នុងការសម្រេចគោលការណ៍របស់បក្សកុម្មុយនីសកម្ពុជានោះទេ» ។ តាមការពិតនៅក្នុងឯកសាររបស់បណ្ណសារដ្ឋានសហពន្ធ័សូវៀតបានលាតត្រដាងថា ប៉ុល ពត គ្រាន់តែធ្វើសេចក្តីថ្លែងការណ៍សន្ទាចំពោះមុខអ្នកយកព័ត៌មានវៀតណាមដើម្បី «កាត់បន្ថយសម្ពាធ» ចេញពី

ភក្តីភាពរបស់វៀតណាមចំពោះបក្សកុម្មុយនីស្តកម្ពុជា និងដើម្បី «បោកបញ្ឆោត» ជនជាតិវៀតណាមឲ្យជឿជាក់ថា ខ្មែរក្រហមពិតជាធ្វើតាមបន្ទាប់របស់វៀតណាមមែន ។ គម្រោងចង់ធ្វើការសម្រេចចិត្តដោយខ្លួនឯងរបស់ខ្មែរក្រហមបានលេចឡើងយ៉ាងច្បាស់ក្នុងឆ្នាំ១៩៧៧ នៅពេលដែល ប៉ុល ពត បដិសេធមិនចូលរួមអង្គប្រជុំរវាងមេដឹកនាំកម្ពុជា-វៀតណាម តាមការស្នើឡើងរបស់ឧបនាយករដ្ឋមន្ត្រីក្រសួងការបរទេសវៀតណាម ហ័ង វ៉ាន់ឡយ ។

ការវិវាទផ្នែកនយោបាយបានប្រែក្លាយទៅជាទំនាស់ប្រដាប់អាវុធយ៉ាងឆាប់រហ័ស ។ ក្នុងពាក់កណ្តាលឆ្នាំ១៩៧៧ ការវាយប្រហាររវាងកម្ពុជាប្រជាធិបតេយ្យនិងវៀតណាមនៅតាមព្រំដែនបានផ្ទុះឡើង ។ ទោះបីជាទំនាស់ព្រំដែនបានកើតឡើងជាយូរឆ្នាំមកហើយក៏ដោយ នៅក្នុងឆ្នាំ១៩៧៧ទំនាស់ព្រំដែននេះបានរីករាលដាលកាន់តែធំឡើងៗ ហើយក្លាយទៅជាសង្គ្រាមដ៏ធំមួយរវាងវៀតណាមនិងកម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងខែឧសភា ឆ្នាំ១៩៧៨ មេដឹកនាំកម្ពុជាប្រជាធិតេយ្យបានធ្វើសេចក្តីប្រកាសជាសាធារណៈតាមវិទ្យុ ដោយជំរុញឲ្យជនជាតិខ្មែរម្នាក់សម្លាប់ទាហានវៀតណាមឲ្យបាន៣០នាក់សម្រាប់ជនជាតិកម្ពុជាដែលទទួលរងការឈឺចាប់គ្រប់រូប ។ ខ្មែរក្រហមក៏បានប្រើប្រាស់ការឃោសនាជាលាយលក្ខណ៍អក្សរដើម្បីផ្សព្វផ្សាយយុទ្ធសាស្ត្ររបស់ខ្លួនប្រឆាំងនឹងវៀតណាមផងដែរ ដូចជានៅក្នុងទស្សនាវដ្តីឆ្នាំ១៩៧៨ ដែលមានចំណងជើងថា សៀវភៅខ្មៅ ៈ ការពិតនិងភ័ស្តុតាងនៃសកម្មភាពឈ្លានពាននិងលេបត្របាក់ទឹកដីរបស់ជនជាតិវៀតណាមមកលើកម្ពុជា ។

ទោះបីជាទំនាស់ព្រំដែនបានធ្វើឲ្យមានការប៉ះពាល់យ៉ាងខ្លាំងចំពោះទំនាក់ទំនងដែលធ្លាប់មានការប្រេះស្រាំរវាងកម្ពុជាប្រជាធិបតេយ្យនិងវៀតណាមកន្លងមកហើយក៏ដោយ ក៏ខ្មែរក្រហមនៅតែគិតថា មូលហេតុដែលធ្វើឲ្យមានការបែកបាក់នេះគឺដោយសារតែគំនិតបិតុនិយមរបស់គណបក្សពលករវៀតណាមទាំងស្រុង ៈ

«មូលហេតុនៃសង្គ្រាមរវាងកម្ពុជានិងវៀតណាមគឺមិនមែនត្រឹមតែបញ្ហាព្រំដែនតែមួយនោះទេ ។ មូលហេតុចម្បងនៃសង្គ្រាមនេះគឺបណ្តាលមកពីការអនុវត្តគោលនយោបាយរបស់វៀតណាមដើម្បីបង្ហាញពង្រីកអំណាចនិងគំនិតបិតុនិយមរបស់ខ្លួន ដោយប្រើគ្រប់វិធីទាំងអស់ដូចជា ប្រើប្រាស់ការលួងលោម និងធម៌ត្រជាក់ដណ្តើមយកបក្ស កងទ័ពនិងរដ្ឋអំណាច ក៏ដូចជាប្រើប្រាស់យុទ្ធសាស្ត្រកងទ័ពដ៏សាហាវឃោរឃៅដូចអ្វីដែលវៀតណាមបានធ្វើមកលើកម្ពុជានាពេលបច្ចុប្បន្ននេះអ៊ីចឹង» ។

សេចក្តីថ្លែងការណ៍របស់ខ្មែរក្រហមបានលាតត្រដាងនូវការសង្ស័យរបស់ខ្លួនជាយូរណាស់មកហើយដែលថា វៀតណាមគ្រាន់តែប្រើប្រាស់សំបកក្រៅជាសហព័ន្ធឥណ្ឌូចិនដើម្បីឈ្លានពាននិងគាបសង្កត់ប្រទេសកម្ពុជាតែប៉ុណ្ណោះ ។ ប៉ុល ពត បានរំពឹកថា ការភ្ជាប់ខ្លួនជាមួយសហព័ន្ធឥណ្ឌូចិននឹងអាចនាំឲ្យជនជាតិវៀតណាមរាប់សែននាក់ចូលមករស់នៅក្នុងទឹកដីកម្ពុជា ហើយវានឹងធ្វើឲ្យចំនួនប្រជាជនខ្មែរចុះថយរហូតយើងក្លាយជាជនជាតិភាគតិចនៅក្នុងទឹកដីរបស់ខ្លួនមិនខាន ។ យ៉ាងណាមិញ នៅក្នុងឯកសាររបស់ខ្មែរក្រហមក៏បានបញ្ជាក់ពីការព្រួយបារម្ភដូចគ្នានេះដែរ ដោយសរសេរថា «វៀតណាមនឹងនាំជនជាតិរបស់ខ្លួនពី១លានទៅ២លាននាក់មករស់នៅក្នុងទឹកដីកម្ពុជារៀងរាល់ឆ្នាំ ។ បន្ទាប់មកយើងនឹងបាត់បង់ទឹកដីរបស់យើង ហើយពេលនោះពូជសាសន៍របស់យើងនឹងត្រូវរលាយបាត់ទាំងស្រុង» ។ ចេញពីអំណះអំណាងនេះ យើងអាចមើលឃើញពីស្មារតីរបស់ខ្មែរក្រហមក្នុងការការពារទឹកដីនិងពូជសាសន៍របស់ខ្លួន ។

ក្រោយមក ភាពតានតឹងរវាងខ្មែរក្រហមនិងវៀតណាមបានធ្វើឲ្យបក្សកុម្មុយនីស្តកម្ពុជាមានអារម្មណ៍ស្អប់ជនជាតិវៀតណាម ។ ដោយសារតែមានការភ័យខ្លាចចំពោះការជ្រៀតចូលរបស់ជនជាតិវៀតណាមក្នុងបក្សកុម្មុយនីស្តកម្ពុជា ធ្វើឲ្យខ្មែរក្រហមចាប់ផ្តើមធ្វើការសម្លាប់រង្គាលនូវសមាជិកបក្សដែលជាប់សង្ស័យថាក្បត់បក្សនិងគាំទ្រវៀតណាម ហើយមានជនរងគ្រោះដទៃទៀតរួមមានអ្នកដែលធ្លាប់ហ៊ឹកហ៊ឺនវិជ្ជាជីវៈនិងរស់នៅក្រៅប្រទេសឬក៏ជាប់សាច់ឈាមជាមួយអ្នកដែលមិនមែនជាខ្មែរ ។ ខ្មែរក្រហមបានធ្វើការតាមដានទៅលើប្រវត្តិរូបរបស់សមាជិកបក្សរបស់ខ្លួនទាំងថ្មីទាំងចាស់គ្មានចន្លោះអ្នកណាម្នាក់ឡើយ ។ នៅក្នុងសេចក្តីថ្លែងការណ៍ចំពោះគណបក្សពលករដាណឺម៉ាកក្នុងឆ្នាំ១៩៧៨ អគ្គលេខាធិការខ្មែរក្រហម នួន ជា បានធ្វើការពន្យល់ថា

ការបោសសម្អាតបក្សយ៉ាងហួសហេតុនេះគឺជាអត្ថិភាពចម្បងបំផុតរបស់ខ្មែរក្រហម ។ នួន ជា ប្រកាសទៀតថា «យើងមិនព្រួយបារម្ភចំពោះការវាយប្រហាររបស់កងទ័ពពីខាងក្រៅទេ ។ អ្វីដែលយើងបារម្ភខ្លាំងបំផុតគឺដង្កូវក្នុងសាច់ឯងទៅវិញ» ។

អារម្មណ៍ស្អប់គុំកួនបានឈានដល់កំម្រិតខ្ពស់បំផុតក្នុងឆ្នាំ១៩៧៨ ដែលធ្វើឲ្យមានការសម្លាប់យ៉ាងរង្គាលនៅភូមិភាគបូព៌ា ។ មុនពេលដែលមានការសម្លាប់រង្គាលនេះ ខ្មែរក្រហមកំពុងតែប្រឈមមុខនឹងការវាយប្រហារជាបន្តបន្ទាប់ពីកងទ័ពវៀតណាមនៅតាមបណ្តោយព្រំប្រទល់ភូមិភាគបូព៌ា ។ ការធ្វើសង្គ្រាមចាញ់វៀតណាមបានបណ្តាលឲ្យ (អង្គការខ្មែរក្រហម) ចោទប្រកាន់ទៅលើកម្មាភិបាលខ្មែរក្រហមភូមិភាគបូព៌ាថាចូលដៃចូលជើងជាមួយវៀតណាម ។ យោងតាម ប៉ុល ពត ថា «ភូមិភាគបូព៌ាគឺបានរួមសហការជាមួយយួន ហើយបានអនុញ្ញាតឲ្យយួនឈ្លានពានទឹកដី ។ ដូច្នេះមានតែយើងធ្វើសង្គ្រាមនៅខាងក្រោយឲ្យរួចរាល់សិនដើម្បីសម្អាតខ្លួនយើងឲ្យជ្រះស្រឡះមុននឹងយើងអាចយកឈ្នះសង្គ្រាមនៅពេលខាងមុខ ។ ចំពោះនរណាម្នាក់ដែលចូលដៃជាមួយយួនត្រូវតែចាប់ខ្លួនទាំងអស់» ។ អង្គការបានធ្វើការសម្លាប់រង្គាលប្រជាជនភូមិភាគបូព៌ាដែលមាន «ក្បាលយួន-ខ្លួនខ្មែរ» ជាង១,៥លាននាក់ ដើម្បីដាក់ទោសកម្មាភិបាលខ្មែរក្រហមភូមិភាគបូព៌ាចំពោះអំពើក្បត់របស់ខ្លួន ។ ការសម្លាប់រង្គាលបានបណ្តាលឲ្យមានការចាប់ខ្លួននិងការសម្លាប់មនុស្សច្រើនរាប់មិនអស់ ក៏ដូចជាខ្មែរក្រហមមួយចំនួនដែលភៀសខ្លួនទៅប្រទេសវៀតណាមផងដែរ ។

## ជនជាតិភាគតិចវៀតណាមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ភាពតានតឹងផ្នែកនយោបាយរវាងខ្មែរនិងវៀតណាមបានធ្វើឲ្យមានបញ្ហាដល់ជនជាតិភាគតិចវៀតណាមដែលរស់នៅក្នុងកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅពេលដែលខ្មែរក្រហមឡើងកាន់កាប់អំណាចនៅខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានរៀបចំផែនការយ៉ាងល្អិតល្អន់ក្នុងការជម្លៀសជនជាតិភាគតិចវៀតណាមជាង១៥០.០០០នាក់ចេញពីទឹកដីកម្ពុជា ។ ការជម្លៀសនេះបាននាំឲ្យជនភៀសខ្លួនវៀតណាមជាច្រើនពាន់នាក់ចូលទៅរស់នៅខេត្តដុងថាប អានយ៉ាង និងខេត្តតាយនិញ ។ ក្នុងខែកញ្ញា ឆ្នាំ១៩៧៥ អង្គការបានធ្វើការឡោមព័ទ្ធជនជាតិវៀតណាមមួយចំនួនដែលរស់នៅប្រទេសកម្ពុជាដោយជោគជ័យ ហើយបាននិរទេសអ្នកទាំងនោះគេឲ្យទៅកាន់ប្រទេសវៀតណាមវិញ ។ នៅក្នុងសៀវភៅខ្មៅ អង្គការទម្លាក់កំហុសទៅលើជនជាតិវៀតណាមដោយសរសេរថា «ជនជាតិវៀតណាមបានជ្រៀតចូលទឹកដីកម្ពុជា ហើយរស់នៅដោយលួចលាក់ក្នុងចំណោមប្រជាជនខ្មែរ» ។ អ្នកសិក្សាស្រាវជ្រាវនៅតំបន់អាស៊ីអាគ្នេយ៍ លោក រ៉មស៊ីស អាម៉ែរ បានធ្វើការកំណត់ចំនួនប្រជាជនវៀតណាមដែលនៅសេសសល់ គឺមានប្រហែលជា៣ម៉ឺននាក់ក្រោយពីការជម្លៀសពីឆ្នាំ១៩៧៥ ដែលខុសពីការគិតរបស់ លោក អាឡិច ហ៊ិនតុន ដែលថាសល់ប្រហែលតែ១ម៉ឺននាក់ប៉ុណ្ណោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ជនជាតិភាគតិចវៀតណាមដែលនៅសេសសល់តិចតួចបំផុតក្នុងរបបកម្ពុជាប្រជាធិបតេយ្យភាគច្រើនដោយសារតែគេចង់រស់នៅជាមួយដៃគូខ្មែរក្រហមរបស់គេដែលជាជនជាតិខ្មែរ ម្យ៉ាងទៀតក៏ដោយសារតែជនជាតិវៀតណាមមិនចង់ចាកចេញពីប្រទេសដែលគេធ្លាប់ចាប់កំណើតនិងធំដឹងក្តីនោះទេ ។ ដូច្នេះ ជនជាតិវៀតណាមទាំងអស់បានក្លាយជាគោលដៅដែលខ្មែរក្រហមទុកសម្រាប់ធ្វើបាបនៅពេលក្រោយ ។

ចាប់ផ្តើមពីពាក់កណ្តាលឆ្នាំ១៩៧៦ អង្គការបានធ្វើការហាមប្រាមជនជាតិវៀតណាមមិនឲ្យចាកចេញពីប្រទេសនេះទេ ។ ប៉ុន្តែនៅពាក់កណ្តាលឆ្នាំ១៩៧៧ ពេលដែលមានជម្លោះព្រំដែន ខ្មែរក្រហមបានធ្វើការរឹតបន្តឹងយ៉ាងខ្លាំងចំពោះជនជាតិភាគតិចវៀតណាមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយក្រោយមកក៏អនុវត្តនូវយុទ្ធសាស្ត្ររបស់ខ្លួនដើម្បីលុបបំបាត់ជនជាតិវៀតណាមទាំងអស់ដែលនៅសេសសល់ ។ ក្នុងខែមេសា ឆ្នាំ១៩៧៧ ខ្មែរក្រហមបានបោះពុម្ពនូវ «បទបញ្ជាពីមន្ទីរ៨៧០» ដោយបង្គាប់ឲ្យធ្វើការចាប់ខ្លួន «ជនជាតិភាគតិចវៀតណាមទាំងអស់និងជនជាតិខ្មែរទាំងអស់ដែលនិយាយភាសាវៀតណាមឬមួយមានមិត្តភក្តិជាជនជាតិវៀនណាម» ។ ម្យ៉ាងវិញទៀត ជនជាតិវៀតណាមក៏ប្រឈមមុខនឹងការគំរាមកំហែងដល់ជីវិតផងដែរ ។ ខ្មែរក្រហមបានធ្វើការបោសសម្អាតសហគមន៍និងគ្រួសារវៀតណាមយ៉ាងច្រើន ។ ចំពោះការសម្លាប់រង្គាលក្នុងខេត្តកំពង់ឆ្នាំងនៅ

ពាក់កណ្តាលខែឧសភា ឆ្នាំ១៩៧៧ មានជនជាតិវៀតណាមជិតង់ និងក្មេងៗប្រមាណជា៤២០នាក់ត្រូវបានសម្លាប់ចោល ។ ចំណែកការសម្លាប់រង្គាលមួយទៀតនៅខេត្តក្រចេះ ឆ្នាំ១៩៧៨វិញ ខ្មែរក្រហមបានកំណត់គោលដៅចំពោះប្រជាជនណាដែលមានជាប់សាច់ឈាមវៀតណាម គ្រួសារវៀតណាម ឬនរណាក៏ដោយឲ្យតែមានជាប់ទាក់ទងជាមួយនឹងជនជាតិវៀតណាម ។ ខ្មែរក្រហមស៊ើរតែបញ្ជាឲ្យប្តីដែលជាជនជាតិខ្មែរសម្លាប់ប្រពន្ធវៀតណាមរបស់ខ្លួនទៀតផង ។

## ប្រវត្តិរឿងផ្ទាល់ខ្លួន

ដូចដែលបានពិភាក្សាមកខាងលើរួចហើយដែលថា ជនជាតិភាគតិចវៀតណាមបានប្រឈមមុខនឹងគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរបំផុតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ដោយពិចារណាទៅលើស្ថានភាពដ៏លំបាករបស់គេ ទើបធ្វើឲ្យស្ថាប័នស្រាវជ្រាវជាច្រើនដូចជាមជ្ឈមណ្ឌលឯកសារកម្ពុជាជាដើមបានអនុវត្តនូវគម្រោងមួយដែលមានគោលបំណងចង់ស្វែងយល់ពីបទពិសោធន៍របស់ជនជាតិភាគតិចវៀតណាម ។ ទោះបីជាជនជាតិវៀតណាមភាគច្រើនត្រូវបានសម្លាប់ឬគេចខ្លួនបាត់ក្នុងសម័យខ្មែរក្រហមហើយក៏ដោយ ក៏មជ្ឈមណ្ឌលឯកសារកម្ពុជានៅតែអាចធ្វើបទសម្ភាសន៍ជាច្រើនជាមួយនឹងជនជាតិវៀតណាមដែលនៅរស់រានមានជីវិតឬសមាជិកគ្រួសារ ក៏ដូចមិត្តភក្តិជាជនជាតិខ្មែរដែលនៅរស់របស់គេដែរ ។ ភាគច្រើននៃបទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺធ្វើឡើងនៅភូមិពោធិ៍ចិនដាំ ឃុំស្វាយអន្ទរ ស្រុកព្រៃវែង ខេត្តព្រៃវែង ។ ក្នុងសម័យខ្មែរក្រហម ខេត្តព្រៃវែងសម្បូរទៅដោយលំនៅឋានរបស់ជនជាតិភាគតិចវៀតណាម ព្រោះខេត្តនេះមានទីតាំងនៅជាប់ព្រំដែនកម្ពុជា-វៀតណាមប៉ែកបូព៌ា ។ ក្នុងខែសីហា ឆ្នាំ២០០៨ ខ្ញុំបានធ្វើបទសម្ភាសន៍ខ្លះៗជាមួយនឹងគ្រួសារវៀតណាមនៅភូមិពោធិ៍ចិនដាំដែរ ។ ក្រៅពីភូមិពោធិ៍ចិនដាំក្នុងខេត្តព្រៃវែង ក៏នៅមានជនជាតិវៀតណាមផ្សេងទៀតដែលនៅរស់រានមានជីវិតនៅក្នុងខេត្តស្វាយរៀង រស់នៅភូមិភាគបូព៌ានៃព្រះរាជាណាចក្រកម្ពុជាដែរ ។ ក្នុងផ្នែកនេះ ខ្ញុំនឹងធ្វើការរៀបរាប់ពីរឿងរ៉ាវផ្ទាល់របស់ជនរងគ្រោះវៀតណាមដែលប្រមូលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជានិងបទសម្ភាសន៍របស់ខ្ញុំផ្ទាល់ ។

### ស៊ុម សាន

នៅក្នុងបទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាឆ្នាំ១៩៩៨ បុរសជនជាតិខ្មែរម្នាក់ឈ្មោះ ឡាច នី បានរៀបរាប់សាច់រឿងរបស់គាត់ដែលមានប្រពន្ធជាជនជាតិវៀតណាមឈ្មោះ ស៊ុម សាន ។ នី នៅចាំថា ក្នុងខែកក្កដា ឆ្នាំ១៩៧៧ ខ្មែរក្រហមបានធ្វើការតាមដាននៅក្នុងភូមិដោយពិនិត្យមើលថាតើនរណាជាជនជាតិខ្មែរនិងនរណាជាជនជាតិវៀតណាម ។ នៅពេលនោះ គាត់និងប្រពន្ធរួមទាំងកូនទាំង៧នាក់រស់នៅភូមិពោធិ៍ចិនដាំ ។ នី បានពន្យល់ថា ទោះបីជាប្រពន្ធរបស់គាត់ជាជនជាតិភាគតិចវៀតណាមក៏ដោយ ក៏ប៉ុន្តែប្រពន្ធរបស់គាត់រស់នៅក្នុងប្រទេសកម្ពុជាជាយូរណាស់មកហើយ ហើយនិយាយភាសាខ្មែរបានយ៉ាងច្បាស់ទៀតផង ។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏ នី នៅតែដឹងច្បាស់ក្នុងចិត្តថា ខ្មែរក្រហមប្រាកដជាដឹងថាប្រពន្ធរបស់គាត់គឺជាជនជាតិវៀតណាម (ដោយសារតែពណ៌សម្បុររបស់ប្រពន្ធគាត់សជាងគេដែលធ្វើឲ្យប្រពន្ធគាត់មើលទៅដូចជាជនជាតិវៀតណាមអ៊ីចឹងម្យ៉ាងដោយសារតែអ្នកនៅក្នុងភូមិរបស់គាត់ប្រាប់ទៅខ្មែរក្រហមផង) ។ នី ព្យាយាមបញ្ចុះបញ្ចូលខ្មែរក្រហមថា ប្រពន្ធគាត់ជាជនជាតិចិនមិនមែនជនជាតិវៀតណាមទេ តែគេនៅតែមិនជឿ ។ ជាក់ស្តែងនៅពេលនោះ ខ្មែរក្រហមព្យាយាមបំបែកគាត់ចេញពីគ្រួសារដោយចាប់ខ្លួនគាត់ទៅឃុំនៅឯស្រុកផ្សេងក្នុងខេត្តដដែលអស់រយៈពេលជាង២ខែ ។

បន្ទាប់ពី នី ត្រូវបានដោះលែងមកភូមិវិញ ញាតិសន្តានរបស់គាត់បានប្រាប់គាត់ថា ប្រពន្ធនិងកូនរបស់គាត់ត្រូវខ្មែរក្រហមចាប់ខ្លួនបាត់អស់ហើយ ។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ិន ឆន (អ្នកបរទេះសេះនៅក្នុងសម័យខ្មែរក្រហមក្នុងភូមិពោធិ៍ចិនដាំ) ជុំ ឈាន (ស្ត្រីដែលធ្វើការក្នុងកងជាមួយនឹង សាន) និង ឡាច ណាក់ (ប្អូនថ្លៃស្រីរបស់ សាន) បានរៀបរាប់រឿងរ៉ាវដែលកើតឡើងចំពោះ សាន និងកូនរបស់នាង ។ គេនៅចាំថា ឈ្លបស្រុករបស់ខ្មែរក្រហម៤នាក់បានមកផ្ទះរបស់ សាន នៅម៉ោងឈប់សម្រាកពីការងារ ។ ឈ្លបនោះបានប្រាប់ សាន ថា គាត់ (សាន) និងកូនត្រូវបញ្ជូនទៅរៀនសូត្រនៅកន្លែងផ្សេង ។ នៅពេលនោះ គ្រួសាររបស់គាត់គ្មាននរណា

ហ៊ានប្រឆាំងនឹងបញ្ជារបស់ខ្មែរក្រហមនោះទេ ព្រោះគេជឿជាក់ទៅលើខ្មែរក្រហម ហើយជាពិសេសគឺខ្លាចមានការឈ្លោះគ្នាជាមួយឈ្លបទាំងអស់នោះណាស់ ។

ខ្មែរក្រហមចចេសចង់នាំយកកូនរបស់ សាន ទៅជាមួយ សាន ខ្លាំងណាស់ ។ ពេលនោះ កូនស្រីច្បងរបស់ សាន ទៅធ្វើការនិងស្នាក់នៅឯភូមិដទៃទៀត ។ ខ្មែរក្រហមបានបញ្ជាឲ្យកូនស្រីច្បងនោះត្រឡប់មកភូមិពោធិ៍ចិនដាំវិញដើម្បីឲ្យនាងបានរួមដំណើរទៅជាមួយម្តាយនិងបងប្អូនរបស់នាងជាជាងបន្សល់ទុកនាងឲ្យរស់នៅក្នុងភូមិ ។ បន្ទាប់មក ពួកឈ្លបទាំងនោះបានចាប់ចងដៃរបស់ សាន និងកូនទាំង៧នាក់មកក្រោយ ហើយដាក់លើរទេះសេះដឹកយកទៅបាត់ ។ បន្ទាប់មក នី ក៏បានឮពីមេភូមិឈ្មោះ ឡឹក ឆែម ថា ការសម្រេចចិត្តរបស់ខ្មែរក្រហមក្នុងការចាប់កូនស្រីច្បងរបស់ សាន គឺជាគោលការណ៍សំខាន់របស់ខ្មែរក្រហមចំពោះជនជាតិវៀតណាម ។ នី បាននិយាយថា នៅក្នុងភូមិរបស់គាត់ ខ្មែរក្រហមសម្លាប់កូនរបស់ប្តីប្រពន្ធខ្មែរ-វៀតណាម គឺអាស្រ័យទៅលើខាងឪពុកឬខាងម្តាយមានជាប់សាច់ឈាមវៀតណាម ។ ប្រសិនបើឪពុកជាជនជាតិវៀតណាម គឺសម្លាប់តែឪពុកទេ ដោយទុកកូនឲ្យនៅរស់ ខុសពីម្តាយដែលជាជនជាតិវៀតណាម គឺទាំងម្តាយនិងកូនសុទ្ធតែត្រូវសម្លាប់ទាំងអស់ ។

ក្រោយមកអ្នកបររទេះសេះដែលដឹក សាន និងកូនរបស់ សាន បានប្រាប់ ស៊ិន ឆន ថា ខ្មែរក្រហមបញ្ជាឲ្យគាត់ដឹកគ្រួសារនេះទៅវត្តអូរកណ្តាល ។ នៅពេលគាត់ដឹកដល់វត្តហើយ ខ្មែរក្រហមបានបញ្ជាឲ្យគាត់ត្រឡប់ទៅភូមិវិញជាប្រញាប់ ។ ចាប់តាំងពីពេលនោះមកមិនមាននរណាម្នាក់បានដឹងពីហេតុការណ៍ដែលកើតមានឡើងចំពោះ សាន និងកូនៗរបស់គាត់ទៀតទេ ។ នី សន្មតថាប្រពន្ធរបស់គាត់ត្រូវបានខ្មែរក្រហមបញ្ជូនពីវត្តអូរកណ្តាលយកទៅសម្លាប់នៅក្រាំងគរ ។ នី និយាយថា អំឡុងពេលដែលគាត់នៅជាប់ឃុំឃាំង គាត់បានលបស្តាប់ពួកឈ្លបនិយាយពីរវាលពិឃាតក្រាំងគរថាជាកន្លែងដែលវាចាប់ជនជាតិវៀតណាមទៅឃុំឃាំងនិងធ្វើទារុណកម្ម ។ នី បាននិយាយទៀតថា ក្រាំងគរជាមន្ទីរសន្តិសុខមួយរបស់ខ្មែរក្រហមនិងបានសម្លាប់មនុស្សប្រមាណពី៤ម៉ឺនទៅ៥ម៉ឺននាក់ ទាំងជនជាតិខ្មែរនិងវៀតណាម ។ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំទៅ នី បានទៅមើលវាលពិឃាតនោះហើយប្រាប់ថា រណ្តៅនីមួយៗមានសាកសពយ៉ាងហោចណាស់ពី២០ទៅ៣០នាក់ ហើយកន្លែងខ្លះមានដល់ទៅ៥០នាក់ ។ នី នៅចងចាំពីការមើលឃើញដោយផ្ទាល់ភ្នែកជាច្រើនលើកអំពីការសម្លាប់នៅវាលពិឃាតដីខ្លាញ់ខេត្តពោធិ៍សាត់ ដែលធ្វើឲ្យគាត់ជឿជាក់ថា ប្រពន្ធកូនរបស់គាត់ប្រហែលជាត្រូវឈ្លបសម្លាប់តាមវិធីដូចគ្នានឹងអ្នកដែលត្រូវខ្មែរក្រហមសម្លាប់នៅដីខ្លាញ់ដែរ ។ នៅដីខ្លាញ់ ខ្មែរក្រហមបានជីករណ្តៅយ៉ាងធំមួយ បន្ទាប់មក ឈ្លបក៏បានតម្រង់ជួរជនរងគ្រោះដែលមានដៃជាប់ចំណងនិងចងបិទភ្នែកឲ្យឈរនៅចុងមាត់រណ្តៅ រួចឈ្លបក៏យកដំបងដែកមកវាយចំកញ្ចឹងកជនរងគ្រោះរហូតទាល់តែដួលសន្លប់ធ្លាក់ចូលក្នុងរណ្តៅ ។ នៅពេលដែលជនរងគ្រោះធ្លាក់ចូលក្នុងរណ្តៅ ខ្មែរក្រហមក៏កប់អ្នកទាំងនោះតែម្តង ដោយមិនខ្វល់ថាតើជនរងគ្រោះទាំងអស់នោះស្លាប់ឬរស់នោះទេ ។

ការចងចាំចុងក្រោយបំផុតដែលគ្រួសារនិងមិត្តភក្តិរបស់ សាន នៅជិតជាប់ក្នុងអារម្មណ៍នោះគឺជារូបភាពពេលដែលខ្មែរក្រហមអូស សាន និងកូនរបស់គាត់ដាក់លើរទេះសេះ ។ ណាក់ បាននិយាយថា រយៈពេល៣ថ្ងៃក្រោយពីមិនឃើញ សាន ត្រឡប់មកវិញ ធ្វើឲ្យសមាជិកគ្រួសារគាត់គិតថា សាន និងកូនប្រហែលជាស្លាប់បាត់ហើយ ។ ណាក់ ក៏បាននិយាយប្រាប់ផងដែរអំពីការប្រជុំក្នុងភូមិមួយដែលខ្មែរក្រហមព្យាយាមបញ្ចុះបញ្ចូលកុំឲ្យប្រជាជនមានការព្រួយបារម្ភពីការបាត់ខ្លួនរបស់ប្រជាជនវៀតណាម ។ នៅក្នុងអង្គប្រជុំ ខ្មែរក្រហមបានប្រាប់ប្រជាជនទាំងអស់គ្នាថា កុំឲ្យមានការភិតភ័យព្រោះរឿងដែលកើតឡើងចំពោះជនជាតិវៀតណាមគ្មានអ្វីជាប់ទាក់ទងជាមួយនឹង «យើង» ឬប្រជាជនកម្ពុជាទេ ។ ខ្មែរក្រហមបានធ្វើការសម្រេចចិត្តមួយយ៉ាងដាច់ខាតថា កូនក្មេងតូចយ៉ាងណាក៏ដោយ ឲ្យតែជាប់សាច់ឈាមវៀតណាម មិនត្រូវផ្តល់ក្តីអាណិតអាសូរឡើយ ហើយត្រូវសម្លាប់ទាំងអស់ដើម្បីលុបបំបាត់ឈាមអាក្រក់ទាំងនេះចេញពីកម្ពុជា ។

## ជុយ និង ង៉ាម

ជុយ និង ង៉ាម មានបទពិសោធន៍ឆ្លងកាត់សម័យខ្មែរក្រហមស្រដៀងគ្នា ។ ទាំងពីរនាក់គឺជាជនជាតិវៀតណាមសុទ្ធសាធដែល

រស់នៅក្នុងភូមិពោធិ៍ចិនដាំ ។ ជុយ គឺជាអតីតទាហានវៀតណាម ម្នាក់ដែលមកតាំងទីលំនៅក្នុងប្រទេសកម្ពុជា ដែលក្រោយមកបាន រៀបការជាមួយនារីជនជាតិខ្មែរម្នាក់ ឈ្មោះ ដូង អឿន ។ គេ ទាំងពីរមានកូនស្រីម្នាក់ឈ្មោះ គីម វ៉ា ហើយកូនប្តីមុនរបស់ អឿន មានពីរនាក់ទៀត ។ ចំណែក ង៉ាម មានប្រពន្ធជាជនជាតិខ្មែរ ឈ្មោះ គិច និងមានកូន៣នាក់ ដែល២នាក់នៅរស់ ហើយម្នាក់ ទៀតបានស្លាប់ក្នុងសម័យខ្មែរក្រហម ។ ង៉ាម និងគ្រួសាររបស់ គាត់រស់នៅក្នុងភូមិពោធិ៍ចិនដាំជាង២០ឆ្នាំមកហើយ មុនពេល ដែលខ្មែរក្រហមចូលកាន់កាប់អំណាច ។ ទាំង ង៉ាម និង ជុយ សុទ្ធ តែនិយាយភាសាខ្មែរបានល្អ ប៉ុន្តែមានអ្នកជិតខាងម្នាក់នៅចាំថា ជុយ និយាយខ្មែរមានសំឡេងខុសពីគេបន្តិច ។ នៅពេលដែលខ្មែរ ក្រហមចូលកាន់កាប់អំណាច អឿន នៅចាំបានថា បងប្អូនរបស់ ជុយ បានដាស់តឿន ជុយ ឲ្យគេចខ្លួនទៅនៅដីក្រហម ។ អ្នកភូមិ ម្នាក់ឈ្មោះ សេក គ្រឿង បានប្រាប់ថា ដីក្រហមមានទីតាំងនៅ ខេត្តស្វាយរៀង ជាកន្លែងមួយដែលពួកគេនិយាយថាជាកន្លែងមាន សុវត្ថិភាពសម្រាប់ជនជាតិវៀតណាមក្នុងសម័យខ្មែរក្រហម ។ គ្រឿង ស្គាល់អ្នកភូមិខ្លះដែលធ្លាប់គេចខ្លួនទៅនៅដីក្រហមដែរ ហើយក៏បានគេចផុតពីការធ្វើបាបរបស់ខ្មែរក្រហម ។ ទោះបីជា មានការណែនាំពីមិត្តភក្តិ និងបងប្អូនយ៉ាងណាក៏ដោយ ក៏ ជុយ នៅ តែបន្តរស់នៅក្នុងភូមិពោធិ៍ចិនដាំនេះដដែល ។

នៅពេលដែលខ្មែរក្រហមចូលកាន់កាប់អំណាច គេបាន រៀបចំប្រជាជនឲ្យទៅធ្វើការទាំងអស់ ហើយត្រូវហូបបាយរួមគ្នា នៅក្នុងកងទៀត ។ ម្តាយរបស់ អឿន ឈ្មោះ ណុត អោ បាន និយាយរៀបរាប់ពីជីវភាពរស់នៅដ៏លំបាកក្នុងរបបខ្មែរក្រហមថា ម្នាក់ៗគ្មានអាហារហូបគ្រប់គ្រាន់ទេ ។ នៅក្នុងសម័យនោះ ជុយ ត្រូវធ្វើការច្រើនណាស់ដូចជា ធ្វើជីអាចម៍គោ និងជួយដាំបន្លែនៅ ក្នុងភូមិ ។ ចំណែក ង៉ាម ត្រូវទៅជីកប្រឡាយ និងធ្វើចង្អូរបង្ហូរ ទឹកចូលក្នុងស្រែទៀតផង ។ ជុយ និង ង៉ាម នៅធ្វើការងារទាំងនេះ រហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៧ ជាពេលដែលខ្មែរក្រហមនាំអ្នក ទាំងពីរនាក់ទៅក្នុងព្រៃ ហើយមិនដែលឃើញត្រឡប់មកវិញសោះ ។

គ្រួសារក៏ដូចជាមិត្តភក្តិរបស់ ជុយ និង ង៉ាម បាននិយាយ ប្រាប់ពីហេតុការណ៍ដែលអ្នកទាំងពីរបាត់ខ្លួន ។ អ្នកភូមិម្នាក់ដែល ឈ្មោះ ហេង ហ៊ុយ ធ្វើការជាមួយ ជុយ និង ង៉ាម នៅក្នុងព្រៃ នៅចាំថា នៅដើមដំបូងទាំងជនជាតិវៀតណាមនិងជនជាតិខ្មែរ ត្រូវបានខ្មែរក្រហមធ្វើល្អដាក់ស្មើគ្នា ។ ប៉ុន្តែ ចាប់ពីដើមឆ្នាំ ១៩៧៧មក ខ្មែរក្រហមចាប់ផ្តើមបែងចែកអ្នកភូមិទាំងអស់ទៅ តាមជាតិសាសន៍ផ្សេងៗ មានន័យថា ជនជាតិវៀតណាមត្រូវរស់ នៅក្នុងក្រុមជនជាតិវៀតណាម ចំណែកជនជាតិចិនត្រូវរស់នៅ ក្នុងក្រុមជនជាតិចិន ហើយចាមនៅក្នុងក្រុមចាម ។ ហ៊ុយ បាន បន្ថែមទៀតថា ខ្មែរក្រហមក៏បានបែងចែកប្រជាជនជាបីក្រុមផង ដែរ ក្រុមទី១) រួមមានអ្នកមាន និងអ្នកមធ្យម ក្រុមទី២) អ្នកធ្វើការ និងក្រុមទីបី) ជាកសិករ ។ ក្រុមដែលមិនមែនជាជនជាតិខ្មែរនិង ក្រុមទី១ត្រូវទៅរស់នៅកន្លែងផ្សេងឆ្ងាយពីភូមិ ។ ដោយសារតែ ហ៊ុយ ជាកូនកាត់ចិន ហើយស្ថិតនៅក្នុងក្រុមទី១ ដូច្នេះ ហ៊ុយ ត្រូវ ខ្មែរក្រហមបញ្ជូនឲ្យទៅរស់នៅតំបន់ដាច់ស្រយាលពីភូមិ ។ គាត់ក៏ បាននិយាយទៀតថា ខ្មែរក្រហមបានសម្លាប់រង្គាលប្រជាជន ក្នុងក្រុមណាដែលវាមិនត្រូវការ ។ ពេលមួយ ហ៊ុយ បានប្រទះ ឃើញខ្មែរក្រហមបញ្ជូនគ្រួសារចិនមួយចំនួនទៅរស់នៅឯភូមិដទៃ ទៀត ។

ដោយធ្វើទៅតាមគោលការណ៍ក្នុងការបែងចែកពូជសាសន៍ និងឋានៈ មេភូមិបានបញ្ជាឲ្យមេកងនៅក្រុមនីមួយៗជ្រើសរើស បុរសម្នាក់ចេញពីក្រុមរបស់ខ្លួនដើម្បីទៅកាប់ខសក្នុងព្រៃតាពៅ នៅភូមិអូរកណ្តាល ឃុំដំរីពួន ស្រុកព្រៃវែង ខេត្តព្រៃវែង ។ មាន ន័យថា បើក្នុងភូមិពោធិ៍ចិនដាំមាន១០ក្រុម នោះបុរស១០នាក់ ត្រូវបានចាត់តាំងឲ្យទៅកាប់ព្រៃ ។ ហ៊ុយ នៅចាំបានថា អ្នកទៅ កាប់ព្រៃទាំងអស់គឺមានទាំងជនជាតិខ្មែរ ចិន និងយួន រួមមានទាំង ជុយ និង ង៉ាម ផងដែរ ។ កូនស្រីរបស់ ង៉ាម ឈ្មោះ ង៉ាម កុក បាននិយាយថា កាលណោះគាត់មិនបានចាំច្បាស់នូវអ្វីទាំងអស់ ទាក់ទងទៅនឹងរឿងរ៉ាវដែលខ្មែរក្រហមហៅឪពុកគាត់ឲ្យទៅធ្វើការ នៅក្នុងព្រៃ ព្រោះពេលនោះគាត់មានអាយុត្រឹមតែ២ឆ្នាំប៉ុណ្ណោះ ។ ចំណែកឯគ្រួសាររបស់ ជុយ នៅចាំបានថា កាលណោះមាន មេភូមិឈ្មោះ ឆែម បានមកផ្ទះរបស់គាត់ ហើយហៅ ជុយ ឲ្យ ទៅកាប់ព្រៃដោយមិនមានការគំរាមសម្លុតអ្វីនោះទេ ។ វ៉ា ពុ ម្តាយគាត់ប្រាប់ថា ឪពុករបស់គាត់បានយល់ព្រមទៅដោយសារ

តែមើលឃើញថាខ្មែរក្រហមមិនមានសកម្មភាពបង្ខំឡើយ ដែលធ្វើឲ្យ ជុយ និងក្រុមគ្រួសារសុទ្ធតែជឿថា ការងារកាប់ព្រៃនេះជាការពិត ។ អោ នៅចាំថា ពេលព្រឹកឡើងថ្ងៃបន្ទាប់ ជុយ ក៏រៀបបង្វេចខោអាវ ហើយផ្ដែផ្ដាំ អោ ឲ្យជួយមើលថែកូនគាត់ផង ។ លុះដល់ម៉ោង៧ព្រឹក ទើប ជុយ ង៉ាម ហ៊ុយ និងអ្នកមានឈ្មោះទៅកាប់ព្រៃទាំងអស់ចាប់ផ្ដើមចេញដំណើរដោយថ្មើរជើងទៅព្រៃតាពោចម្ងាយជិត១០គីឡូម៉ែត្រ ។

អំឡុងពេលនៅក្នុងព្រៃអ្នកទាំងអស់នេះបានរៀបចំទម្លាប់ធ្វើការរបស់ខ្លួន ដោយនៅពេលព្រឹកត្រូវទៅកាប់ខស លុះដល់ថ្ងៃត្រង់ដាំបាយ ធ្វើម្ហូប ហើយហូបបាយ ពេលហូបបាយថ្ងៃត្រង់រួចហើយ អ្នកកាប់ព្រៃទាំងអស់ក៏ចាប់ផ្ដើមត្រឡប់ចូលក្នុងព្រៃវិញ ដើម្បីបំពេញការងារបន្តទៀត រហូតដល់ពេលល្ងាចទើបឈប់សម្រាក ។ អ្នកទាំងនោះរស់នៅបានជិតកន្លះខែ រហូតដល់ថ្ងៃដែល ជុយ និង ង៉ាម បាត់ខ្លួន ។ នៅថ្ងៃបាត់ខ្លួននោះ ហ៊ុយ នៅចាំបានថា មេភូមិបានជិះកង់មកហៅគាត់ឲ្យត្រឡប់ទៅភូមិវិញ ។ ពេលដែលធ្វើដំណើរមកស្រុកវិញ កង់របស់មេភូមិស្រាប់តែជ្រុះច្រវាក់នៅទល់មុខវត្តអូរកណ្ដោល ។ ពេលនោះ មេភូមិបានហៅ ជុយ និង ង៉ាម ឲ្យនៅជួយជួសជុលកង់គាត់សិន ដោយឲ្យអ្នកផ្សេងទៀតបន្តដំណើរទៅមុន ។ ហ៊ុយ បានបន្តទៀតថា កាលនោះគាត់យល់ថា វាមិនមែនជារឿងចម្លែកទេដែលមេភូមិទុក ង៉ាម នៅជាមួយដែរនោះ ព្រោះ ង៉ាម ចេះជួសជុលកង់ស្រាប់ ។ ហ៊ុយ និងអ្នកដទៃទៀតក្នុងក្រុមនៅចាំ ង៉ាម និង ជុយ នៅវត្តអូរកណ្ដោល តែមិនឃើញអ្នកទាំងពីរត្រឡប់មកសោះ ដូច្នេះ ហ៊ុយ និងអ្នកដទៃទៀតក៏សម្រេចចិត្តធ្វើដំណើរមកភូមិមុន ។ ពេលត្រឡប់មកដល់ពោធិ៍-ចិនដាំ ហ៊ុយ បានឮដំណឹងថាខ្មែរក្រហមបានចាប់ប្រពន្ធកូនរបស់ឡាច នី ទៅគឺដោយសារតែប្រពន្ធរបស់គាត់ជាជនជាតិវៀតណាម ។ បន្ទាប់មក ទើប ហ៊ុយ ជឿជាក់ថា កង់របស់មេភូមិស្រាប់តែធ្លាក់ច្រវាក់មិនមែនជារឿងចៃដន្យនោះទេ ។ ផ្ទុយមកវិញ ហ៊ុយ ជឿជាក់ថា មេភូមិមានបំណងចង់បំបែក ជុយ និង ង៉ាម ចេញពីភ្នែកគេឯង រួចសម្លាប់ទាំងពីរនាក់នៅវត្តអូរកណ្ដោល ដែលជាមន្ទីរសន្តិសុខខ្មែរក្រហមកាលពីសម័យនោះ ។ ហ៊ុយ ជឿថាខ្មែរក្រហមប្រាកដជាដឹងមុនថា ង៉ាម និង ជុយ ជាជនជាតិវៀតណាម ។ ជាទូទៅកម្មាភិបាលថ្នាក់ធំៗរបស់ខ្មែរក្រហមមិនសូវជាស្គាល់អ្នកភូមិទាំងអស់ទេ ប៉ុន្តែ ហ៊ុយ ជឿជាក់ថា មេភូមិដែលរស់នៅជាមួយអ្នកស្រុកភូមិជាអ្នករាយការណ៍ទៅកម្មាភិបាលខ្មែរក្រហមធំៗពីជីវប្រវត្តិរបស់ ជុយ និង ង៉ាម ។ យោងតាមអ្វីដែល ជុយ បាននិយាយគោលការណ៍របស់ខ្មែរក្រហមដែលថាសម្លាប់ជនជាតិវៀតណាមគឺចេញមកពីមេដឹកនាំធំៗរបស់អង្គការខ្មែរក្រហម ប៉ុន្តែព័ត៌មានលម្អិតទាក់ទងទៅនឹង «សត្រូវ» ជនជាតិវៀតណាមគឺចេញមកពីកម្មាភិបាលថ្នាក់ក្រោមរបស់ខ្មែរក្រហមដូចជាមេភូមិជាដើម ។

ក្រោយពីការបាត់ខ្លួនរបស់ជនជាតិវៀតណាមនៅក្នុងភូមិពោធិ៍អូរចិនដាំ ខ្មែរក្រហមបានរៀបចំធ្វើការប្រជុំមួយជាមួយអ្នកភូមិ ។ នៅក្នុងអង្គប្រជុំ ខ្មែរក្រហមព្យាយាមលួងលោមប្រជាជនទាំងអស់ដោយនិយាយថា គេគ្រាន់តែនាំយកជនជាតិវៀតណាមទាំងអស់នោះទៅនៅឯភូមិផ្សេងទៀត ដែលមានដីទំនេរច្រើនជាងនេះ ។ ប៉ុន្តែ អោ បាននិយាយថា គ្រួសាររបស់គាត់នៅតែមានការភ័យខ្លាចថា ពួកគាត់នឹងក្លាយជាគោលដៅដែលខ្មែរក្រហមធ្វើបាបខុសពីអ្វីដែលខ្មែរក្រហមប្រឹងប្រែងនិយាយលួងលោមប្រជាជនកុំឲ្យមានការភ័យខ្លាច ។ អោ នៅចាំថា មានអ្នកភូមិម្នាក់បានណែនាំឲ្យ អោ ប្ដូរឈ្មោះកូនស្រីរបស់ ជុយ ពី គីម វ៉ា ឲ្យទៅជា សា មិន វិញ ដែលស្ដាប់ទៅមិនសូវដូចជាឈ្មោះវៀតណាមពេក ។ អោ យល់ឃើញថា ដំបូន្មាននេះអាចទទួលយកបាន ដូច្នេះចាប់ពីពេលនោះមក កូនស្រីរបស់ ជុយ ក៏ជាប់ឈ្មោះថា សា មិន រហូតដល់សព្វថ្ងៃ ។

### សេង ហួរ

សេង ហួរ កើតនៅខេត្តព្រៃវែង គាត់ជាកូនកាត់ចិននិងវៀតណាមដែលមានម្ដាយឈ្មោះ លេ ពីហៃ ជាជនជាតិវៀតណាម ហើយឪពុកឈ្មោះ សេង ជាកូនចិនមានមុខរបរជាជាងកាត់ដេរ និងលក់សម្លៀកបំពាក់ ។ ហួរ មានបងប្អូន៨នាក់ ដែលភាគច្រើនត្រូវបានបាត់ខ្លួនក្នុងរបបខ្មែរក្រហម ។ នៅក្នុងឆ្នាំ១៩៧៧ ខ្មែរក្រហមបានចាប់ខ្លួនបងប្រុសរបស់ហួរ ឈ្មោះ សេង វ៉ាន់ និងកូន៣នាក់ទៀតរបស់គាត់ ។ វ៉ាន់ និងកូន២នាក់របស់គាត់បានបាត់ខ្លួន ប៉ុន្តែកូនម្នាក់ទៀតអាចគេចផុតពីការចាប់ខ្លួនរបស់ខ្មែរ

ក្រហមហើយអាចរស់រានមានជីវិត ។ បងស្រីរបស់ ហួរ ឈ្មោះ សេង មុយ ក៏បានគេចផុតពីពីសម័យនោះដែរ ហើយសព្វថ្ងៃរស់នៅភូមិច្បារអំពៅ ។ ប្អូនស្រីរបស់ហួរ ឈ្មោះ សេង ទៀង និង ប្អូនប្រុសឈ្មោះ សេង កេ ត្រូវខ្មែរក្រហមចាប់ខ្លួននៅឆ្នាំ ១៩៧៧ ។ បន្ទាប់ពីការចាប់ខ្លួនរបស់ សេង ទៀង និង សេង កេ ខ្មែរក្រហមក៏បន្តចាប់ខ្លួន ហួរ និងកូនព្រមទាំងម្តាយរបស់គាត់ទៀត ។ នៅក្នុងបទសម្ភាសន៍ឆ្នាំ២០០៨ ស្វាមីរបស់ ហួរ ឈ្មោះ យុន ម៉ុន បានរៀបរាប់ពីរឿងដែលកើតឡើងចំពោះ ហួរ ។

មុនពេលរបបខ្មែរក្រហមចូលមកដល់ ហួរ និង ម៉ុន រស់នៅក្នុងភូមិស្វាយអន្ទរ ខេត្តព្រៃវែង ។ ហួរ បានជួបនឹង ម៉ុន នៅពេលដែលគាត់នៅជាលោកសង្ឃនៅឡើយ បន្ទាប់មកគេទាំងពីរនាក់ក៏ស្រឡាញ់គ្នា ។ នៅឆ្នាំ១៩៦៩ ម៉ុន បានសឹក ហើយរៀបការជាមួយ ហួរ ។ ពេលនោះ ម៉ុន មានអាយុ២៨ឆ្នាំ ហើយ ហួរ អាយុត្រឹមតែ១៧ឆ្នាំប៉ុណ្ណោះ ។ គេទាំងពីរមានកូន៣នាក់សុទ្ធតែប្រុស ដូចជា ចាន់ថា កើតនៅឆ្នាំ១៩៧០ ចន្ទូ កើតនៅឆ្នាំ១៩៧៣ និង ចាន់ធឿន កើតនៅឆ្នាំ១៩៧៥ ។ តាម ម៉ុន និយាយ គាត់គឺជាគ្រួសារវៀតណាមតែម្នាក់ដែលរស់នៅក្នុងភូមិស្វាយអន្ទរ ។

ជៀប លន ជាអ្នកស្រុករស់នៅក្នុងភូមិស្វាយអន្ទរនិងជាប្អូនថ្លៃស្រីរបស់ ម៉ុន បាននិយាយពីជីវភាពរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ លន បានរៀបរាប់ថា ក្រោយពេលដែលខ្មែរក្រហមឡើងកាន់អំណាច មិនយូរប៉ុន្មានក៏ចាប់ផ្តើមប្រមូលជនជាតិចិននិងវៀតណាមទាំងអស់ឲ្យទៅស្រុកកំណើតរបស់គេវិញ ។ ខ្មែរក្រហមបានបញ្ជាក់យ៉ាងច្បាស់ថា នេះជាលើកចុងក្រោយហើយដែលគេផ្តល់ឱកាសឲ្យ «ជនបរទេស» ចាកចេញពីទីនេះ ។ អំឡុងពេលនោះ គ្រួសារខាងម្តាយរបស់ ហួរ បាន មករក ហួរ និង ម៉ុន ដើម្បីនិយាយបញ្ចុះបញ្ចូលឲ្យពួកគេគេចទៅនៅដីក្រហម ។ លន នៅចាំថា គាត់បានឮអ្នកភូមិថា ដីក្រហមគឺជាកន្លែងសុវត្ថិភាពមួយសម្រាប់ជនជាតិវៀតណាមកាលពីសម័យខ្មែរក្រហម ។ ទោះបីជាមានការអំពាវនាវឲ្យទៅដីក្រហមក៏ដោយ ក៏ ហួរ និង ម៉ុន នៅតែបដិសេធមិនព្រមចាកចេញពីភូមិឡើយ ហើយសុខចិត្តបន្តរស់នៅក្នុងភូមិស្វាយអន្ទងក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមដដែល ។

នៅពេលនោះ ហួរ ធ្វើការនៅវាលស្រែ ចំណែក ម៉ុន ធ្វើការនៅកងចល័ត ។ ម៉ុន នៅចាំថា កាលពីសម័យខ្មែរក្រហម គាត់និងប្រពន្ធធ្វើការបែកគ្នា បានជួបគ្នាតែពេលយប់ប៉ុណ្ណោះ ។ គាត់និយាយថា ចំពោះជីវិតរបស់គាត់ក្នុងរបបខ្មែរក្រហមមិនសូវជាពិបាកខ្លាំងនោះទេ គឺធ្វើការធម្មតា ប្រសិនបើខ្មែរក្រហមបញ្ជាឲ្យធ្វើអ្វីមួយ ប្រជាជនត្រូវតែធ្វើតាមបញ្ជា នោះវានឹងមិនមានបញ្ហាអ្វីឡើយ ។ យ៉ាងណាមិញ នៅឆ្នាំ១៩៧៦ លក្ខខណ្ឌការងារនិងជីវភាពរស់នៅកាន់តែយ៉ាប់ទៅៗ ។ ខ្មែរក្រហមបង្ខំប្រជាជនឲ្យធ្វើការក្នុងស្រែតាំងពីម៉ោង៧ព្រឹករហូតដល់ម៉ោង៥ល្ងាច ដោយមិនបានផ្តល់អាហារឲ្យហូបគ្រប់គ្រាន់ទេ ។ អតីតមេឃុំស្វាយអន្ទរ ប៉ែក ប៉ាច បានអះអាងថា កាលពីសម័យខ្មែរក្រហមគឺគ្មានសេរីភាពទេ ។ ទំនាក់ទំនងរវាងគ្រួសារនិងគ្រួសារត្រូវកាត់ផ្តាច់ពីគ្នា ពីព្រោះខ្មែរក្រហមមិនអនុញ្ញាតឲ្យទៅសួរសុខទុក្ខបងប្អូនញាតិសន្តានឡើយ ។ មានពេលខ្លះ ទោះបីជាមានបងប្អូនឈឺធ្ងន់យ៉ាងណាក៏ដោយ ក៏ខ្មែរក្រហមមិនអនុញ្ញាតឲ្យទៅសួរសុខទុក្ខដែរ ។ នៅឆ្នាំ១៩៧៧ ម៉ុន ត្រូវអង្គការចាត់តាំងឲ្យទៅធ្វើការនៅឃុំជើងផ្សង ។ ការងារថ្មីនេះ ធ្វើឲ្យ ម៉ុន បានជួបក្រុមគ្រួសារយូរៗម្តង ជួនកាល ១០ថ្ងៃជួបម្តង ឬជួនកាលរាប់ខែទើបជួបម្តង ហើយម្តងៗបាននៅផ្ទះតែ៣ទៅ៤ថ្ងៃប៉ុណ្ណោះ ។

**(នៅមានត)**

**អ៊ីលីហ្សាបែត ជូ**

## កម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរនឹងធ្វើការចាក់ផ្សាយកម្មវិធីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ដែលនិពន្ធដោយលោក ឌី ខាំបូលី ឡើងវិញនៅលើគេហទំព័ររបស់ខ្លួននៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ ខាងមុខនេះ ។

អ្នកទាំងអស់គ្នាអាចស្តាប់ ថតចម្លង និងអានសាច់រឿងដែលមាននៅក្នុងសៀវភៅនេះតាមរយៈគេហទំព័រវិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរ ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ដំណើរហេតុៈ ការកាត់ទោសខ្មែរក្រហម និងយុត្តិធម៌ សម្រាប់អំពើប្រល័យពូជសាសន៍នៅកម្ពុជា

សភាសហរដ្ឋអាមេរិកបានអនុម័តច្បាប់ស្តីពីយុត្តិធម៌ចំពោះអំពើប្រល័យពូជសាសន៍នៅកម្ពុជា (22 U.S.C. 2656 note) កាលពីខែមេសា ឆ្នាំ១៩៩៤ ។ ច្បាប់នេះចែងថា “សហរដ្ឋអាមេរិកមានគោលនយោបាយគាំទ្រការខិតខំប្រឹងប្រែងដើម្បីនាំខ្លួនសមាជិកពួកខ្មែរក្រហមមកកាត់ទោសចំពោះអំពើឧក្រិដ្ឋរបស់គេប្រឆាំងមនុស្សជាតិ ។

នៅឆ្នាំ១៩៩៤ ក្រសួងការបរទេសសហរដ្ឋអាមេរិកបានបង្កើតការិយាល័យស៊ើបអង្កេតអំពើប្រល័យពូជសាសន៍សម្រាប់ប្រទេសកម្ពុជាដើម្បី ៈ

- ស៊ើបអង្កេតបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិដែលប្រព្រឹត្តដោយមេដឹកនាំខ្មែរក្រហមថ្នាក់ជាតិ ។
- ផ្តល់ជាឯកសារ កំណត់ហេតុ និងភ័ស្តុតាងផ្សេងទៀតដែលប្រមូលបានតាមរយៈការស៊ើបអង្កេតនេះដល់ប្រជាជនកម្ពុជា ។
- រៀបចំសំណើសម្រាប់បង្កើតតុលាការឧក្រិដ្ឋអន្តរជាតិដើម្បីកាត់ទោសអ្នកដែលជាប់ចោទថាបានប្រព្រឹត្តអំពើប្រល័យពូជសា.សន៍នៅកម្ពុជា ។

នៅខែមករា ឆ្នាំ១៩៩៥ ការិយាល័យស៊ើបអង្កេតអំពើប្រល័យពូជសាសន៍សម្រាប់កម្ពុជាបានផ្តល់អំណោយថវិកាចំនួន ៥០០.០០០ដុល្លារអាមេរិកដល់កម្មវិធីស្តីពីអំពើប្រល័យពូជសាសន៍នៅកម្ពុជារបស់សកលវិទ្យាល័យ Yale សម្រាប់ធ្វើការស្រាវជ្រាវបណ្តុះបណ្តាលនិងចងក្រងឯកសារស្តីពីរបបខ្មែរក្រហម ។ អំណោយថវិកាចំនួន១លានដុល្លារអាមេរិកពីក្រសួងការបរទេសអាមេរិកត្រូវបានផ្តល់ជាលើកទី២ដល់កម្មវិធីនេះកាលពីខែមិថុនា ឆ្នាំ១៩៩៧ ។

នៅខែមករា ឆ្នាំ១៩៩៥ ផងដែរកម្មវិធីស្តីពីអំពើប្រល័យពូជសាសន៍សម្រាប់កម្ពុជាបានបង្កើតមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) នៅក្រុងភ្នំពេញ ។ DC-Cam បានក្លាយជាវិទ្យាស្ថានស្រាវជ្រាវឯករាជ្យកម្ពុជាមួយនៅខែមករា ឆ្នាំ១៩៩៧ ដោយមានបំណងធ្វើឲ្យសាធារណជនយល់ដឹងកាន់តែច្បាស់ពីរបបខ្មែរក្រហមនិងជួយប្រជាជនកម្ពុជា និងអ្នកឯទៀតដែលមានបំណងធ្វើការប្តឹងផ្តល់តាមផ្លូវច្បាប់ចំពោះអំពើប្រល័យពូជសាសន៍ បទឧក្រិដ្ឋសង្គ្រាម និងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ដែលត្រូវបានប្រព្រឹត្តនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ តាំងពីឆ្នាំ២០០១មក ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) បានផ្តល់ថវិកាចំនួន ៤,៤៦លានដុល្លារអាមេរិកដើម្បីជួយដល់សកម្មភាពការងាររបស់ DC-Cam ។

នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៣ សហរដ្ឋអាមេរិកបានចូលរួមក្នុងការគាំទ្រនូវសេចក្តីសម្រេចចិត្តមួយក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ ដើម្បីអនុម័តលើកិច្ចព្រមព្រៀងមួយរវាងសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (ECCC ឬ សាលាក្តីខ្មែរក្រហម) ។ សេចក្តីសម្រេចចិត្តរបស់សហប្រជាជាតិនេះបានអំពាវនាវដល់សហគមន៍អន្តរជាតិឲ្យផ្តល់ជំនួយ រួមទាំងជំនួយថវិកានិងជំនួយជាបុគ្គលិកដល់សាលាក្តីខ្មែរក្រហមផងដែរ ។

សហរដ្ឋអាមេរិកពុំបានផ្តល់ថវិកាដល់សាលាក្តីខ្មែរក្រហមទេក្នុងរយៈពេលកន្លងមក រហូតដល់ពេលដែលខ្លួនយល់ឃើញថា សាលាក្តីនេះអនុវត្តបាននូវបទដ្ឋានយុត្តិធម៌អន្តរជាតិ ។ បន្ទាប់ពីការត្រួតពិនិត្យដោយការយកចិត្តទុកដាក់ចំពោះដំណើរការវិវត្តរបស់សាលាក្តីនេះរួចមក នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨ លោក John Negroponte អនុរដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិកបានប្រកាសថាក្រសួងការបរទេសសហរដ្ឋអាមេរិកមានបំណងនឹងផ្តល់ទឹកប្រាក់ចំនួន១,៨លានដុល្លាអាមេរិកដើម្បីគាំទ្រដល់សកម្មភាពនានារបស់សាលាក្តីខ្មែរក្រហម ។ ជាចុងក្រោយការផ្តល់ថវិកានឹងត្រូវធ្វើឡើងបន្ទាប់ពីការយល់ព្រមរបស់សភាអាមេរិក ។

# កុំបោះបង់ខ្ញុំអី


គីម សុវណ្ណា

សព្វថ្ងៃនេះ នាងខ្ញុំជាមន្ត្រីប៉ូលិសធ្វើការនៅក្នុងការិយាល័យបុគ្គលិកនៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប ។ ខ្ញុំពុំធ្លាប់ចាប់អារម្មណ៍លើព័ត៌មានឬទស្សនាវដ្តីបែបរន្ធត់យ៉ាងនេះឡើយ ទើបតែនៅព្រឹកថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០៥ ខ្ញុំបានឃើញទស្សនាវដ្តីស្វែងរកការពិតមួយក្បាលដែលដាក់នៅលើតុមិត្តរួមការងារ បន្ទាប់មកខ្ញុំក៏យកមកអានយ៉ាងផ្ចិតផ្ចង់ ។ នៅលើក្របសៀវភៅមានអក្សរធំៗពណ៌ក្រហមដែលមានចំណងជើងថា «ស្វែងរកការពិត» លេខ៦៥ ខែឧសភា ២០០៥ បោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ពេលចាប់ផ្តើមអានទំព័រដំបូង ខ្ញុំប្រទះឃើញរូបថតមិត្តនារីកម្មាភិបាលអាវខ្មៅម្នាក់ដែលធ្វើឲ្យបេះដូងខ្ញុំចាប់ផ្តើមលោតញាប់ជាងមុន ព្រឺក្បាល និងទឹកភ្នែកហូរមកដោយមិនដឹងខ្លួន ។ ខ្ញុំបន្តអានទស្សនាវដ្តីនេះទាំងអារម្មណ៍ពុះកញ្ជ្រោលជាមួយនឹងការរំឭកឡើងវិញពីជីវិតកុមារភាពរបស់ខ្ញុំដែលទទួលរងការឈឺចាប់និងការបាត់បង់ ។ ខ្ញុំតែងតែគិតថានៅសម័យខ្មែរក្រហមប្រហែលជាគ្មានកុមារណាម្នាក់បានជួបប្រទះភាពតក់ស្លុត និងភ័យរន្ធត់ដូចជារូបខ្ញុំឡើយ ។

ខ្ញុំជាកូនទី៦ ក្នុងចំណោមបងប្អូន៨ ម្តាយឈ្មោះ ស៊ុម ប្ញង់ និងឪពុកឈ្មោះ គីម ស៊ុំ ធ្វើជាទាហាននៅខេត្តសៀមរាប ។ នៅឆ្នាំ១៩៧៣ នៅពេលឪពុករបស់ខ្ញុំចូលនិវត្តន៍ គាត់បានទិញដីស្រែប្រមាណ២០ហិកតានៅភូមិព្រៃមាន់ ខេត្តបាត់ដំបង (សព្វថ្ងៃខេត្តបន្ទាយមានជ័យ) ។ ខ្ញុំក៏បានផ្លាស់ទៅរស់នៅទីនោះរហូតដល់ខ្មែរក្រហមចូលមកជម្លៀសប្រជាជនពីភូមិក្នុងឆ្នាំ១៩៧៥ ។ នៅពេលធ្វើដំណើរ ខ្ញុំត្រូវសម្រាកនៅតាមចញ្ចើមផ្លូវ ជួនកាលនៅក្នុងព្រៃ ។ រាល់ថ្ងៃខ្ញុំតែងតែឃើញម្តាយរបស់ខ្ញុំយំព្រោះតែគាត់បែកពីបងប្រុសទី៣ ដែលជានិស្សិតថ្នាក់ទី១ពីសង្គមចាស់ កូនស្រីទី១មានប្តីធ្វើជាទាហាន លន់ នល់ នៅខេត្តកំពង់ធំ និងកូនពីរនាក់ទៀតត្រូវខ្មែរក្រហមចាត់តាំងឲ្យធ្វើកងចល័ត ។ ខ្ញុំនៅសល់តែបងស្រីទី៥ និងប្អូនពៅប៉ុណ្ណោះ ។

នៅឆ្នាំ១៩៧៧ ខ្ញុំទើបតែមានអាយុ៧ឆ្នាំ អង្គការបានដាក់ផែនការឲ្យក្រុមគ្រួសាររបស់ខ្ញុំដាំបន្លែគ្រប់មុខព្រោះវាដំណាំសំខាន់សម្រាប់កម្មាភិបាលខ្មែរក្រហម ។ លើសពីនេះ ឪពុករបស់ខ្ញុំក៏ត្រូវចាត់តាំងឲ្យនៅដាំថ្នាំជក់ជាច្រើនរងថែមទៀត ។ ខ្ញុំអាណិតគាត់ណាស់ ព្រោះក្នុងមួយថ្ងៃៗ គាត់ត្រូវរែកទឹករាប់រយអម្រែកដើម្បីស្រោចដំណាំ ។

ខ្ញុំឃើញរទេះគោរបស់សហករណ៍មកដឹកភោគផលដំណាំដែលឪពុកខ្ញុំដាំបានជារៀងរាល់ថ្ងៃ ។ ខ្ញុំត្រូវដេររកន្ទោង ដាំស្ពៃ និងដើរបេះដង្កូវចេញពីដើមថ្នាំជក់ពុំដែលមានពេលទំនេរឡើយ ។ ទោះបីជានឿយហត់យ៉ាងណាក្តី ក៏គ្រួសារខ្ញុំរស់នៅជុំគ្នាមិនសូវខ្វះខាតអាហារហូបដូចប្រជាជនដែលរស់នៅតំបន់ផ្សេងទេ ។ នៅឆ្នាំ១៩៧៨ សភាពការណ៍អាក្រក់ក៏ចាប់ផ្តើមកើតឡើង ដោយកម្មាភិបាលខាងនិរតីចូលមកដល់និងគ្រប់គ្រងប្រជាជននៅតំបន់ភូមិភាគពាយ័ព្យ ហើយក្រុមគ្រួសាររបស់ខ្ញុំត្រូវអង្គការផ្លាស់ឲ្យទៅរស់នៅសហករណ៍ភូមិរហាល ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យវិញ ។ តាំងពីពេលនោះ ការរស់នៅរបស់គ្រួសារខ្ញុំចាប់ផ្តើមជួបការលំបាកយ៉ាងខ្លាំង ដោយត្រូវអង្គការបង្ខំឲ្យធ្វើការជាទម្ងន់និងរស់នៅបែកគ្នាទៀត ។ ខ្មែរក្រហមបានកំណត់របបអាហារសម្រាប់មនុស្សចាស់និងកុមារត្រឹមតែបបរមួយកូនចានចង្កឹះលាយនឹងដំឡូងជ្វាបីដុំប៉ុណ្ណោះ ។ ប៉ុន្តែគ្រួសារខ្ញុំមានសំណាងដោយសារឪពុកខ្ញុំឆ្លៀតពីការងារមកផ្សំថ្នាំខ្មែរដើម្បីដូរយកអង្ករ ហើយនៅក្នុងផ្ទះក៏មានអង្ករខ្លះដែលម្តាយខ្ញុំកប់ទុកសម្រាប់ត្រៀមនៅពេលហូបមិនឆ្អែតដែរ ។ នៅរដូវធ្វើស្រែ ឪពុកខ្ញុំត្រូវភ្ជួររាស់តាំងពីព្រលឹម ជួនកាលរហូតដល់យប់ជ្រៅ ចំណែកម្តាយត្រូវមើលក្មេងតូចៗចំនួន៥នាក់នៅកងកុមារ ។ មិនត្រឹមតែប៉ុណ្ណោះ ខ្មែរក្រហមថែមទាំងឲ្យគាត់រែកទឹកស្រោចដើមដូងចំនួន២០ដើមជារៀងរាល់ថ្ងៃទៀត ។

ចំណែកខ្ញុំត្រូវកាប់ដើមទន្ទ្រានខែត្រធ្វើជី ដកស្មៅ រើសក្ដួរស្រូវ និងលើកភ្លឺស្រែរហូតដល់ពេលហូបបបរថ្ងៃត្រង់ ។ បន្ទាប់មក ប្រធានកងបានប្រមូលកុមារទាំងអស់ឲ្យទៅរៀនអក្សរនៅសាលាមួយកន្លែងឆ្ងាយពីភូមិ ។ នៅទីនោះ ឈ្លបខ្មែរក្រហមបានបង្ខំកុមារតូចៗឲ្យជីកស្រះចំនួន៤ ទំហំប្រមាណ១០ម៉ែត្របួនជ្រុងក្នុងបរិវេណសាលា ដោយប្រាប់ថាទុកសម្រាប់ដាំឈូកលម្អ ។ មួយរយៈក្រោយមក ពេលម៉ោងសម្រាក ខ្ញុំជាមួយមិត្តភក្តិនៅក្នុងថ្នាក់បានរត់ទៅលេងនៅជិតស្រះដែលបានជីក ស្រាប់តែឃើញស្រះនោះត្រូវលុបជិត មានគល់ឫស្សីនិងដំបងដែកប្រឡាក់សុទ្ធតែឈាមនៅតាមមាត់ស្រះ ។ យើងចាប់ផ្តើមមានអារម្មណ៍ភិតភ័យរៀងៗខ្លួន ។ បន្តិចក្រោយមក ខ្ញុំឮសំឡេងខ្លាំងៗស្រែកពីចម្ងាយថា «នែពួកឯងឆាប់ត្រឡប់មកវិញភ្លាម» យើងក៏រត់យ៉ាងលឿនចូលក្នុងថ្នាក់វិញ ដោយម្នាក់ៗមិនហ៊ានងើបមុខមើលគ្រូបង្រៀនទេ ពីព្រោះពេលនោះគាត់បញ្ចេញទឹកមុខខឹង រួចគំរាមថា «បើពួកឯងហ៊ានទៅមើលទីនោះទៀត ពួកឯងនឹងស្ដាយក្រោយជាមិនខាន» ។ ចាប់ពីពេលនោះមក ពួកយើងបានត្រឹមតែអាចឈរមើលទៅកាន់ស្រះនោះពីចម្ងាយប៉ុណ្ណោះ ដែលក្នុងនោះមានសាកសពជាច្រើនហើមរលួយ ។ យើងមិនអាចរៀននៅទីនោះបានទៀតទេ ព្រោះតែក្លិនស្អុយរបស់សាកសពជះក្លិនមក ។ ក្រោយមក អង្គការដាក់ផែនការថ្មីប្រមូលកុមារទាំងអស់ឲ្យទៅរស់នៅក្នុងអង្គភាពវិញ ។ ខ្ញុំត្រូវរស់នៅបែកពីឪពុកម្ដាយ ប៉ុន្តែខ្ញុំមិនដែលហ៊ានស្រែកយំទេ ព្រោះខ្លាចខ្មែរក្រហមធ្វើទារុណកម្មឬយកទៅសម្លាប់ ។ ខ្ញុំដេកតម្រៀបគ្នាជាមួយកុមារជាច្រើន ថែមទាំងគ្មានភួយសម្រាប់ដណ្ដប់ទៀតផង ។ ចំណែករបបអាហារកាន់តែតិចជាងមុន គឺហូបបបររាវលាយជាមួយដំឡូងជ្វា ស្ងោរផ្ទីឬសម្លដើមចេក ។ ការហូបរបៀបនេះធ្វើឲ្យកុមារក្នុងកងមួយចំនួនបាក់កម្លាំងស្គម និងខ្លះទៀតមានជំងឺហើម ។

ជារៀងរាល់យប់ខ្ញុំតែងតែឃើញមិត្តនារីដែលជាប្រធានកងម្នាក់ដើរត្រួតពិនិត្យតាមផ្ទះ ។ នៅថ្ងៃមួយមានពន្លឺភ្លើងព្រាលៗនៅក្រោមផ្ទះ ខ្ញុំក៏ឱនមើលតាមប្រឡោះក្ដារស្រាប់តែប្រទះឃើញត្រីងៀត ប្រហុក ផ្អក ខ្លាញ់ត្រី និងពងត្រីជាច្រើនដាក់ក្នុងធុងសាំងពេញ ។ ខ្ញុំបានបង្ហើបក្ដារដែលសណ្ដកដែកគោល ហើយដោះអាវដៃវែងដែលពាក់នឹងខ្លួនយកមកចងភ្ជាប់នឹងរនាបរួចសម្រូតខ្លួនចុះមកក្រោម ។ ដោយសារមិនបានហូបម្ហូបនេះយូរមកហើយ ខ្ញុំក៏យកត្រីងៀតមកហូបទាំងឆៅរហូតទាល់តែឆ្អែត ។

ស្នាក់នៅក្នុងកងមួយរយៈ កុមារនៅក្នុងអង្គភាពចាប់ផ្ដើមស្លាប់ជាបណ្ដើរៗ ព្រោះតែហូបមិនគ្រប់គ្រាន់និងធ្វើការហួសកម្លាំង ។ ចំណែកខ្ញុំដែលបានលួចហូបត្រីនៅមានកម្លាំងអាចបន្តធ្វើការតទៅទៀតបាន ។ ក្រោយមក ដោយសារខ្ញុំនឹកឪពុកម្ដាយរបស់ខ្ញុំខ្លាំងពេក នៅយប់ស្ងាត់មួយបន្ទាប់ពីមិត្តនារីនិរតីដើរត្រួតពិនិត្យរួច ខ្ញុំក៏លូនតាមគុម្ពបេកដីក្រាស់នៅខាងក្រោយផ្ទះតម្រង់ទៅផ្ទះ ។ ខ្ញុំដើរឡើងផ្ទះលបៗ ទៅកន្លែងដែលឪពុកម្ដាយខ្ញុំសម្រាន្តរួចលូនចូលទៅឱបដាក់ត្រចៀកគាត់ថា «ម៉ែៗ» ។ ម្ដាយខ្ញុំស្ទុះឡើងស្រវាឱបខ្ញុំ ហើយនិយាយថា «កូនមាសម្ដាយ» រួចគាត់ដាស់លោកឪពុកខ្ញុំឲ្យភ្ញាក់ ។ ម្ដាយខ្ញុំនិយាយថា «កូនមកហូបបាយមក ម្ដាយបានទុកបាយឲ្យកូនជារៀងរាល់ថ្ងៃ» ។ នៅពេលមេឃជិតភ្លឺ ឪពុកខ្ញុំបានឱបប្រាប់ថា «កូនហូបបាយហើយ ឆាប់ត្រឡប់ទៅវិញចុះ» ព្រោះបើកងឈ្លបមកទាន់នោះ ពួកគេមិនទុកជីវិតកូនឡើយ ។

នៅថ្ងៃមួយ ពេលខ្ញុំនិងកុមារដទៃកំពុងឈរតម្រង់ជួរ សមមិត្តនារីនិរតីម្នាក់បានដើរមកទាញដៃឲ្យខ្ញុំចេញពីជួរ ។ ពេលនោះខ្ញុំភ័យណាស់ ហើយគិតក្នុងចិត្តថាគេនឹងយកខ្ញុំទៅសម្លាប់ហើយ ព្រោះប្រហែលជាគេដឹងថាខ្ញុំលួចហូបត្រីងៀត ។ តែផ្ទុយទៅវិញ គេប្រកាសប្រាប់ថាគេនឹងយកខ្ញុំទៅនៅជាមួយ ។ បន្ទាប់មក គេឲ្យខ្ញុំឡើងជិះរទេះគោតម្រង់ទៅភូមិរហាល ។ ខ្ញុំត្រូវស្នាក់នៅជាមួយនារីនិរតីម្នាក់លើផ្ទះមួយមានបីខ្នងសង់អំពីឈើព្រោះម្ចាស់ផ្ទះនេះត្រូវអង្គការជម្លៀសទៅតំបន់ឆ្ងាយ ។ ខ្ញុំមានជីវិតរីករាយជាងមុន ព្រោះមិត្តនារីទាំងអស់ស្រឡាញ់ខ្ញុំគ្រប់ៗគ្នា ខ្ញុំលែងខ្វះខាតការហូបចុកដូចពីមុនទៀតហើយ ។ រាល់ថ្ងៃ មិត្តនារីឲ្យខ្ញុំទៅយកបាយនិងសម្លពីរោងបាយសហករណ៍មកឲ្យគាត់ ។ ខ្ញុំមានសម្លៀកបំពាក់ថ្មីៗ សាច់ក្រណាត់តេតារ៉ុង មានកន្សែងបង់ក និងស្បែកជើងកង់ឡានដែលមិត្តនារីបើកឲ្យ ហើយខ្ញុំមានសិទ្ធិទៅជួបឪពុកម្ដាយខ្ញុំរៀងរាល់ថ្ងៃទៀតផង ។

ភាពរីករាយនេះមិនបានយូរទេ សភាពការណ៍ក៏ផ្លាស់ប្តូរ

ដោយអង្គការប្រកាសថា នរណាដែលមានជាប់ខ្សែចិន យួន ឬ និស្សិតបញ្ញវន្តអាចទៅរស់នៅស្រុកកំណើតវិញ ។ ប្រជាជនដែលប្រាប់ពីប្រវត្តិរូបពិតត្រូវកងឈ្លបខ្មែរក្រហមចាប់មកឃុំឃាំង និងធ្វើទារុណកម្មនៅលើផ្ទះដែលខ្ញុំស្នាក់នៅរាល់យប់ ។ នៅក្នុងភូមិមានលក្ខណៈស្ងាត់ជ្រងំ ឮតែសំឡេងឆ្កែលូនិងសំឡេងថ្ងូររបស់ប្រជាជនដែលត្រូវកងឈ្លបធ្វើទារុណកម្ម ។ ការសួរចម្លើយមានរយៈពេល២-៣ម៉ោង រួចហើយឈ្លបបានដឹកអ្នកទោសទាំងនោះតាមរទេះគោចេញទៅបាត់ ដោយមិនមាននរណាម្នាក់មានវាសនាត្រឡប់ទៅផ្ទះវិញឡើយ ។ នៅពេលព្រឹក មិត្តនារីនិរតីបានបញ្ជាឲ្យចុងភៅនៅរោងបាយសហករណ៍ដាំទឹកក្តៅកន្លះខ្ទះគ្នោត ហើយឲ្យខ្ញុំទៅរែកយកមកលាងឈាមនៅលើផ្ទះ ។ មិត្តនារីមិនអនុញ្ញាតឲ្យអ្នកផ្សេងលាងសម្អាតទេ និងបានហាមឃាត់ខ្ញុំមិនឲ្យខ្ញុំទៅលេងផ្ទះដូចមុនទៀតដែរព្រោះខ្លាចបែកការណ៍ ។ ខ្ញុំហូបមិនបាន ដេកមិនលក់ព្រោះតែក្លិនស្អាបឈាមនិងសំឡេងថ្ងូររបស់អ្នកទោសនៅលើផ្ទះ ។ ពេលខ្លះខ្ញុំចង់រត់ទៅផ្ទះវិញដែរ ក៏ប៉ុន្តែខ្ញុំខ្លាចខ្លួនឯងមានសំណាងអាក្រក់ដូចកុមារដទៃៗទៀតដែលត្រូវឈ្លបសម្លាប់ចោល ។

យប់មួយខ្ញុំឮសម្រិបអ្នកសមនុស្សចូលផ្ទះ ខ្ញុំក្រឡេកទៅឃើញបងប្អូនរបស់ខ្ញុំមាន អ៊ី ពូ មីង និង បងថ្លៃប្រុសត្រូវឈ្លបចងស្លាបសេកបន្តគ្នា ។ បងថ្លៃខ្ញុំមានសម្បុរសស្បែកខៅខ្ចី មាឌរាងខ្ពស់ ហើយមុខរបស់គាត់ត្រូវគេវ៉ៃហូរឈាមរហាម ។ មិត្តនារីនិរតីបានគំរាមបងថ្លៃខ្ញុំថា «មិត្ត វ៉ា ងើបមុខឡើង» ។ បន្ទាប់មក គាត់ក៏ងើបមុខហើយសម្លឹងចំមុខខ្ញុំ ។ ខ្ញុំរន្ធត់ស្ទើរតែទប់ចិត្តមិនបាន ខ្ញុំបានយកដៃទាំងពីរមកបិទមាត់ជិត ហើយលូនចូលទៅសម្ងំក្រោមគ្រែរហូតដេកលក់ ។ ពេលភ្ញាក់ដឹងខ្លួន ស្រាប់តែបាត់មនុស្សអស់រលីង ខ្ញុំបានដើរលបៗចេញមកក្រៅដោយជាប់ឈាមនៅនឹងបាតជើងទៀតផង ។ ខ្ញុំមកអង្គុយយំនៅកាំជណ្តើរផ្ទះ បន្ទាប់មក មិត្តនារីបានដើរមកអួសដៃខ្ញុំ ហើយនិយាយថា «អូនតូចទៅដេកទៅ កុំខ្លាចអី គេទៅបាត់អស់ហើយ» ។ ប៉ុន្តែខ្ញុំនៅតែនៅក្រាញមិនព្រមទៅ ដេកជាមួយពួកគេឡើយ ខ្ញុំនៅអង្គុយយំរហូតទល់ភ្លឺ ។

ដោយមិនអស់ចិត្ត នៅពេលព្រឹកមេឃមិនទាន់ភ្លឺច្បាស់ ខ្ញុំងើបឈរលើកាំជណ្តើរ រួចឡើងទៅអើតមើលផ្ទះម្តងទៀត ឃើញឈាមនិងឧបករណ៍ធ្វើទារុណកម្មនៅពេញលើផ្ទះ ។ បន្ទាប់មក ខ្ញុំដើរទៅផ្ទះបាយសហករណ៍ដើម្បីយកទឹកក្តៅមកលាងឈាមដូចសព្វដង ស្រាប់តែបងស្រីជីដូនមួយរបស់ខ្ញុំដើរយំពីចម្ងាយធ្វើឲ្យខ្ញុំឈរទ្រឹងមួយកន្លែង ដៃកាន់ធុងទឹកក្តៅនៅឡើយ គាត់ដើរមកជិតខ្ញុំទាំងដង្ហក់ថា «មីអូនពុកឯងស្លាប់ហើយ» ។ គ្រាន់តែឮពាក្យនេះ ខ្ញុំទម្លាក់ធុងទឹកចុះ រួចរត់សំដៅទៅផ្ទះ ។ ពេលទៅដល់ ខ្ញុំឃើញម្តាយខ្ញុំយំឱបប្អូនពៅនៅក្បែរជញ្ជាំងផ្ទះ រួចនិយាយប្រាប់ខ្ញុំទាំងទឹកភ្នែកថា «ឪពុករបស់កូនចងកសម្លាប់ខ្លួនហើយ ព្រោះខ្លាចឈ្លបយកទៅធ្វើទារុណកម្ម» ។ ខ្មែរក្រហមមិនអនុញ្ញាតឲ្យធ្វើពិធីបុណ្យសពឪពុករបស់ខ្ញុំទេ ដោយពួកគេជីករណ្តៅនៅពីក្រោមដើមអម្ពិលដែលគាត់ចងក រួចកាត់ខ្សែទម្លាក់ចុះរណ្តៅកប់នៅទីនោះ ។ ចំណែកបងថ្លៃរបស់ខ្ញុំត្រូវឈ្លបយកទៅសម្លាប់មួយថ្ងៃមុនឪពុករបស់ខ្ញុំស្លាប់ដែរ ។ គ្រួសារខ្ញុំមិនមានអ្វីទីពឹងទៀតទេ រាល់ថ្ងៃយើងទទួលតែបបររាវៗលាយជាមួយនឹងដំឡូងប៉ុណ្ណោះ ។ ប៉ុន្តែខ្ញុំខិតខំឆ្លៀតឱកាសលួចគាស់គល់ចេកមកលាងទឹកចិតជាចំណិតៗ មកដាំលាយជាមួយបបរបន្ថែម ។

ខ្ញុំត្រូវកុមារនៅមូលដ្ឋានមិនឲ្យដើរចូលហ្វូងជាមួយទេ ដោយចោទថាខ្ញុំជាកូនខ្មាំងនិងបានវាយធ្វើបាបខ្ញុំ រួចដោះយកខោអាវក្រណាត់តេតារ៉ុនរបស់ខ្ញុំ ថែមទាំងប្រមាថថា «ខ្មាំងមិនសមនឹងស្លៀកសម្លៀកបំពាក់ល្អនោះទេ មានតែខោអាវជ្រលក់ទឹកខ្មៅនេះទើបសម» ។ ចំណែកម្តាយរបស់ខ្ញុំគាត់ត្រូវកងឈ្លបនាំទៅសួរចម្លើយរៀងរាល់ថ្ងៃ ព្រោះក្រុមគ្រួសាររបស់ខ្ញុំស្ថិតក្រោមការតាមដានរបស់អង្គការ យើងរស់នៅទាំងក្តីអស់សង្ឃឹមនិងរង់ចាំតែសេចក្តីស្លាប់ប៉ុណ្ណោះ ។ ជាភ័ព្វសំណាង នៅរដូវច្រូតកាត់ នៅតាមថ្នល់ជាតិខ្ញុំឮសំឡេងគ្រាប់កាំភ្លើងធំលាន់ក្អិលៗ ។ ម្តាយខ្ញុំនៅពេលនោះមានជំងឺជាប្រចាំ គាត់ឈឺរីងរៃព្រោះតែនឹកឪពុកនិងបងប្អូនដែលស្លាប់ ។

នៅដើមឆ្នាំ១៩៨០ គ្រួសារខ្ញុំក៏ត្រឡប់មករស់នៅស្រុកកំណើតខាងឪពុកខ្ញុំវិញ គឺភូមិស្នាយគ្រាង ឃុំធ្លក ស្រុកស្វាយរៀង ខេត្តស្វាយរៀង ។ មិនយូរប៉ុន្មានម្តាយខ្ញុំក៏ស្លាប់ទៀត ។ ចុងក្រោយការចងចាំនិងការចងគំនុំចំពោះបនប្រល័យពូជសាសន៍ មិនអាចធ្វើឲ្យខ្ញុំបំភ្លេចបានជារៀងរហូត ។ **គីម សុខណ្ណា**

# កំព្រាឪពុកម្តាយ


ខន ស្រីមុំ ក្នុងឆ្នាំ១៩៨៧

ខន ស្រីមុំ គឺជាកូនពៅក្នុងគ្រួសារដែលមានសមាជិក ២នាក់ ។ មុនឆ្នាំ១៩៧៥ គ្រួសាររបស់ខ្ញុំរស់នៅទីក្រុងភ្នំពេញ ។

នៅឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញ ក្រុមគ្រួសារនាងខ្ញុំត្រូវបានជម្លៀសទៅខេត្តពោធិ៍សាត់ ។ នៅទីនោះ ឪពុករបស់ខ្ញុំត្រូវខ្មែរក្រហមចាត់តាំងឲ្យធ្វើការនៅក្នុងកងភ្ជួរស្រែ ។ គាត់តែងតែក្រោកពីព្រឹកទៅភ្ជួរស្រែជារៀងរាល់ថ្ងៃ ប៉ុន្តែអាហារដែលគាត់ទទួលបានគឺហូបតែបបរ មានថ្ងៃខ្លះពុំមានអ្វីហូបទៀតផង ។ មិនយូរប៉ុន្មាន ឪពុករបស់ខ្ញុំក៏ធ្លាក់ខ្លួនឈឺដោយមានជំងឺហើម ។ នៅពេលនោះ គាត់ក៏បានដើរទៅសុំកន្ទួតពីមេកងយកមកធ្វើថ្នាំព្យាបាល ប៉ុន្តែមេកងនោះពុំព្រមឲ្យគាត់ឡើយ ។ រហូតដល់ថ្ងៃមួយនៅពេលដែលឪពុកខ្ញុំជិតដាច់ខ្យល់ គាត់បានប្រាប់ម្តាយខ្ញុំថាគាត់ឃ្លានបាយណាស់ ។ ដោយសារតែអាណិតឪពុកខ្ញុំខ្លាំងពេក ម្តាយខ្ញុំក៏ដាច់ចិត្តទៅសុំបាយពីមេកងទាំងយប់ ដោយប្រាប់ថា «ប្តីខ្ញុំជិតស្លាប់ហើយ ឥឡូវគាត់ស្រែកថាឃ្លានបាយណាស់» ។ ក្រោយពេលដែលម្តាយខ្ញុំយកបាយ ទៅបញ្ចុកឪពុកខ្ញុំ គាត់និយាយថាបាយនេះស្រួយណាស់ រួចហើយក៏ដាច់ខ្យល់នៅវេលាម៉ោង១០យប់ ។ មុនពេលដែលឪពុកខ្ញុំស្លាប់ គាត់បានផ្តាំម្តាយរបស់ខ្ញុំថា «សូមអូនមើលកូនទាំងពីរឲ្យបានល្អផង» ។ ក្នុងខណៈនោះ ខ្ញុំទើបតែមានអាយុ៩ឆ្នាំ ចំណែកបងប្រុសខ្ញុំឈ្មោះ ខន ចាន់នី អាយុ១១ឆ្នាំ ត្រូវរស់នៅដោយគ្មានឪពុក ។ ជារៀងរាល់យប់ ម្តាយខ្ញុំតែងតែទៅលួចអង្ករលួចត្រីយកមកចម្អិនឲ្យខ្ញុំនិងបងប្រុសហូបបំពេញក្រពះ ។

នៅក្នុងឆ្នាំ១៩៧៧ ពេលដែលម្តាយរបស់ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើជាចុងភៅ គាត់តែងតែលាក់អំបិលទុកបន្តិចបន្តួចយកឲ្យខ្ញុំទាំងពីរ ។ ដោយសារតែបាត់អំបិលពីកាម៉ែល ខ្មែរក្រហមបានសួរម្តាយខ្ញុំ ហើយគាត់ក៏ប្រាប់ទៅវិញថា *«អំបិលនោះអស់ហើយ»* រួចម្តាយរបស់ខ្ញុំបានស្បថថា *«បើសិនជាខ្ញុំបានលាក់អំបិលនោះទុកមែន ឲ្យខ្ញុំស្លាប់ចោលកូនសម្លាញ់ទាំងពីរទៅចុះ»* ។ នៅវេលាម៉ោង១២យប់នោះ ស្រាប់តែម្តាយខ្ញុំឈឺពោះផង រាកផង រហូតដល់ព្រឹកឡើងទើបខ្មែរក្រហមបញ្ជូនគាត់ទៅព្យាបាលនៅមន្ទីរពេទ្យ ហើយគាត់ក៏ស្លាប់នៅទីនោះទៅ ។ បន្ទាប់មកបងប្រុសខ្ញុំបានរត់មកប្រាប់ខ្ញុំទាំងទឹកភ្នែកថា *«ម៉ែយើងស្លាប់ចោលយើងហើយអូន»* ។ ពេលឮដូច្នោះ ខ្ញុំអស់សង្ឃឹមយ៉ាងខ្លាំង ហើយយំឱបគ្នាទាំងពីរនាក់បងប្អូន ។ ឪពុកម្តាយខ្ញុំស្លាប់នៅក្នុងសហករណ៍ភូមិពោធិ៍ ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ ។

ក្រោយពេលដែលឪពុកម្តាយខ្ញុំស្លាប់ ខ្មែរក្រហមបានបំបែកបងប្រុសខ្ញុំឲ្យទៅរស់នៅកងផ្សេងពីខ្ញុំ ។ រៀងរាល់យប់គាត់តែងតែលួចមកដេកជាមួយខ្ញុំ ហើយក្រោកវិញនៅម៉ោង៥ទៀបភ្លឺត្រឡប់ទៅកងគាត់វិញ ។ ដោយមិនចង់បែកពីបង ខ្ញុំក៏រត់ទៅនៅកងជាមួយគាត់ ។ នៅទីនោះយើងទាំងពីរហូបមិនបានគ្រប់គ្រាន់ទេ ដោយសារបាយមួយចំណែករបស់គាត់ត្រូវបានចែករំលែកមកឲ្យខ្ញុំ ។

លុះដល់ឆ្នាំ១៩៧៩ ពេលដែលវៀតណាមចូលមករំដោះ ខ្ញុំនិងបងប្រុសបានសុំអ្នកភូមិជិះរទេះគោក្នុងពេលយប់ដើម្បីគេចពីខ្មែរក្រហម ដោយយើងទាំងពីរនាក់ក្រាបនឹងបាតរទេះគោ ព្រោះខ្លាចខ្មែរក្រហមឃើញ ។ ខ្ញុំនិងបងប្រុសស្ពាយមុង ភួយ អង្ករ កាម៉ែល ធ្វើដំណើរទៅភូមិតាឡូដើម្បីតាមរកមីងនិងអ៊ំដែលត្រូវខ្មែរក្រហមចាត់តាំងឲ្យទៅជីកប្រឡាយនៅទីនោះ ។ ប្រហែលជាមួយខែកន្លះទើបយើងធ្វើដំណើរទៅដល់ភូមិតាឡូ ប៉ុន្តែយើងរកគាត់ទាំងពីរមិនឃើញសោះ ហើយថែមទាំងមិនដឹងថាស្លាប់ឬរស់ទៀតផង ។

ស្នាក់នៅទីនោះរយៈពេលកន្លះខែ ទើបយើងទាំងពីរធ្វើដំណើរមកដល់ភូមិបឹងខ្នារ ស្រុកបាកាន រួចក៏បានជួបពូមីងពីរនាក់ប្តីប្រពន្ធសុំយើងទាំងពីរនាក់ធ្វើជាកូន ប៉ុន្តែខ្ញុំទាំងពីរនាក់មិនព្រម

ហើយក៏បន្តដំណើរទៅស្រុកកណ្តៀង ។ នៅពេលនោះមាននារីខ្មែរក្រហមពីរនាក់សុំខ្ញុំទាំងពីរយកទៅចិញ្ចឹមដោយរស់នៅដាច់ពីគ្នា ប៉ុន្តែយើងទាំងពីរនាក់តែងតែស្អាត់ជួបគ្នាជារៀងរាល់ថ្ងៃ ។ ថ្ងៃមួយនារីខ្មែរក្រហមដឹងថាខ្ញុំស្អាត់ទៅជួបនឹងបង គាត់ក៏បានយកខ្ញុំទៅព្រៃស្វាត់ ដោយគំរាមខ្ញុំថា «បើឯងហ៊ានទៅជួបបងប្រុសទៀត គាត់នឹងសម្លាប់ខ្ញុំចោល» ។ ដោយភ័យខ្លាចខ្លាំងពេក ខ្ញុំក៏បានសន្យាជាមួយគាត់ថាឈប់ទៅជួបជាមួយបងប្រុសខ្ញុំទៀតហើយ ។

មិនយូរប៉ុន្មាន កងទ័ពវៀតណាមក៏ឡើងទៅរំដោះដល់ភ្នំក្រវាញ ។ ចាប់តាំងពីពេលនោះមក ខ្ញុំបាត់ដំណឹងពីបងប្រុសរហូត រួចខ្ញុំក៏សម្រេចចិត្តត្រឡប់មករស់នៅទីរួមខេត្តពោធិ៍សាត់វិញ ។

**ខន ស្រីមុំ**

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” នៃមជ្ឈមណ្ឌលឯកសារកម្ពុជាឥឡូវនេះបានចាប់ផ្តើមបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យនិងព្រឹត្តិការណ៍វិវត្តន៍នៃអង្គជំនុំជម្រះវិសាមញ្ញដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខឆាប់ៗនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

“ការិយាល័យព័ត៌មានសាធារណៈ” មានផ្តល់ជូននូវសេវា៣យ៉ាង ៖

**១) បណ្ណាល័យ ៖** នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ ៖** មជ្ឈមណ្ឌលមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនានៅរៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ នៅវេលាម៉ោង៩ព្រឹកនិង៣រសៀល ។

**៣) ក្រុមការងារផ្នែកតុលាការ ៖** ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ិរិ សាវីណា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

## លិខិតថ្លែងអំណរគុណ

ខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានផ្តល់ឱកាសឲ្យនាងខ្ញុំបានសរសេរអត្ថបទរៀបរាប់ពីរឿងរ៉ាវផ្ទាល់ខ្លួនដែលបានលាក់ទុកក្នុងចិត្តជាយូរណាស់មកហើយ ដើម្បីឲ្យប្រជាជននិងក្មេងជំនាន់បានយល់ដឹងពីអំពើឃោឃៅនៅរយៈកាល៣ឆ្នាំ ៨ខែ ២០ថ្ងៃ នៃការគ្រប់គ្រងរបស់ខ្មែរក្រហម ។ ខ្ញុំសំណូមពរឲ្យទស្សនាវដ្តីស្វែងរកការពិតផ្សព្វផ្សាយទៅដល់ប្រជាជនដែលរស់នៅក្នុងភូមិរហាល ឃុំរហាល ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ដើម្បីឲ្យពួកគេបានដឹងអំពីជីវិតកុមារភាពរបស់នាងខ្ញុំនៅក្នុងសម័យខ្មែរក្រហមផង ។

គោលបំណងសំខាន់របស់ខ្ញុំ គឺសុំឲ្យសន្តិភាពនៅជារៀងរហូត បើទោះបីខ្ញុំជាមន្ត្រីប៉ូលិសមានស្វាមីជាយោធាខេត្តដែលមានបៀវត្សរ៍តិចតួចក៏ដោយ ក៏យើងរស់នៅជួបជុំគ្រួសារយ៉ាងមានសុភមង្គលនិងមានសេរីភាពគ្រប់គ្រាន់និងមិនព្រួយបារម្ភខ្លាចខ្វះអាហារនិងការយកទៅសម្លាប់ចោលដូចជារបបខ្មែរក្រហមដែរ ។

ជាថ្មីម្តងទៀត នាងខ្ញុំសូមថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជានិងរាជរដ្ឋាភិបាលដ៏ឈ្លាសវៃ ដែលបានបង្កើតឲ្យមានកម្មវិធីស្រាវជ្រាវអំពើប្រល័យពូជសាសន៍នេះឡើង ដើម្បីរកយុត្តិជូនប្រជាជនស្លូតត្រង់ដែលបានស្លាប់ ។ **គីម សុវណ្ណា**

## សេចក្តីប្រកាសរកបងប្រុសទី៤ឈ្មោះ ប៉ាក វ៉ាន

ខ្ញុំបាទឈ្មោះ ប៉ាក វ៉ាត មានឪពុកឈ្មោះ ប៉ាក ហែម ម្តាយឈ្មោះ សូ ឈូក រស់នៅភូមិអំពែង ឃុំអង្កោល ស្រុកដំណាក់ចង្អើរ ក្រុងកែប ។ សូមប្រកាសរកបងប្រុសទី៤ឈ្មោះ ប៉ាក វ៉ាន ដែលបានចូលធ្វើទ័ពនៅទីក្រុងហាណូយប្រទេសវៀតណាមខាងជើងនៅឆ្នាំ១៩៦៨ ។ នៅឆ្នាំ១៩៧៥ ស្រាប់តែមានអ្នកភូមិម្នាក់បានមកប្រាប់ដំណឹងថាបានឃើញ វ៉ាន ត្រឡប់មកស្រុកកំណើតវិញ បន្ទាប់មកគាត់ត្រូវបានខ្មែរក្រហមបញ្ជូនទៅធ្វើការខាងនេសាទ រួចក៏រត់ទៅរស់នៅកោះត្រល់ ។ ក្រោយថ្ងៃរំដោះឆ្នាំ១៩៧៩ មានស្ត្រីម្នាក់រស់នៅទីក្រុងភ្នំពេញបានយកអាសយដ្ឋានរបស់គាត់មកប្រគល់ឲ្យខ្ញុំ និងប្រាប់ថា បងវ៉ាន កំពុងរស់នៅសហរដ្ឋអាមេរិក ។ ប៉ុន្តែ សព្វថ្ងៃនេះខ្ញុំមិនដែលបានទទួលដំណឹងពីគាត់ឡើយ ។

ប្រសិនបើបងណាបានស្គាល់ ឬព្រួឈ្មោះ សូមបងទាក់ទងមកអាសយដ្ឋានភូមិអំពែង សង្កាត់អង្កោល ខណ្ឌដំណាក់ចង្អើរ ក្រុងកែប ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ក្រុងភ្នំពេញ ឬតាមរយៈទូរសព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ

## សេចក្តីប្រកាសរកបងប្រុសទី២ឈ្មោះ លឹម វេងស៊ីម

ខ្ញុំបាទឈ្មោះ លឹម វេងហួ ឬ អ៊ិត ហួ អាយុ៥៧ឆ្នាំ រស់នៅភូមិតាកុល ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ លឹម សៀកឃុន (ស្លាប់) ម្តាយ ស៊ីហ្គេចហួយ ឬ អ៊ិត ហួន សព្វថ្ងៃនៅរស់ ។ ខ្ញុំបាទមានបងប្អូនបង្កើតទាំងអស់៧នាក់ (ស្លាប់ម្នាក់ក្នុងសម័យខ្មែរក្រហម) គឺៈ ទី១) លឹម វេងគង់ (ស្លាប់) ទី២) លឹម វេងស៊ីម ទី៣) លឹម វេងអាង ឬអ៊ិត អាន ទី៤) លឹម សាវ៉ានី ឬ អ៊ិត សាវ៉ានី និងទី៥) លឹម អុកឡារី ឬ អ៊ិត ឡារី ។

ខ្ញុំសូមប្រកាសរកបងប្រុសទី២ឈ្មោះ លឹម វេងស៊ីម កាលពីជំនាន់ខ្មែរក្រហមធ្វើជាទាហានទ័ពអាកាសនៅខេត្តកំពង់សោម ។ នៅឆ្នាំ១៩៧៥ វេងស៊ីម ត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅស្រុកកំពង់ត្របែក ខេត្តព្រៃវែង ។ នៅឆ្នាំ១៩៧៨ វេងស៊ីម ត្រូវអង្គការបញ្ជូនឲ្យធ្វើការនៅស្រុកមោងឫស្សី ខេត្តបាត់ដំបងវិញ ។ នៅខែមករា ឆ្នាំ១៩៧៩ ខ្ញុំបានទទួលដំណឹងតាមរយៈអ្នកភូមិថាបានឃើញគាត់នៅព្រំដែនថៃ ។ ក្រោយមកមិនដែលបានទទួលដំណឹងពីគាត់ទេ ។

ប្រសិនបើបងប្អូនណាបានឃើញ ឬស្គាល់ សូមមេត្តាទាក់ទងមកខ្ញុំបាទតាមរយៈទូរសព្ទលេខ ០១២ ៨៤៣ ៣៣០ ឬ ០១៥ ៨៤៣ ៣៣០ ឬ ០១២ ៩៧១ ៨៧៩ ឬ ០១៦ ៩៧១ ៨៧៩ ។



ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុីតដេន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 105, September 2008 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.